**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សន្តតិកម្មតាមមតកសាសន៍

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ញាណ ចិត្រា**

**ក. ឌីណាល់ ស្រីម៉ុច**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ីង គីមឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ញាណា ចិត្រា** និង **ឌីណាល់ ស្រីម៉ុច** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ (សិស្សបង់ថ្លៃ) ឆ្នាំសិក្សា២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមលំឱនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

**-លោកឪពុកអ្នកម្តាយ** ដែលបានផ្តល់កំណើតដល់រូបកូន ព្រមទាំងបានលះបង់ទាំងកម្លាំងកាយចិត្ត ចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ ទំនុកបម្រុងដល់រូបកូនគ្រប់បែបយ៉ាងទាំងស្មារតី និងសម្ភារៈ ព្រមទាំងបានខិតខំប្រឹងប្រែងដើម្បីឲ្យកូនបានសិក្សារៀនសូត្រ ចាប់តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។

**-ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង លោក លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្តក្នុងកិច្ចដឹកនាំ គ្រប់គ្រង ជាពិសេសបង្ហាត់បង្រៀន ផ្តល់ដំបូន្មាន ក៏ដូចជាបទពិសោធន៍ល្អៗជាច្រើនដែលជាទ្រព្យដ៏គាប់ប្រសើរ និងមានតម្លៃឥតគណនាសម្រាប់និស្សិតគ្រប់រូប ដើម្បីជាស្ពានចម្លងទៅថ្ងៃអនាគតដ៏ភ្លឺស្វាង។

**-លោកសាស្ត្រាចារ្យ ហ៊ីង គឹមឡេង** ដែលជាសាស្ត្រាចារ្យណែនាំក្នុងសារណាបញ្ចប់ការសិក្សា។ ក្នុងអំឡុងពេលនេះ លោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការបង្ហាត់បង្ហាញ ណែនាំ ផ្តល់ដំបូន្មានល្អៗ ជួយជ្រោមជ្រែង កែសម្រួល និងលើកទឹកចិត្តយើងខ្ញុំក្នុងការស្រាវជ្រាវ និងចងក្រងសារណាបញ្ចប់ការសិក្សានេះឡើង។

យើងខ្ញុំសូមធ្វើការខន្តីអភ័យទោសនូវរាល់ចំណុចអវិជ្ជមាន រួមមានពាក្យពេចន៍ អក្ខរាវិរុទ្ធដែលកើតមានឡើងដោយកំហុសអចេតនា។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួង ដល់វត្ថុស័ក្តិសិទ្ធក្នុងលោក ព្រមទាំងទេវតាឆ្នាំថ្មី សូមតាមជួយថែរក្សាដល់លោកអ្នកមានគុណទាំងពីរ លោក លោកស្រីសាស្ត្រាចារ្យ និងសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការប្រកបដោយសេចក្តីសុខ ចម្រើន និងសម្រេចនូវរាល់បំណងប្រាថ្នាទាំងអស់។

# អារម្ភកថា

យើងខ្ញុំទាំងពីររូប សូមគោរពចំពោះលោកឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យ មិត្តអ្នកអាន និងនិស្សិតគ្រប់រូបដោយសេចក្តីគោរព និងសេចក្តីស្រឡាញ់។

យើងខ្ញុំទាំងពីររូប គឺជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៨-២០១៩ ដែលត្រូវបានប្រធានការិយាល័យស្រាវជ្រាវ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយបានអនុញ្ញាតឲ្យយើងខ្ញុំស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សា លើប្រធានបទដែលយើងខ្ញុំបានស្នើសុំ "សន្តតិកម្មតាមមតកសាសន៍" ដើម្បីចងក្រងជាឯកសារ និងសម្រាប់តម្កល់ទុកជាវត្ថុអនុស្សាវរីយ៍នៅក្នុងបណ្ណាល័យ សម្រាប់មិត្តអ្នកអាន និងនិស្សិតជំនាន់ក្រោយសិក្សាស្វែងយល់ទៅលើរបបសន្តតិកម្មតាមមតកសាសន៍នេះ។

សៀវភៅនេះ គឺជាផ្នែកមួយជួយឲ្យមិត្តអ្នកអានទទួលបានចំណេះដឹងបន្ថែមខាងផ្នែកច្បាប់ជាពិសេស គឺជួយឲ្យអ្នកទាំងអស់គ្នាទទួលបាននូវពុទ្ធិបន្ថែមដែលទាក់ទងនឹងរបបសន្តតិកម្មតាមមតកសាសន៍ ដែលបញ្ហានេះកំពុងតែកើតមានឡើងនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ហើយចំណេះដឹងនេះ ជួយឲ្យអ្នកទាំងអស់គ្នាអាចដោះស្រាយរាល់បញ្ហាដែលកើតមានចំពោះខ្លួន គ្រួសារ និងសង្គមជាតិ ជាអាទិ៍។

ចំណេះដឹងគឺជាអំណាច និងជាអាវុធដ៏មុតស្រួច សម្រាប់ធ្វើឲ្យមនុស្សមិនឆាប់ចាញ់បោកគេ ធ្វើឲ្យមនុស្សមានភាពក្លាហាន និងចេះដោះស្រាយរាល់បញ្ហាដែលកើតមាន។ ចំណេះវិជ្ជាគឺជាពន្លឺបំភ្លឺផ្លូវ ដែលនាំឲ្យយើងដើរតាមផ្លូវត្រូវ និងមិនធ្លាក់ក្នុងផ្លូវខុស។ ប្រទេសជាតិមួយមានការរីកចម្រើនលូតលាស់ និងមានការអភិវឌ្ឍន៍បានលុះត្រាតែសិស្ស-និស្សិត ឬប្រជាជននៃប្រទេសនោះមានចំណេះដឹងខ្ពង់ខ្ពស់ មានរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងបានល្អ មានសណ្តាប់ធ្នាប់ល្អ និងមានសុខសន្តិភាព។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរអរគុណចំពោះ ឯកឧត្តម លោក-លោកស្រីសាស្ត្រាចារ្យ សិស្សនិស្សិត មិត្តអ្នកអានទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងយកចិត្តទុកដាក់ក្នុងការអានសៀវភៅរបស់យើងខ្ញុំ ហើយសូមជូនពរឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១

**ជំពូកទី១**

**មូលដ្ឋាននៃការបង្កើតមតកសាសន៍**

**ផ្នែកទី១៖ លក្ខណៈទូទៅនៃមតកសាសន៍ និងសមត្ថភាពនៃការធ្វើមតកសាសន៍** ........ ៣

**កថាខណ្ឌទី១៖ លក្ខណៈទូទៅនៃមតកសាសន៍** ........ ៣

១.ការធ្វើមតកសាសន៍ដោយឯកតោភាគី ........ ៣

២.មតកសាសន៍ក្រោយមរណភាពរបស់មតកជន ........ ៣

៣.មតកសាសន៍ដែលត្រូវបានកំណត់ដោយបញ្ញត្តិច្បាប់ ........ ៣

៤.មតកសាសន៍ដែលកំណត់ដោយបុគ្គល ........ ៤

**កថាខណ្ឌទី២៖ សមត្ថភាពក្នុងការធ្វើមតកសាសន៍** ........ ៤

១.បុគ្គលដែលមានសមត្ថភាព ........ ៤

២.ការតាក់តែងមតកសាសន៍ ........ ៤

**ផ្នែកទី២៖ ទម្រង់ និងខ្លឹមសារនៃមតកសាសន៍** ........ ៥

**កថាខណ្ឌទី១៖ ទម្រង់នៃមតកសាសន៍** ........ ៥

១.បុគ្គលដែលមិនមានលក្ខណៈសម្បត្តិជាសាក្សី ........ ៥

២.ទម្រង់នៃមតកសាសន៍ក្នុងករណីធម្មតា ........ ៦

៣.មតកសាសន៍ក្នុងករណីពិសេស ........ ៨

**កថាខណ្ឌទី២៖ ខ្លឹមសារនៃមតកសាសន៍** ........ ១២

១.ការផ្ដាច់មត៌កពីជនដែលសន្មតថាជាសន្តតិជន ........ ១២

៣.ការកំណត់នូវវិធីបែងចែកមត៌ក ........ ១៤

៤.ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ដោយខ្លឹមសារនៃមតកសាសន៍ ........ ១៥

៥.ករណីមតកជនហាមឃាត់មិនឲ្យបែងចែកក្នុងរយៈពេលកំណត់ ........ ១៥

**ផ្នែកទី៣៖ ការលុបចោលមតកសាសន៍ និង អានុភាពនៃមតកសាសន៍** ........ ១៦

**កថាខណ្ឌទី១៖ ការលុបចោលមតកសាសន៍** ........ ១៦

១.ទម្រង់នៃការលុបចោលមតកសាសន៍ ........ ១៦

**កថាខណ្ឌទី២៖ អានុភាពនៃមតកសាសន៍**................................................................១៨
១.អានុភាពនៃមតកសាសន៍ក្នុងករណីមានលក្ខខណ្ឌបង្អង់..........................................១៨
២.អានុភាពនៃការកំណត់ចំណែកមតិក........................................................................១៨

## ជំពូកទី២

## ការប្រតិបត្តិមតកសាសន៍

**ផ្នែកទី១៖ ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ សិទ្ធិអំណាច និងការប្រតិបត្តិមតកសាសន៍**......................................................................................................................២១
**កថាខណ្ឌទី១៖ ការកំណត់អ្នកប្រតិបត្តិមតកសាសន៍** ...............................................២១
១.ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ដោយមតកជន ................................................២១
២.ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ដោយផ្លូវតុលាការ .....................................២២
៣.ការដាស់តឿនឲ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ .........................................២៣
**កថាខណ្ឌទី២៖ សិទ្ធិអំណាចអ្នកប្រតិបត្តិមតកសាសន៍**...........................................២៣
១.តួនាទី និងសិទ្ធិអំណាចអ្នកប្រតិបត្តិមតកសាសន៍ ..................................................២៣
២.សោហ៊ុយ និងកម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍ ....................................................២៤
៣.ការឈប់ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ ..................................................២៥
**កថាខណ្ឌទី៣៖ ការប្រតិបត្តិមតកសាសន៍**.................................................................២៥
១.នីតិវិធីមុននៃការអនុវត្តមតកសាសន៍.......................................................................២៥
**ផ្នែកទី២៖ អច្ច័យទាន និងនីតិវិធីនៃការបែងចែកមត៌ក**...........................................៣០
**កថាខណ្ឌទី១៖ អច្ច័យទាន និងអច្ច័យលាភី**.............................................................៣០
១.អច្ច័យទាន ............................................................................................................៣០
២.អច្ច័យលាភី............................................................................................................៣២
៣.ការលុបចោល ........................................................................................................៣៤
**កថាខណ្ឌទី២៖ នីតិវិធីនៃការបែងចែកមត៌ក** ............................................................៣៤
១.ការបែងចែកតាមសន្តិវិធី .........................................................................................៣៤
២.មូលដ្ឋាននៃការបែងចែក..........................................................................................៣៥
៣.ការបែងចែកក្នុងករណីអវត្តមានសន្តតិជនខ្លះ.............................................................៣៦
៤.ការបែងចែកក្នុងករណីអច្ច័យទានមោឃៈ..................................................................៣៦
៥.ការបែងចែកដោយតុលាការ.......................................................................................៣៧

៦.ជនដែលទទួលស្គាល់ក្រោយការបែងចែក និងការទាមទារ....................................៣៧

**ជំពូកទី៣**

**ភាគបម្រុង**

**ផ្នែកទី១៖ ការគណនាភាគបម្រុង និងការកាត់នៃភាគបម្រុង** ......................................៣៩

**កថាខណ្ឌទី១៖ ការគណនាភាគបម្រុង** ...........................................................៣៩

១.មូលដ្ឋាននៃភាគបម្រុង.............................................................................៣៩

២.ការគណនាភាគបម្រុង...............................................................................៤១

**កថាខ័ណ្ឌទី២៖ ការកាត់នៃភាគបម្រុង** ..........................................................៤២

១.ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង .........................៤២

២.ចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង.......................... ៤៣

**ផ្នែកទី២៖ នីតិវិធីនៃការកាត់បន្ថយ និងការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង**.....................................................................................................៤៥

**កថាខ័ណ្ឌទី១៖ នីតិវិធីនៃការកាត់បន្ថយ** .........................................................៤៥

១.ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ..............................................៤៥

២.លំដាប់នៃការកាត់បន្ថយ...........................................................................៤៥

៣.អានុភាពនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង .............................................៥២

**កថាខណ្ឌទី២៖ ការរលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង** ......... ៥៣

១.អាជ្ញាយុកាល .......................................................................................៥៣

២.ការបោះបង់ភាគបម្រុង ............................................................................ ៥៣

៣.សហាសន្តតិជននៃភាគបម្រុង.......................................................................៥៤

**សេចក្តីសន្និដ្ឋាន**.......................................................................................៥៥

**អនុសាសន៍**

**ឯកសារពិគ្រោះ និងឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ក្នុងសង្គមនាពេលបច្ចុប្បន្ន ការរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប បានខិតខំប្រឹងប្រែងធ្វើការ ប្រកបមុខរបររកស៊ីដើម្បីទ្រទ្រង់ជីវភាពនៃការរស់នៅប្រចាំថ្ងៃ ដោយបុគ្គលខ្លះ ការធ្វើការងារ ឬការប្រកបមុខរបររកស៊ីកាន់តែមានភាពរីកចម្រើន ក៏បានទិញនូវផ្ទះ ដី រថយន្តជាអាទិ៍ ប៉ុន្តែ បុគ្គលខ្លះ ក៏មានបំណុល ដោយសារមុខជំនួញក្ស័យធនជាអាទិ៍។ នៅពេលដែលមនុស្សម្នាក់បានស្លាប់បាត់បង់ជីវិតទៅ ដោយបានបន្សល់នូវទ្រព្យសម្បត្តិសម្រាប់ឲ្យបុគ្គលដែលមានសិទ្ធិស្នងនូវទ្រព្យសម្បត្តិទាំងអស់នោះ ប៉ុន្តែក្នុងករណីមានបុគ្គលដែលមានសិទ្ធិស្នងទ្រព្យច្រើននាក់ ឬការពិភាក្សាបែងចែកទ្រព្យមិនស្រុះស្រួលគ្នា ដែលជាហេតុធ្វើឲ្យមានបញ្ហាស្មុគស្មាញកើតឡើងចំពោះអ្នកមានសិទ្ធិទាំងអស់នោះ។ ដោយសារតែបញ្ហាទាំងនោះហើយ ទើបធ្វើឲ្យមានការបង្កើតនូវរបបសន្តតិកម្មនៅកម្ពុជា ដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ គន្ថីទី៨ ជារបបមួយសម្រាប់ការពារ និងដោះស្រាយនូវបញ្ហាទាំងនេះ។

សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនឲ្យទៅសន្តតិជនម្នាក់ ឬច្រើននាក់ តាមឆន្ទៈរបស់មតកជន ឬតាមច្បាប់ដែលមានភាគីម្ខាងជាសន្តតិជន ទទួលនូវមត៌កពីមតកជន ដែលជាអ្នកបន្សល់ទុកនូវមត៌ក ដោយរាប់បញ្ចូលទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម (បំណុល)។

សន្តតិកម្ម គឺជាគោលការណ៍នៃការគោរព និងការកំណត់អំពីព្រំដែននៃសិទ្ធិរបស់មតកជនក្នុងការផ្ទេរសិទ្ធិ និងករណីយកិច្ចឲ្យទៅសន្តតិជនដែលមានឆន្ទៈក្នុងការទទួល ដែលជននេះត្រូវបានច្បាប់ទទួលស្គាល់ និងការពារនូវសិទ្ធិសេរីភាព។

ដើម្បីជាការឆ្លើយតបទៅនឹងប្រធានបទខាងលើ ដូច្នេះ សន្តតិកម្មតាមមតកសាសន៍នឹងត្រូវលើកយកមកបកស្រាយ ដោយផ្អែកលើក្រមរដ្ឋប្បវេណីដែលកំពុងមានអានុភាព។

នៅលើសកលលោក របបសន្តតិកម្ម មានគោលការណ៍ចម្បងពីរប្រភេទ គឺគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ គឺសន្តតិជនត្រូវទទួលស្នងមត៌កតែម្តង ឬធ្វើការសងបំណុលជាមុនសិនមុននឹងធ្វើការបែងចែក។ ហើយម្យ៉ាងវិញទៀត សន្តតិជនមានសិទ្ធិទទួលយកទាំងស្រុង ឬទទួលយកដោយមានកម្រិត ឬបោះបង់សន្តតិកម្មតែម្តង។ មានស្ថានភាពមួយចំនួនទៀត ដែលមានសហសន្តតិជន និងមានជនដែលបានទទួលទ្រព្យ ដោយប្រទានកម្មជាដើម នៅពេលដែលមតកជននៅរស់ ហើយដើម្បីធ្វើឲ្យមានសមភាពជាក់ស្តែង ទាមទារឲ្យមានការសម្រួលចំណែកមត៌ក ក្នុងករណីមានអ្នកដែលបានទទួលផលប្រយោជន៍ពិសេស ជាអាទិ៍។ ចំណែក គោលការណ៍ជម្រះបញ្ជី គឺជាការជម្រះសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ហើយសន្តតិជនអាចស្នងមត៌កបាន ក្នុងករណីដែលមានបន្សល់ទ្រព្យសកម្មតែប៉ុណ្ណោះ និងមានករណីធ្ងន់ធ្ងរ ត្រូវប្រកាសក្ស័យធន ហើយនីតិវិធីនេះ

មានលក្ខណៈស្មុគស្មាញ ដោយចំណាយសោហ៊ុយច្រើន ហើយចាំបាច់ត្រូវការអ្នកច្បាប់ ព្រមទាំងចំណាយទាំងពេលវេលាច្រើន។ ដូច្នេះ ដោយសារតែបញ្ហាទាំងនេះហើយ ទើបធ្វើឲ្យក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលទាក់ទងនឹងសន្តតិកម្ម បានជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលមានការបំពានសិទ្ធិចំពោះបុគ្គលដែលមានសិទ្ធិជាសន្តតិជន នោះបញ្ហានេះ នឹងត្រូវបានយកមកបកស្រាយដែលទាក់ទងនឹងភាគបម្រុង។

# ជំពូកទី១

# មូលដ្ឋាននៃការបង្កើតមតកសាសន៍

# ជំពូកទី១
# មូលដ្ឋាននៃការបង្កើតមតកសាសន៍

មូលដ្ឋាននៃការបង្កើតមតកសាសន៍ គឺជាចំណុចសារវន្តនៅក្នុងការបកស្រាយនូវជំពូកទី១ ដែលជាផ្នែកមួយនៅក្នុងប្រធានបទស្តីពី "**សន្តតិកម្មតាមមតកសាសន៍**" ឬជាចរិកនៃមតកសាសន៍ ដែលឆ្លុះបញ្ចាំងអំពីចំណុចសំខាន់ៗនៅក្នុងមតកសាសន៍ ហេតុដូច្នេះ ចំពោះការបកស្រាយត្រូវបាន កំណត់ចំណុចនីមួយៗដូចជា៖ លក្ខណៈទូទៅនៃមតកសាសន៍ សមត្ថភាពនៃការធ្វើមតកសាសន៍ ទម្រង់នៃមតកសាសន៍ ខ្លឹមសារនៃមតកសាសន៍ ការលុបចោលនៃមតកសាសន៍ អានុភាពនៃមតក-សាសន៍ និងចំណុចផ្សេងៗទៀត។

## ផ្នែកទី១៖ លក្ខណៈទូទៅនៃមតកសាសន៍ និងសមត្ថភាពនៃការធ្វើមតកសាសន៍

### កថាខណ្ឌទី១៖ លក្ខណៈទូទៅនៃមតកសាសន៍

#### ១.ការធ្វើមតកសាសន៍ដោយឯកតោភាគី

មតកសាសន៍ គឺជាប្រភេទកិច្ចសន្យាមានលក្ខណៈឯកតោភាគីមួយ ដែលមតកជន ឬម្ចាស់បណ្តាំ អាចបង្កើតកិច្ចសន្យាបានដោយភាគីតែម្ខាង ពោលគឺម្ចាស់បណ្តាំ ដោយមិនចាំបាច់ត្រូវមាន ការយល់ព្រម ឬទទួលស្គាល់ពីសន្តតិជន ឬតតិយជនឡើយ។

#### ២.មតកសាសន៍ក្រោយមរណភាពរបស់មតកជន

នៅមុនពេលដែលមតកជនបានទទួលមរណភាព មតកជន មានសេរីភាពពេញលេញក្នុង ការធ្វើមតកសាសន៍ និងមានសិទ្ធិក្នុងការកែប្រែ ឬលុបចោលមតកសាសន៍ទៅតាមឆន្ទៈរបស់ខ្លួន នៅពេលណាក៏បាន ហើយមតកសាសន៍ដែលធ្វើការកែប្រែចុងក្រោយនឹងមានអានុភាពអនុវត្ត។ មតកសាសន៍ដែលធ្វើការកែប្រែចុងក្រោយនោះ ត្រូវកំណត់ទៅលើកាលបរិច្ឆេទដែលបានចុះចុង ក្រោយនោះ។ ដោយឡែក មតកសាសន៍នឹងមិនមានអានុភាពអនុវត្តឡើយ ប្រសិនបើម្ចាស់បណ្តាំ មិនទាន់ទទួលមរណភាព ដូច្នេះ សន្តតិកម្មត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន[1]។

#### ៣.មតកសាសន៍ដែលត្រូវបានកំណត់ដោយបញ្ញត្តិច្បាប់

សន្តតិកម្មតាមមតកសាសន៍ គឺជាការសម្តែងឆន្ទៈចុងក្រោយរបស់ម្ចាស់បណ្តាំនៅមុនពេល ដែលម្ចាស់បណ្តាំទទួលមរណភាព ដែលនេះ គឺជាសិទ្ធិសេរីភាពរបស់ម្ចាស់ណ្តាំ។ ប៉ុន្តែ បើទោះបី នេះជាសិទ្ធិរបស់ម្ចាស់បណ្តាំក៏ដោយ ក៏មតកសាសន៍នេះត្រូវបង្កើតឡើងដោយផ្អែកទៅតាមបញ្ញត្តិ ច្បាប់ដែលកំពុងមានអានុភាពជាកំហិត ដោយមិនត្រូវឲ្យផ្ទុយទៅនឹងបញ្ញត្តិស្តីពីភាគបម្រុងបាន ឡើយ។ ក្នុងករណី ប្រសិនបើមតកសាសន៍នេះ មិនគោរពតាមគោលការណ៍នៃច្បាប់ទេ នោះមតក សាសន៍នឹងទុកជាមោឃៈ ដោយមិនមានអានុភាពអនុវត្តតាំងពីដំបូង។

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៩៥ ១

### ៤.មតកសាសន៍ដែលកំណត់ដោយបុគ្គល

មតកសាសន៍ដែលកំណត់ដោយបុគ្គល គឺជាសិទ្ធិស្វ័យភាពរបស់ម្ចាស់បណ្តាំនៅក្នុងការសម្តែងឆន្ទៈនៅក្នុងមតកសាសន៍។ ដោយម្ចាស់បណ្តាំ អាចកំណត់អំពីបុគ្គលដែលមានសិទ្ធិក្នុងការទទួលបាននូវមតិក ការកំណត់អំពីទ្រព្យសម្បត្តិដែលជាកម្មវត្ថុសម្រាប់ការអនុវត្តន៍នៅក្នុងរបបនៃមតកសាសន៍ និងការកំណត់អំពីវិធីនៃការបែងចែក ជាអាទ៍។ ប៉ុន្តែ ទោះជាយ៉ាងណាក្តី ការកំណត់បែបនេះ មិនត្រូវឲ្យផ្ទុយទៅនឹងបញ្ញត្តិនៃច្បាប់បានឡើយ។

ដោយឡែក នៅក្នុងរបបនៃមតកសាសន៍ តើបុគ្គលណាខ្លះដែលមានសមត្ថភាពនៅក្នុងការធ្វើមតកសាសន៍ ដែលជាឆន្ទៈចុងក្រោយរបស់ខ្លួនបាន? ដូចនេះ បុគ្គលដែលមានសមត្ថភាពក្នុងការធ្វើមតកសាសន៍ នឹងត្រូវបកស្រាយនៅចំណុចបន្តបន្ទាប់ខាងក្រោមនេះ។

## កថាខណ្ឌទី២៖ សមត្ថភាពក្នុងការធ្វើមតកសាសន៍

### ១.បុគ្គលដែលមានសមត្ថភាព

ម្ចាស់បណ្តាំ គឺជាបុគ្គលដែលធ្វើមតកសាសន៍ ប៉ុន្តែ ម្ចាស់បណ្តាំត្រូវមានសមត្ថភាពនៅពេលធ្វើមតកសាសន៍។[2] នៅក្នុងករណីដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍ក្នុងស្ថានភាពបាត់បង់ស្មារតីដោយសារគ្រឿងស្រវឹង ចាស់វង្វេងស្មារតីជាអាទ៍ នោះមតកសាសន៍នឹងត្រូវចាត់ទុកជាមោឃៈ។ ម្យ៉ាងវិញទៀត ចំពោះបុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនេះ។ [3] ម្ចាស់បណ្តាំត្រូវមានស្មារតី ឬមានសមត្ថភាពក្នុងការគិតត្រិះរិះពិចារណាយ៉ាងត្រឹមត្រូវ ទើបអាចធ្វើការសន្និដ្ឋានបានថា មតកសាសន៍ធ្វើឡើងដោយឆន្ទៈរបស់ខ្លួនយ៉ាងពិតប្រាកដមែន។ បុគ្គលដែលមានសមត្ថភាពនេះ ត្រូវបានកំណត់ដោយច្បាប់ មានដូចជាបុគ្គលដែលជានីតិជន និងអនីតិជនដែលបានអត្តាធិនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា អាចធ្វើមតកសាសន៍បាន។[4]

### ២.ការតាក់តែងមតកសាសន៍

ជាគោលការណ៍ មតកសាសន៍ត្រូវបានធ្វើឡើងដោយម្ចាស់បណ្តាំផ្ទាល់ ហើយទាមទារឲ្យម្ចាស់បណ្តាំនោះមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការវិនិច្ឆ័យ យល់ដឹងអំពីភាពត្រឹមត្រូវ មានបញ្ញាស្មារតីគ្រប់គ្រាន់ ជារួមគឺមិនមែនជាមនុស្សដែលត្រូវបានច្បាប់កម្រិតសមត្ថភាពឡើយ។

ការតាក់តែងមតកសាសន៍ជាអាទ៍ គឺជារឿងមួយដ៏ចាំបាច់សម្រាប់ម្ចាស់បណ្តាំ ដែលមានបំណងចង់ធ្វើលិខិតបណ្តាំមតិក។ តាមរយៈក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦៩ ១

[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦៩ ២

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦៨ ១

បានកំណត់អំពីទម្រង់នៃការតាក់តែងមតកសាសន៍ សម្រាប់ម្ចាស់បណ្ដាំដែលចង់ធ្វើតាមទម្រង់មួយណាក៏បាន។ ទម្រង់នៃមតកសាសន៍ ត្រូវបានកំណត់ជា២ ធំៗ គឺទម្រង់នៃមតកសាសន៍ធម្មតា និង មតកសាសន៍ក្នុងករណីពិសេស ដែលនឹងធ្វើការបកស្រាយនៅក្នុងកថាខណ្ឌទី១ ស្ដីពី "**ទម្រង់នៃមតកសាសន៍**" នៃផ្នែកទី២ និងចំណុចបន្តបន្ទាប់ដូចខាងក្រោម។

## ផ្នែកទី២៖ ទម្រង់ និងខ្លឹមសារនៃមតកសាសន៍

### កថាខណ្ឌទី១៖ ទម្រង់នៃមតកសាសន៍

ទម្រង់នៃលិខិតមតកសាសន៍ គឺជាការចាំបាច់មួយនៅក្នុងរបបសន្តតិកម្ម ដែលម្ចាស់បណ្ដាំត្រូវធ្វើលិខិតបណ្ដាំមតិកឲ្យបានត្រឹមត្រូវទៅតាមទម្រង់លិខិត ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។ ជាការពិតណាស់ មតកសសាន៍ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីដែលកំពុងនៅជាធរមាននេះ។[5] ក្នុងករណីមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះមិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្ដាំដូចគ្នា។ ហើយនៅក្នុងករណីដែលមតកសាសន៍គ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយមតកសាសន៍ទាំងនោះផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក។[6] បានសេចក្ដីថា ចំពោះចំណុចនីមួយៗដែលមានអត្ថន័យដូចគ្នា ឬផ្ទុយគ្នា នោះមតកសាសន៍នឹងស៊ីសងគ្នាទៅវិញទៅមក កាត់កងគ្នាទៅវិញទៅមកដើម្បីបង្រួប់អត្ថន័យរវាងមតកសាសន៍មួយចំពោះមតកសាសន៍មួយផ្សេងទៀត។

#### ១.បុគ្គលដែលមិនមានលក្ខណៈសម្បត្តិជាសាក្សី

សាក្សី គឺជាបុគ្គលដែលជួយសម្រួលដល់មតកសាសន៍ឲ្យកាន់តែរឹងមាំ និងមានសុពលភាពតាមនីតិវិធីដែលច្បាប់បានកំណត់។ នៅក្នុងក្រមរដ្ឋប្បវេណី បានកំណត់បុគ្គលមួយចំនួនដែលមិនមានលក្ខណៈសម្បត្តិជាសាក្សីសម្រាប់របបនៃមតកសាន៍នេះ។ អនីតិជន ជននៅក្រោមអាណាព្យាបាលធម្មតា ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី សហព័ទ្ធ ញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្ដាំ ជាអាទ៏។ នៅក្នុងករណីដែលសារការីជាអ្នកធ្វើមតកសាសន៍ សហព័ទ្ធ ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី ព្រមទាំងនិយោជិតរបស់សារការី មិនអាចក្លាយជាសាក្សីបានឡើយ។[7]

---

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧០ ១

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧០ ២

[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧២

## ២.ទម្រង់នៃមតកសាសន៍ក្នុងករណីធម្មតា

### ២.១.ទម្រង់នៃមតកសាសន៍ដោយលិខិតយថាភូត

ទម្រង់នៃមតកសាសន៍ដោយលិខិតយថាភូត គឺជាទម្រង់ដែលធ្វើឡើងដោយសារការី។ សារការី គឺជាអ្នកទទួលបន្ទុកក្នុងការតាក់តែង ព្រមទាំងថែរក្សាលិខិតមតកសាសន៍នោះ។ ទម្រង់នៃមតកសាសន៍ ត្រូវគោរពតាមលក្ខខណ្ឌដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ទើបធ្វើឲ្យទម្រង់នេះមានសុពលភាពគតិយុត្ត។ ហើយទម្រង់នេះត្រូវបានកំណត់ដូចខាងក្រោយះ

- ✓ ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី
- ✓ ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច២ នាក់
- ✓ ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី
- ✓ សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់។
- ✓ បន្ទាប់ពីម្ចាស់បណ្តាំស្តាប់ និងសាក្សីបានទទួលស្គាល់ថា ការកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗត្រូវធ្វើឲ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬមិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង។[8]
- ✓ សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា។

### ២.២.ទម្រង់នៃមតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ គឺជាទម្រង់មួយដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី នាពេលបច្ចុប្បន្ន។ លិខិតមតកសាសន៍នេះ មានលក្ខណៈខុសពីលិខិតមតកសាសន៍ដោយលិខិតយថាភូត ដោយមតកសាសន៍ដោយលិខិតសម្ងាត់ ម្ចាស់បណ្តាំ អាចសរសេរដោយខ្លួនឯង ឬមានអ្នកសរសេរជំនួស ឬអាចប្រើម៉ាស៊ីនសម្រាប់វាយអត្ថបទ ជាអាទិ៍។

មតកសាសន៍ដោយលិខិតសម្ងាត់ត្រូវបានកំណត់ដូចខាងក្រោមះ

.ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៣

.ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬសរសេរសញ្ញាសំគាល់ ឬមធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬមិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ។

.ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សី២នាក់ ព្រមទាំងធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនណាក្រៅពីសាមីខ្លួនបានសេសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ នៅលើលិខិតដែលបានបិទជិតនោះ។ ម្យ៉ាងវិញទៀត សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំនៅលើលិខិតដែលបានបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និងម្ចាស់បណ្តាំ។[9]

## ២.៣.មតកសាសន៍ដោយលិខិតឯកជន

មតកសាសន៍ដោយលិខិតឯកជន គឺជាលិខិតមួយដែលស្ថិតក្នុងចំណោមទម្រង់មតសាសន៍ធម្មតាខាងលើដែរ ប៉ុន្តែលក្ខខណ្ឌនៃលិខិតនេះ ខុសពីលិខិតទាំងពីរដូចដែលបានបកស្រាយខាងលើ។ ម្ចាស់បណ្តាំ គឺជាអ្នកធ្វើលិខិតនេះដោយផ្ទាល់ខ្លួនឯង ហើយម្ចាស់បណ្តាំត្រូវសរសេរពាក្យពេចន៍ ឃ្លោងឃ្លាទាំងអស់ ព្រមទាំងចុះថ្ងៃខែឆ្នាំ និងហត្ថលេខាលើលិខិតនោះដោយខ្លួនឯង។ នៅក្នុងករណីដែលមតកសាសន៍ដោយលិខិតឯកជននេះ ត្រូវបានសរសេរដោយអ្នកផ្សេង ក្រៅពីសាមីខ្លួន ឬដោយប្រើឧបករណ៍បច្ចេកវិទ្យា ដូចជាកុំព្យូទ័រជាអាទិ៍ លិខិតនេះនឹងត្រូវចាត់ទុកជាមោឃៈ។

ម្យ៉ាងវិញទៀត ក្នុងករណីមានការសង្ស័យអំពីភាពមិនពិតប្រាកដនៃលិខិតមតកសាសន៍របស់ម្ចាស់បណ្តាំដោយសន្តតិជន ឬបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ។ ក្នុងករណីនេះ អ្នកដែលមានសិទ្ធិក្នុងការអនុវត្តន៍នៃលិខិត ព្រមទាំងបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ អាចធ្វើការផ្ទៀងផ្ទាត់ចំពោះអក្សរដែលបានសរសេរនៅក្នុងលិខិតមតកសាសន៍ ជាមួយនឹងអក្សរដែលម្ចាស់បណ្តាំបានសរសេរនៅក្នុងអត្ថបទផ្សេងទៀត ដើម្បីបញ្ជាក់អំពីភាពពិត ឬមិនពិតប្រាកដនៃលិខិតមតកសាសន៍នោះ។

នៅក្នុងករណីមានការបន្ថែមពាក្យពេចន៍ ការលុប ឬការកែប្រែផ្សេងៗទៀតនៅក្នុងមតក-សាសន៍លិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនៅកន្លែង ហើយសរ-សេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ។[10] ចំពោះការទាមទារ

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៥

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៤

ឲ្យមានការបញ្ជាក់ឲ្យបានច្បាស់បែបនេះ គឺដើម្បីការពារ ក្នុងករណីដែលមានជនទុច្ចរិត បានធ្វើការផ្លាស់ប្តូរ ឬក្លែងបន្លំតាមរយៈការសរសេរបន្ថែម ឬកែប្រែពាក្យពេចន៍ឃ្លោងឃ្លាផ្សេងនៅក្នុងមតកសាសន៍នោះ។ ដូច្នេះ ដើម្បីការពារនូវបញ្ហាទាំងអស់នោះ ក្នុងករណីដែលម្ចាស់បណ្តាំចង់កែប្រែ ឬលុបពាក្យពេចន៍ខ្លះៗជាអាទិ៍។ ម្ចាស់បណ្តាំត្រូវសរសេរបញ្ជាក់អំពីការផ្លាស់ប្តូរនោះ ហើយចាំបាច់ត្រូវចុះហត្ថលេខាផងដែរ ដើម្បីកំណត់ឲ្យបានច្បាស់លាស់ពីការ កែប្រែ ផ្លាស់ប្តូរ លុប ឬបន្ថែមពាក្យពេចន៍ដែលបានធ្វើឡើងដោយម្ចាស់បណ្តាំយ៉ាងពិតប្រាកដ។[11]

### ៣.មតកសាសន៍ក្នុងករណីពិសេស

មតកសាសន៍ក្នុងករណីពិសេស គឺជាផ្នែកមួយនៃទម្រង់មតកសាសន៍ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។ មតកសាសន៍ក្នុងករណីពិសេសនេះ មានអានុភាពដូចនឹងមតកសាសន៍ដែលបានបកស្រាយខាងលើដែរ។ ប៉ុន្តែមតកសាសន៍ក្នុងករណីពិសេសនេះ ជាទម្រង់មួយបង្កើតឡើងសម្រាប់ម្ចាស់បណ្តាំដែលជាជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ជនកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ជនដែលត្រូវបានជាប់ឃុំឃាំង ឬជនដែលស្ថិតក្នុងនាវា ឬយន្តហោះ ជនដែលមិនអាចនិយាយបាន និងជនដែលមានសញ្ជាតិខ្មែររស់នៅបរទេស ជាអាទិ៍។ ដែលនេះ គឺជាគោលបំណងនៃមតកសាសន៍ក្នុងករណីពិសេស។ ដូច្នេះ មតកសាសន៍ពិសេសនេះ នឹងធ្វើការបកស្រាយដូចខាងក្រោម៖

#### ៣.១.មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

បុគ្គលដែលមានសមត្ថភាពក្នុងការធ្វើមតកសាសន៍ ទើបអាចធ្វើបានដូចអ្វីដែលបានបង្ហាញខាងលើ។ ដោយឡែក សម្រាប់ជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ ក៏អាចធ្វើមតកសាសន៍បានផងដែរ ប៉ុន្តែជននេះ ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដែលបានកំណត់ដោយច្បាប់។

ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅបានសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ហើយត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច២ នាក់។[12] នៅពេលដែលជននោះសរសេរមតកសាសន៍ដោយផ្ទាល់ ឬនាពេលដែលជននោះបង្ហាញខ្លឹមសារនៃមតកសាសន៍ទៅឲ្យសារការី។ ក្នុងករណី ប្រសិនបើជននេះធ្វើមតកសាសន៍ដោយលិខិតយថាភូត ត្រូវតែមានវត្តមានសាក្សីផ្សេងទៀតក្រៅពីវេជ្ជបណ្ឌិតដែលបានបង្ហាញខាងលើផងដែរ។

---

[11] ម៉ៃ ច័ន្ទតារាវុធ និងហួ ឡេងហុង, *សារណាបញ្ចប់ការសិក្សា៖ សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជាបច្ចុប្បន្ន* (ភ្នំពេញ, ២០១៤), ១៤

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៦ ១

វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍ ម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិស្មារតីនោះទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ។[13] ការបកស្រាយលម្អិតនឹងមាននៅក្នុងចំណុច "**ការតម្រិតន្ធូវមតកសាសន៍ចំពោះអ្នកអាណាព្យាបាល**" ខាងក្រោម។

### ៣.២.មតកសាសន៍នៃជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

ចំពោះជនដែលកំពុងជួបប្រទះនូវគ្រោះថ្នាក់បន្ទាន់ ដែលបណ្តាលឲ្យប៉ះពាល់ដល់អាយុជីវិតអាចសម្រេចបំណងរបស់ខ្លួនបានដែលទាក់ទងទៅនឹងសន្តតិកម្ម។ ក្នុងករណីដែលជននេះមានសមត្ថភាព អាចធ្វើមតកសាសន៍ដោយលិខិតឯកជនបាន ហើយប្រសិនបើមានពេលវេលាគ្រប់គ្រាន់ដែលអាចមានសារការី ជននេះអាចធ្វើមតកសាសន៍ដោយលិខិតយថាភូតបាននៅចំពោះមុខសារការី។ ក្នុងករណីម្យ៉ាងវិញទៀត បើគ្មានសមត្ថភាព ឬពេលវេលាគ្រប់គ្រាន់ ជននេះអាចធ្វើមតកសាសន៍ដោយប្រាប់ផ្ទាល់មាត់បាន នៅចំពោះមុខបុគ្គលដែលមានវត្តមាននៅទីនោះ ហើយលក្ខខណ្ឌលម្អិតនឹងមានបកស្រាយដូចខាងក្រោម។

ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឲ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ នាក់ ហើយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់នៅចំពោះជនម្នាក់ក្នុងចំណោមសាក្សីនោះ។ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះត្រូវសរសេរខ្លឹមសារនោះជាលាយល័ក្ខណ៍អក្សរ ហើយអានឲ្យសាក្សីស្តាប់ ឬឲ្យសាក្សីពិនិត្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថា ការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវចុះហត្ថលេខាលើលិខិតនោះ។

មតកសាសន៍ដែលបានបកស្រាយខាងលើ នឹងមិនមានអានុភាពឡើយ ប្រសិនបើសាក្សីណាម្នាក់ ឬបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ ដោយគិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍ ហើយបើពុំបានទទួលការបញ្ជាក់ទេនោះ។ តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។

---

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៦ ២

### ៣.៣.មតកសាសន៍នៃជនដែលកំពុងជាប់ឃុំឃាំង

ចំពោះជនដែលត្រូវជាប់ឃុំឃាំង អាចធ្វើមតកសាសន៍បាន ដោយវិធីដូចគ្នានឹងការធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬដោយលិខិតឯកជនបាន។ ប៉ុន្តែ នៅក្នុងករណីខ្លះដែលមិនអាចធ្វើមតកសាសន៍ដោយលិខិតឯកជនបាន ដោយសារជននេះជាអនក្ខរជន ឬហេតុផ្សេងទៀត ជាហេតុត្រូវអនុវត្តដូចខាងក្រោមនេះ។[14]

បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬសាលដីកា ឬដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវមានវត្តមានរបស់នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំង និងសាក្សីយ៉ាងតិច ២ នាក់។[15] ហើយលក្ខខណ្ឌបន្ថែមនឹងមានបកស្រាយដូចខាងក្រោម។

### ៣.៤.មតកសាសន៍នៃជនដែលកំពុងនៅក្នុងយន្តហោះ ឬនាវា

ជនដែលកំពុងនៅលើយន្តហោះ ឬនាវាដែលកំពុងតែនឹងជួបគ្រោះថ្នាក់ដែលមិនអាចសន្និដ្ឋានបានថាអាចនៅមានជីវិតរស់នៅបន្ត ឬយ៉ាងណាដោយសារតែហេតុការណ៍ដែលហៀបនឹងកើតឡើងនោះ ឬដោយហេតុផលផ្សេងទៀតជាអាទិ៍។ តាមការកំណត់របស់ច្បាប់ ជនដែលកំពុងស្ថិតនៅក្នុងស្ថានភាពបែបនេះ អាចធ្វើមតកសាសន៍បានដោយលិខិតយថាភូត ឬដោយលិខិតឯកជន ហើយលក្ខខណ្ឌនៃការធ្វើមតកសាសន៍បែបនេះ នឹងបកស្រាយដូចខាងក្រោមៈ

បុគ្គលដែលនៅក្នុងនាវា ឬយន្តហោះអាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឲ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះម្នាក់ និងសាក្សីយ៉ាងតិច ២ នាក់។[16]

**កំណត់សំគាល់ៈ** នៅក្នុងចំណុចមតកសាសន៍នៃជនដែលកំពុងជាប់ឃុំឃាំង និងមតកសាសន៍នៃជនដែលកំពុងនៅលើយន្តហោះ និងនាវាដែលបានបកស្រាយខាងលើ គឺនៅមិនទាន់បំពេញលក្ខខណ្ឌគ្រប់គ្រាន់នៅឡើយទេ។ ដែលលក្ខខណ្ឌបន្ថែមនឹងបកស្រាយដូចខាងក្រោមៈ

នៅពេលធ្វើមតកសាសន៍ ចំពោះជនដែលកំពុងជាប់ឃុំឃាំង ជនដែលកំពុងនៅលើយន្តហោះ និងជនដែលកំពុងនៅលើនាវា ជនទាំងនេះអាចធ្វើមតកសាសន៍ដោយផ្ទាល់មាត់បាននៅ

[14] ម៉ៃ ច័ន្ទតារាវុធ និងហូ ឡេងហុង, *សារណាបញ្ចប់ការសិក្សាៈ សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជាបច្ចុប្បន្ន* (ភ្នំពេញ, ២០១៥), ១៨

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៨ ១

[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៨ ២

ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះបាន។[17] ដោយជនដែលបានកំណត់ទាំងនេះ ត្រូវអនុវត្តមុខងារជាសារការី។

មតកសាសន៍ដែលបានធ្វើឡើងដូចដែលបានបកស្រាយខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ក្នុងអំឡុងពេល ៦ ខែ ដោយគិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បានធ្វើមតកសាសន៍តាមទម្រង់ណាមួយដែលបានកំណត់ដោយបញ្ញត្តិច្បាប់ ដោយទម្រង់នៃលិខិតយថាភូត លិខិតឯកជន និងលិខិតសម្ងាត់ ក្រោយពេលបុគ្គលនោះត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬចុះពីនាវា ឬយន្តហោះ។[18]

## ៣.៥.មតកសាសន៍នៃជនដែលមិនអាចនិយាយបាន

ចំពោះបុគ្គលដែលមិនអាចនិយាយបាន ច្បាប់បានអនុញ្ញាតឲ្យបុគ្គលទាំងនេះ អាចធ្វើមតក-សាសន៍បាន។ វាជាភាពងាយស្រួលមួយចំពោះជនដែលមិនអាចនិយាយបាន មានបំណងចង់បង្ហាញឆន្ទៈដែលទាក់ទង់ទៅនឹងការផ្ទេរសិទ្ធិ និងករណីយកិច្ច អាចធ្វើមតកសាសន៍បាន ដែលនេះជាការបង្ហាញអំពីស្មារតីនៃច្បាប់ចំពោះបុគ្គលទាំងនោះ។

នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងច្បាប់ មតកសាសន៍ដោយលិខិតយថាភូត លិខិតសម្ងាត់ និងមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ម្ចាស់បណ្តាំអាចជំនួសការប្រាប់បានដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬសេចក្តីថ្លែងការណ៍ថា លិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬសាក្សី។[19]

ក្នុងករណីដែលសារការី ឬបុគ្គលផ្សេងទៀតដែលបានកំណត់ ត្រូវអានឲ្យម្ចាស់បណ្តាំ ឬសាក្សីស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលដែលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និងសាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬបុគ្គលដែលត្រូវបានកំណត់ អាចជំនួសការអានឲ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬសាក្សី។ នៅក្នុងករណីដែលបានបកស្រាយខាងលើនេះ សារការី ឬបុគ្គលផ្សេងទៀតដែលបានកំណត់ ត្រូវសរសេរអំពីហេតុចូលទៅក្នុងលិខិតនោះ។[20]

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៨ ៣
[18] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៨ ៥
[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៩ ១
[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧៩ ២

### ៣.៦.មតកសាសន៍នៃជនជាតិខ្មែរដែលរស់នៅបរទេស

នៅក្នុងករណីជនជាតិខ្មែរដែលរស់នៅបរទេស មានបំណង់ចង់ធ្វើមតកសាសន៍ ជនជាតិខ្មែរដែលរស់នៅបរទេសនោះ អាចធ្វើមតកសាសន៍បានដោយលិខិតយថាភូត ឬលិខិតសម្ងាត់។ ការធ្វើមតកសាសន៍ដូចដែលបានបកស្រាយខាងលើនេះ ជនជាតិខ្មែរដែលរស់នៅបរទេស អាចធ្វើមតកសាសន៍បាន នៅកន្លែងដែលមានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាដែលប្រចាំនៅលើទឹកដីនៃប្រទេសដែលបុគ្គលនោះកំពុងរស់នៅ។ កុងស៊ុលដែលប្រចាំនៅប្រទេសដែលជនជាតិខ្មែរធ្វើមតកសាសន៍នោះ ត្រូវអនុវត្តមុខនាទីរបស់សារការី។

## កថាខណ្ឌទី២៖ ខ្លឹមសារនៃមតកសាសន៍

### ១.ការផ្តាច់មត៌កពីជនដែលសន្មតថាជាសន្តតិជន

បុគ្គលដែលបានសន្មតថាជាសន្តតិជននឹងត្រូវក្លាយទៅជាសន្តតិជន ដែលមានសិទ្ធិក្នុងការទទួលនូវចំណែកមត៌ក។ សម្រាប់សន្តតិកម្មតាមមតកសាសន៍ ម្ចាស់បណ្តាំ អាចបង្ហាញឆន្ទៈតាមរយៈលិខិតមតកសាសន៍របស់ខ្លួន ក្នុងការកំណត់បុគ្គលដែលនឹងទទួលបានទ្រព្យ ទោះបីជាបុគ្គលនោះ មិនមែនជាជនដែលត្រូវបានកំណត់នៅក្នុងច្បាប់ថា ជាជនដែលមានសិទ្ធិក្លាយជា សន្តតិជនក៏ដោយ។ តែទោះជាយ៉ាងនេះក្តី ការកំណត់ចំពោះបុគ្គលដែលនឹងត្រូវក្លាយជាសន្តតិជនតាមរយៈឆន្ទៈរបស់ម្ចាស់បណ្តាំ គឺមិនត្រូវឲ្យផ្ទុយពីបញ្ញត្តិស្តីពីភាគបម្រុងឡើយ។ បញ្ញត្តិស្តីពីភាគបម្រុង នឹងធ្វើការសិក្សានៅក្នុងជំពូកទី៣ ស្តីពី "**ភាគបម្រុង**" នឹងចំណុចបន្តបន្ទាប់។

ទោះបីជាបុគ្គល ដែលត្រូវបានសន្មតថាជាសន្តតិជនក៏ដោយ បុគ្គលនេះអាចនឹងត្រូវក្លាយជាជនដែលត្រូវបានផ្តាច់មត៌កបានផងដែរ នៅក្នុងករណីដែលមានមូលហេតុផ្សេងៗ តាមរយៈការបង្ហាញឆន្ទៈរបស់មតកជន ក្នុងករណីដូចដែលបានបកស្រាយខាងក្រោម៖

#### (ក).ការផ្តាច់តាមរយៈខ្លឹមសារនៃមតកសាសន៍

មតកជនអាចបង្ហាញឆន្ទៈរបស់ខ្លួននៅក្នុងខ្លឹមសារនៃមតកសាសន៍ ចំពោះការផ្តាច់មត៌កពីសន្តតិជនម្នាក់ ឬច្រើននាក់បាន ហើយចាំបាច់ត្រូវតែបញ្ជាក់អំពីមូលហេតុនៃការផ្តាច់នោះឲ្យច្បាស់លាស់ និងត្រឹមត្រូវ។

#### (ខ).ការផ្តាច់តាមរយៈការដាក់ពាក្យសុំទៅតុលាការ

មតកជនកាលនៅរស់អាចដាក់ពាក្យសុំទៅតុលាការ ឲ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះដោយមិនឲ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ

បុគ្គលដែលបានធ្វើបាបចំពោះមតកជន បានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដែលអាចមកមើលថែមតកជនបាន នៅពេលមតកជនមានជម្ងឺ តែមិនមកមើលថៃ ចំពោះបុគ្គលដែលត្រូវ

បានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឲ្យជាប់ពន្ធនាគារមួយជីវិត និងបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឲ្យកត់សំគាល់ជាអាទិ៍។[21]

យ៉ាងណាមិញ ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្តាច់មតិកដូចដែលបានបកស្រាយក្នុងចំណុច (ក) និង(ខ) ខាងលើ អាចធ្វើវិវាទអំពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការផ្តាច់មតិកនេះ ដូចដែលបានបកស្រាយខាងលើ។ ហើយមតកជនក៏អាចស្នើរសុំទៅតុលាការ ឲ្យលុបចោលអំពីការផ្តាច់មតិកចំពោះសន្តតិជនរបស់ខ្លួនវិញនៅពេលណាក៏បាន។

### ២.ការកំណត់ចំណែកមត៌ក

មតកជនអាចកំណត់ចំណែកមតិក របស់សហសន្តតិជនតាមមតកសាសន៍ ឬអាចបង្ហាញឆន្ទៈផ្ទុយពីបញ្ញត្តិ ស្តីពីចំណែកមតិករបស់បុគ្គលដែលទទួលផលប្រយោជន៍ពិសេសបាន។ ប៉ុន្តែការកំណត់ចំណែកមតិកដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង។[22]

បើមតកជនបានកំណត់ចំណែកមតិក ចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិស្តីពីការសម្រួលចំណែកមតិក។[23]

មតកជនអាចកំណត់នូវចំណែកមតិកបានតាមរយៈខ្លឹមសារក្នុងមតកសាសន៍។ ឧទាហរណ៍ក្នុងករណីជនដែលត្រូវបានសន្មតថាជាសន្តតិជន គឺជាសហព័ទ្ធ និងកូនពីរនាក់ គឺចំណែកមតិកតាមផ្លូវច្បាប់ ១ ភាគ ៣ នៃជនដែលត្រូវបានសន្មតថាជាសន្តតិជន។ ប៉ុន្តែ មតកជនអាចកំណត់ឲ្យនរណាម្នាក់ ក្នុងចំណោមអ្នកទាំងនោះទទួលចំណែក ១ ភាគ ២ ក៏បាន។ ចំណែកមតិករបស់សន្តតិជនដែលកំណត់ដោយមតកជននេះ ហៅថាចំណែកមតិកតាមការកំណត់។ ម្យ៉ាងវិញទៀត មតក-ជនអាចបង្ហាញឆន្ទៈបានផ្សេងពីបញ្ញត្តិនៃមាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណី ដែលចែងអំពីចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស។

**កំណត់សំគាល់៖**

(ក).ផលប្រយោជន៍ពិសេស គឺជាស្ថានភាពណាមួយដែលបុគ្គលនោះបានទទួលទ្រព្យសម្បត្តិពីម្ចាស់បណ្តាំ តាមរយៈប្រទានកម្ម អច្ច័យទាន (អច្ច័យទានពុំអាចយកមកពិចារណា ដើម្បីគណនាបានឡើយ ប្រសិនបើមិនទាន់បានធ្វើការបែងចែកនៅពេលដែលសន្តតិកម្មត្រូវបានចាប់ផ្តើម) និងការធ្វើអំណោយដែលនៅក្នុងឱកាសនៃការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន ឬក្នុងហេតុការផ្សេងទៀត ដើម្បីសម្រួលមុខជំនួញ ឬជីវភាពរស់នៅប្រចាំថ្ងៃ។

---

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥១

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៨២ ១

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៨២ ២

(ខ).ការសម្រួលចំណែកមតិក គឺជាការធ្វើឲ្យមានសមភាពចំពោះចំណែកមតិករបស់សន្តតិជនម្នាក់ៗ ដែលជាគោលការណ៍ សន្តតិជនម្នាក់ៗត្រូវទទួលបានចំណែកមតិកស្មើៗគ្នា។ ហើយការសម្រួលចំណែកមតិកនេះ នឹងត្រូវលើកយកមកពិចារណា នៅក្នុងករណីដែលមានបុគ្គលណា បានទទួលនូវផលប្រយោជន៍ពិសេស។

(គ).ប្រទានកម្ម គឺជាកិច្ចសន្យាមួយ ដែលត្រូវមានអានុភាពដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនគិតថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល បានន័យថារវាងម្ចាស់អំណោយ និងអ្នកដែលទទួលអំណោយធ្វើនៅពេលមានជីវិត។

(ឃ).អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍ ហើយមានអានុភាពនៅពេលដែលចាប់ផ្តើមសន្តតិកម្ម។

### ៣.ការកំណត់នូវវិធីបែងចែកមត៌ក

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬអាចប្រគល់អាណត្តិឲ្យតតិយជនកំណត់វិធីនោះ។[24]

#### ៣.១.ការកំណត់ដោយមតកជន

មតកជនអាចបង្ហាញឆន្ទៈរបស់ខ្លួននៅក្នុងខ្លឹមសារនៃមតកសាសន៍ ដោយកំណត់ឲ្យសន្តតិជន (ក) ស្នងក្រុមហ៊ុន រីឯ (ខ) ទទួលបានដី និង(គ) ទទួលស្នងទ្រព្យសម្បត្តិនៅក្នុងធនាគារ។ ម្យ៉ាងវិញទៀត មតកជនអាចបង្ហាញឆន្ទៈក្រៅពីនេះបាន ដោយអាចកំណត់វិធីបែងចែកដោយគិតទៅតាមភាគនៃមតិកទាំងអស់ ឬមួយផ្នែកចំពោះសន្តតិជនម្នាក់ ឬច្រើននាក់។

#### ៣.២.មតកជនប្រគល់អាណត្តិឲ្យតតិយជនជាអ្នកកំណត់វិធីបែងចែក

ក្នុងករណីដែលមតកជន មិនអាចកំណត់វិធីបែងចែកមតិកបាន ឬពិបាកក្នុងការកំណត់ពីវិធីបែងចែក មតកជនអាចបង្ហាញឆន្ទៈនៅក្នុងមតកសាសន៍បាន ដើម្បីប្រគល់អាណត្តិឲ្យទៅតតិយជនជាអ្នកកំណត់អំពីវិធីបែងចែក ចំពោះមតិកដែលត្រូវប្រគល់ឲ្យទៅសន្តតិជនបាន។ ដូច្នេះ បុគ្គលដែលត្រូវបានប្រគល់អាណត្តិដោយមតកជន ជាអ្នកកំណត់វិធីបែងចែក ត្រូវអនុវត្តឲ្យបានត្រឹមត្រូវទៅតាមការបង្ហាញឆន្ទៈរបស់មតកជននៅក្នុងមតកសាសន៍។ ចំណុចនេះ នឹងត្រូវបកស្រាយនៅបន្តបន្ទាប់ទៀត។

#### ៣.៣.ការកំណត់នូវវិធីបែងចែកមត៌កដោយការធ្វើអនុប្បទាន

មតកជនអាចធ្វើអនុប្បទាននូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែក ឬធ្វើប្រទានកម្ម ឬអច្ច័យទានតាមមតកសាសន៍ ឲ្យទៅជនដែលត្រូវបានសន្មតថាជាសន្តតិជន ឬតតិយជនបានផងដែរ។ ម្យ៉ាងវិញទៀត បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទាននូវទ្រព្យ

---

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៨៣

សម្បត្តិជាក់លាក់តែមួយ ឬច្រើនឲ្យទៅសហសន្តតិជនតែម្នាក់ ឬច្រើននាក់ មតកសាសន៍នោះត្រូវបានសន្មតថាជាការកំណត់នូវវិធីនៃការបែងចែកមតិក។ លើកលែងតែមតកសាសន៍នោះ មានអត្ថន័យជាអច្ច័យទានច្បាស់លាស់ ដូចជា អច្ច័យទានភ្ជាប់បន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យនោះមានចំនួនលើសចំណែកមតិករបស់សហសន្តតិជន គឺត្រូវចាត់ទុកថាបានកំណត់នូវចំណែកមតិកផងដែរ។ លើសពីនេះទៅទៀត បើមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យតែមួយភាគនៅក្នុងចំណោមមតិក បើតម្លៃនៃទ្រព្យនោះ មានចំនួនតិចជាងចំណែកមតិកដែលសន្តតិជននោះត្រូវទទួលខុសត្រូវ លុះត្រាតែពុំមានការកំណត់ផ្សេងនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថា កំណត់វិធីបែងចែកមតិកដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ។[25]

### ៤.ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ដោយខ្លឹមសារនៃមតកសាសន៍

នៅក្នុងខ្លឹមសារនៃមតកសាសន៍ ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬច្រើននាក់ ឬអាចប្រគល់អាណត្តិឲ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះតាមមតកសាសន៍បាន។[26] ក្នុងករណីដែលកូនមិនទាន់គ្រប់អាយុជានីតិជន អាចធ្វើទៅបានចំពោះការប្រគល់អាណត្តិឲ្យឪពុកមារបស់សន្តតិជនធ្វើការកំណត់បែងចែកមតិក។ ប៉ុន្តែ ការប្រគល់អាណត្តិឲ្យទៅសន្តតិជនមិនបានត្រូវបានអនុញ្ញាតឡើយ។ ការកំណត់អ្នកប្រតិបត្តិមតកសាសន៍នេះ នឹងបកស្រាយនៅជំពូកទី២ ស្តីពី "**ការប្រតិបត្តិមតកសាសន៍**" និងចំណុចបន្តបន្ទាប់។

### ៥.ករណីមតកជនហាមឃាត់មិនឲ្យបែងចែកក្នុងរយៈពេលកំណត់

ករណីមតកជនហាមឃាត់មិនឲ្យបែងចែកក្នុងរយៈពេលកំណត់ នេះគឺជាឆន្ទៈរបស់ម្ចាស់ទ្រព្យ ដែលហាមឃាត់ចំពោះការបែងចែកមតិក នៅក្នុងអំឡុងពេលដែលកំណត់មួយ។ តាមរយៈក្រមរដ្ឋប្បវេណី មតកជនអាចហាមឃាត់មិនឲ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្មនោះបាន។[27]

សម្រាប់ការបកស្រាយនៅក្នុងផ្នែកទី១ និងផ្នែកទី២ ខាងលើ គឺមិនទាន់មានភាពទូលំទូលាយ គ្រប់គ្រាន់ដែលមានអត្ថន័យពេញលេញនៅក្នុងជំពូកទី១ ស្តីពី "**មូលដ្ឋាននៃការបង្កើតមតកសាសន៍**" ដូច្នេះ ដើម្បីឲ្យការបកស្រាយនៅក្នុងជំពូកទី១ កាន់តែមានភាពច្បាស់លាស់បន្ថែមទៀតនោះ គួរគប្បីត្រូវធ្វើការសិក្សាបន្ថែមទៀតនៅក្នុងផ្នែកទី៣ ស្តីពី "**ការលុបចោលមតកសាសន៍ និង អានុភាពនៃមតកសាសន៍**" ខាងក្រោមនេះ។

---

[25] មេធាវី អ៊ីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ១៨

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៨៦

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៨៣

## ផ្នែកទី៣៖ ការលុបចោលមតកសាសន៍ និង អានុភាពនៃមតកសាសន៍

### កថាខណ្ឌទី១៖ ការលុបចោលមតកសាសន៍

ការបង្កើតមតកសាសន៍ គឺជាឆន្ទៈរបស់មតកជន ដើម្បីជាគោលបំណងចុងក្រោយរបស់ខ្លួន ហើយសម្រាប់ការបង្កើតមតកសាសន៍នេះទៀតសោធ គឺជាសិទ្ធិផ្តាច់មុខរបស់ម្ចាស់បណ្តាំ។ យ៉ាងណាមិញ ម្ចាស់បណ្តាំមិនត្រឹមតែមានសិទ្ធិក្នុងការបង្កើតនោះទេ បានន័យថា ម្ចាស់បណ្តាំក៏មានសិទ្ធិនៅក្នុងការលុបចោលមតកសាសន៍នោះវិញផងដែរ។

សម្រាប់ការលុបចោលមតកសាសន៍នេះ ត្រូវបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ដែលទាក់ទងនឹងបញ្ញត្តិស្តីពីការលុបចោលមតកសាសន៍ ដូច្នេះ ការបកស្រាយនឹងមានដូចខាងក្រោម៖

#### ១.ទម្រង់នៃការលុបចោលមតកសាសន៍

ម្ចាស់បណ្តាំអាចលុបចោលមតកសាសន៍របស់ខ្លួនបាន នៅក្នុងអំឡុងពេលដែលធ្វើមតកសាសន៍រហូតដល់មុនពេលម្ចាស់បណ្តាំទទួលមរណភាព ដោយអាចលុបមតកសាសន៍បានតាមរយៈបីទម្រង់៖

- ✓ ការលុបចោលដោយទម្រង់នៃមតកសាសន៍
- ✓ ការលុបចោលដោយការចាត់ចែងនាពេលនៅរស់ និង
- ✓ ការលុបចោលដោយសារការបដិសេធលិខិតមតកសាសន៍។

#### ១.១.ការលុបចោលដោយទម្រង់នៃមតកសាសន៍

ម្ចាស់បណ្តាំអាចលុបចោលមតកសាសន៍មួយភាគ ឬទាំងមូលបានតាមទម្រង់នៃមតកសាសន៍។ មានន័យថា បើមតកសាសន៍ដែលបានធ្វើក្រោយ មានភាពផ្ទុយគ្នានឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថាមតកសាសន៍ដែលធ្វើក្រោយនេះ អាចលុបចោលមតកសាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ។[28] យ៉ាងណាមិញ ដើម្បីឲ្យមានភាពច្បាស់លាស់ចំពោះមតកសាសន៍ដែលបានធ្វើនៅពេលមុន ឬពេលក្រោយ គឺត្រូវកំណត់ទៅលើកាលបរិច្ឆេទដែលបានចុះនៅក្នុងមតកសាសន៍នោះ។

ដើម្បីលុបចោលមតកសាសន៍ដោយទម្រង់នៃមតកសាសន៍ គឺត្រូវសរសេរក្នុងមតកសាសន៍ថ្មីដោយបញ្ជាក់ឲ្យបានច្បាស់អំពីការលុបចោល។ ឧទាហរណ៍ លុបចោលមតកសាសន៍ ដែលចុះនាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ទាំងស្រុង។ ដោយវិធីម្យ៉ាងទៀត គឺធ្វើមតកសាសន៍ក្រោយដែលមានខ្លឹមសារផ្ទុយនឹងមតកសាសន៍មុន។

---

[28] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៨៩

### ១.២.ការលុបចោលដោយការចាត់ចែងនាពេលរស់នៅ

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬបានធ្វើសកម្មភាពផ្សេងទៀតចំពោះវត្ថុដែលជាកម្មវត្ថុនៃមតិក នាពេលរស់នៅ ត្រូវចាត់ទុកថាម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬសកម្មភាពផ្សេងនោះ។[29] មានន័យថា តាមមតកសាសន៍ ចលនវត្ថុជាក់លាក់មួយត្រូវក្លាយជាអច្ច័យទានសម្រាប់កូន "ក" ប៉ុន្តែ កាលនៅរស់ មតកជនបានធ្វើប្រទានកម្មនូវចលនវត្ថុជាក់លាក់នោះឲ្យទៅកូន "ខ" ហេតុនេះ មតកជនបានលុបចោលអច្ច័យទាន ដែលជាផ្នែកមួយនៃមតកសាសន៍ហើយ។[30]

### ១.៣.ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ។ ករណីនេះត្រូវយកទៅអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបានបំផ្លាញវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ដោយចេតនា។[31] មានន័យថា លិខិតមតកសាសន៍ ជាភស្តុតាងដែលបង្ហាញឆន្ទៈរបស់មតកជន ហេតុនេះបើមតកជនបានបំផ្លាញ ត្រូវចាត់ទុកថា សាមីខ្លួនលុបចោលមតកសាសន៍។[32]

ក្នុងករណីដែលលិខិតមតកសាសន៍ ត្រូវបានបំផ្លាញដោយទង្វើរបស់តតិយជន ឬដោយប្រធានសក្តិ អានុភាពនៃការលុបចោលមិនកើតមានឡើយ ប៉ុន្តែ ប្រសិនបើមានផ្នែកណាមួយមើលមិនយល់ ត្រូវចាត់ទុកថាផ្នែកនៃមតកសាសន៍នោះគ្មានអានុភាព។ ក្នុងករណីដែលមតកសាសន៍ត្រូវបានលុបចោលទាំងស្រុង នោះត្រូវចាត់ទុកថា មតកសាសន៍មិនត្រូវបានបង្កើតឡើងតាំងពីដើម។

**កំណត់សំគាល់៖ ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក**

បើអច្ច័យលាភី ពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឲ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬបើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឲ្យអច្ច័យលាភីនោះអនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះមិនបានអនុវត្តករណីយកិច្ចនៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬសន្តតិជននោះអាចទាមទារទៅតុលាការ ឲ្យលុបចោលអច្ច័យទាន

---

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៩០

[30] មេធាវី អុីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ១៩

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៩១

[32] មេធាវី អុីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ១៩

នោះបាន។[33] ករណីនេះ នឹងធ្វើការបកស្រាយបន្ថែមនៅក្នុងផ្នែកទី២ ស្តីពី "**អច្ច័យទាន និងការបែងចែកមត៌ក**" នៃជំពូកទី២។

**កថាខណ្ឌទី២៖ អានុភាពនៃមតកសាសន៍**

ជាគោលការណ៍ មតកសាសន៍មួយ អាចមានអានុភាពអនុវត្តបាន លុះត្រាតែមតកសាសន៍នោះ បានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ដូចដែលបានបកស្រាយខាងលើ។ បន្ទាប់ពីបានបំពេញគ្រប់លក្ខខណ្ឌ តើមតកសាសន៍នោះនឹងមានអានុភាពបែបណានៅក្នុងរបបសន្តតិកម្មនេះ? ដូច្នេះ ចំណុចបន្តបន្ទាប់នឹងមានបកស្រាយដូចខាងក្រោមនេះ។

**១.អានុភាពនៃមតកសាសន៍ក្នុងករណីមានលក្ខខណ្ឌបង្អង់**

ជាគោលការណ៍ មតកសាសន៍មានអានុភាពនៅពេលម្ចាស់បណ្តាំបានទទួលមរណភាព ហើយមតកសាសន៍ជាឆន្ទៈរបស់ម្ចាស់បណ្តាំក្នុងការសម្រេចនូវកម្មសិទ្ធិទ្រព្យសម្បត្តិ ក្រោយពេលដែលខ្លួនបានទទួលមរណភាព ហេតុនេះ ប្រសិនបើមតកសាសន៍នោះមានលក្ខខណ្ឌបង្អង់ លុះត្រាតែលក្ខខណ្ឌនោះត្រូវបានបំពេញទើបមតកសាសន៍មានអានុភាព។[34]

ឧទាហរណ៍: អច្ច័យលាភីបានទទួលអច្ច័យទានភ្ជាប់បន្ទុក ដែលបានកំណត់នៅក្នុងមតក-សាសន៍មានខ្លឹមសារថា អច្ច័យទាននេះអាចប្រគល់បាន លុះត្រាតែអច្ច័យលាភីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាមុនសិន បើមិនអនុវត្តតាមលក្ខខណ្ឌនេះទេ អច្ច័យលាភីមិនអាចទទួលមត៌-ករបស់ខ្លួនបានឡើយ។

**២.អានុភាពនៃការកំណត់ចំណែកមត៌ក**

បើមតកជនបានកំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌ក ដោយធ្វើអនុប្បទាននូវទ្រព្យជាក់លាក់មួយ ឬច្រើនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមរយៈមតកសាសន៍ ទ្រព្យនោះនឹងធ្លាក់ទៅលើសន្តតិជនដែលនឹងត្រូវទទួលទ្រព្យនោះដោយស្វ័យប្រវត្តិ នៅពេលមតកសាសន៍បង្កើតអានុភា-ព។ នៅក្នុងករណីនេះ មានការកំណត់វិធីបែងចែកមត៌កតាមមតកសាសន៍ ហេតុនេះមត៌កត្រូវបែងចែកតាមវិធីដែលបានកំណត់នោះ ដោយមិនចាំបាច់ឆ្លងកាត់ការពិភាក្សាដោយសហសន្តតិជនឡើយ។

**២.១.មរណភាពរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជន**

ក្នុងករណីជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម អានុភាពនៃការកំណត់ចំណែកមត៌ករបស់សន្តតិជន ឬការកំណត់នូវវិធីបែងចែកមត៌កតាមរយៈមតកសាសន៍ នឹងមានអានុភាពចំពោះសន្តតិជនជំនួស លើកលែងតែសន្តតិជនបោះបង់

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៩៣

[34] មេធាវី អ៊ីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ២០

សន្តតិកម្ម ឬមតកជនបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍ ឬគ្មានសន្តតិជនជំនួស។[35] ក្នុងករណីនេះ ត្រូវបានកំណត់ដូចគ្នាចំពោះ ជនដែលត្រូវបានសន្មតថាជាសន្តតិជន ដែលបានបាត់បង់សិទ្ធសន្តតិកម្ម ដូចបានកំណត់នៅក្នុងករណីជនដែលជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬដោយការកាត់កាល់សន្តតិជន ជាអាទិ៍។

### ២.២.ការកម្រិតនូវមតកសាសន៍ចំពោះអ្នកអាណាព្យាបាល

នៅមុនពេលបញ្ចប់ការគណនាចំណូលចំណាយក្នុងកិច្ចការឲ្យអាណាព្យាបាល បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ដែលជាប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬអ្នកដែលនៅជុំវិញខ្លួនរបស់អ្នកអាណាព្យាបាល នោះត្រូវចាត់ទុកមតកសាសន៍នោះជាមោឃៈ។ មូលហេតុដោយសារតែ មានការបារម្ភថា អ្នកអាណាព្យាបាលអាចប្រើល្បិចបោកប្រាស់ជននៅក្រោមអាណាព្យាបាល ឲ្យធ្វើមតកសាសន៍ដើម្បីជាផលប្រយោជន៍សម្រាប់ខ្លួន និងអ្នកដែលនៅជុំវិញខ្លួន។ ប៉ុន្តែ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ជាញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬបងប្អូនបង្កើតរបស់ជននៅក្រោមអាណាព្យាបាលទូទៅ នោះបញ្ញត្តិខាងលើនឹងមិនត្រូវយកមកអនុវត្តឡើយ មានន័យថា មតកសាសន៍នោះមិនត្រូវចាត់ទុកជាមោឃៈឡើយ ដោយសារតែមតកសាសន៍នោះបង្កើតឡើងដើម្បីជាផលប្រយោជន៍សម្រាប់អ្នកទាំងនោះជាស្រេចរួចហើយ។[36] ដូច្នេះ ការធ្វើមតកសាសន៍បែបនេះ នឹងមានសុពលភាពតាមផ្លូវច្បាប់។

### ២.៣.សិទ្ធិទទួលនូវទ្រព្យក្នុងករណីដែលអច្ច័យទានត្រូវបានមោឃៈភាព

ក្នុងករណីដែលអច្ច័យលាភីជាអភ័ព្វបុគ្គល ឬទទួលមរណភាព ឬបោះបង់អច្ច័យទាន ឬហេតុផ្សេងទៀត អច្ច័យទាននឹងមិនបង្កើតអានុភាពឡើយ ហើយទ្រព្យសម្បត្តិដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជននៃមតកជន លើកលែងតែមតកជនបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍។[37] ករណីអច្ច័យទាននេះ នឹងមានបកស្រាយនៅជំពូកបន្តបន្ទាប់ទៀត។

ឧទាហរណ៍: មតកជនបានកំណត់នៅក្នុងមតកសាសន៍ ដែលមានខ្លឹមសារថា ធ្វើអច្ច័យទានដែលមានទឹកប្រាក់ចំនួន ៥,០០០ ដុល្លារឲ្យទៅបុគ្គលឈ្មោះ (ក) ហើយប្រសិនបើ (ក) ស្លាប់នៅមុនពេលដែលមតកសាសន៍មានអានុភាព ទឹកប្រាក់ចំនួន ៥,០០០ ដុល្លារនោះនឹងធ្លាក់ទៅលើសន្តតិជនរបស់មតកជន។ ប៉ុន្តែ ក្នុងករណីដែលមតកជនបានបង្ហាញឆន្ទៈផ្សេងពីនេះ នៅក្នុងមតកសាសន៍ដែលមានខ្លឹមថា ទឹកប្រាប់ចំនួន ៥,០០០ ដុល្លារ នឹងត្រូវធ្វើអច្ច័យទានបន្តទៅឲ្យទាយាទ

[35] មេធាវី អ៊ីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ២១

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៩៥

[37] មេធាវី អ៊ីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ២១

របស់ (ក) ក្នុងករណីដែល (ក) ស្លាប់។ ដូច្នេះ អ្នកអនុវត្តមតកសាសន៍ ត្រូវធ្វើតាមឆន្ទៈរបស់មតកជន ដែលបានកំណត់នៅក្នុងមតកសាសន៍។

ក្រោយពីបានសិក្សា នៅក្នុងជំពូកទី១ ស្ដីពី "**មូលដ្ឋាននៃការបង្កើតមតកសាសន៍**" សង្កេតឃើញថា ដើម្បីបង្កើតលិខិតមតកសាសន៍ ចាំបាច់ត្រូវបំពេញនូវលក្ខខណ្ឌដូចដែលបានបកស្រាយនៅក្នុងជំពូកទី១ ខាងលើជាមុនសិន។ ក្នុងករណីដែលមតកសាសន៍ត្រូវបានបង្កើតអានុភាពរួចរាល់ គឺទាមទារឲ្យមានការអនុវត្តនីតិវិធីបន្តទៀត ដើម្បីឲ្យមតកសាសន៍នេះ មានភាពត្រឹមត្រូវដែលសមស្របទៅតាមផ្លូវច្បាប់បាន។

ដូច្នេះ ដើម្បីឲ្យមានលក្ខណៈគ្រប់គ្រាន់នៅក្នុងរបបសន្តតិកម្មតាមមតកសាសន៍នេះ គួរគប្បីសិក្សាបន្ថែមទៀតនៅក្នុងជំពូកទី២ ដែលស្ដីពី "**ការប្រតិបត្តិមតកសាសន៍**" និងចំណុចបន្តបន្ទាប់ទៀត។

# ជំពូកទី២

# ការប្រតិបត្តិមតកសាសន៍

# ជំពូកទី២
# ការប្រតិបត្តិមតកសាសន៍

ជាការឆ្លើយតបចំពោះប្រធានបទទាំងមូលនេះ ក៏ដូចជាការបកស្រាយបំពេញបន្ថែមចំពោះជំពូកទី១ ខាងលើដែលជា "មូលដ្ឋាននៃការបង្កើតមតកសាសន៍" និងដើម្បីបង្ហាញអំពីភាពពេញលេញនៃមតកសាសន៍ ដូច្នេះ គប្បីត្រូវធ្វើការសិក្សាបន្ថែមចំពោះ "ការប្រតិបត្តិមតកសាសន៍" ដែលក្នុងនោះរួមមានដូចជាៈ ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ សិទ្ធិអំណាច និងការប្រតិបត្តិមតក-សាសន៍ អច្ច័យទាន និងនីតិវិធីនៃការចែកមតិក ព្រមទាំងចំណុចផ្សេងទៀត ជាអាទិ៍។

## ផ្នែកទី១ៈការកំណត់អ្នកប្រតិបត្តិមតកសាសន៍ សិទ្ធិអំណាច និងការប្រតិបត្តិមតកសាសន៍

### កថាខណ្ឌទី១ៈ ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

#### ១.ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ដោយមតកជន

មតកជន គឺជាម្ចាស់បណ្តាំ ហើយមតកជនមានសិទ្ធិនៅក្នុងការកំណត់អ្នកដែលមានសិទ្ធិជាអ្នកប្រតិបត្តិមតកសាសន៍។ មតកជនអាចជ្រើសរើសមនុស្សដែលខ្លួនពេញចិត្ត និងទុកចិត្តដើម្បីអនុវត្តនូវមុខងារដែលខ្លួនប្រគល់ឲ្យ។ ការកំណត់អ្នកប្រតិបត្តិមតកសាសន៍នេះ មតកជនអាចសរសេរខ្លឹមសារនៅក្នុងមតកសាសន៍ថា បុគ្គល (ក) ឬ(ខ) គឺជាអ្នកប្រតិបត្តិមតកសាសន៍ នៅពេលដែលខ្លួនទទួលមរណភាព ឬនៅពេលដែលមតកសាសន៍នោះបង្កើតអានុភាព។

មតកសាសន៍នឹងត្រូវដាក់ឲ្យប្រតិបត្តិដោយបុគ្គលម្នាក់ ឬច្រើននាក់ដែលតាមរយៈការកំណត់ដោយម្ចាស់បណ្តាំ ហើយការកំណត់អាចស្តែងចេញនូវសកម្មភាព ២យ៉ាងៈ

##### ១.១.ម្ចាស់បណ្តាំប្រគល់អាណត្តិឲ្យតតិយជនជ្រើសរើសអ្នកប្រតិបត្តិ

នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព នោះជាពេលវេលាដែលត្រូវចាប់ផ្តើមសន្តតិកម្ម។ ក្នុងករណីដែលម្ចាស់បណ្តាំបានប្រគល់អាណត្តិឲ្យតតិយជនជាអ្នកកំណត់អ្នកប្រតិបត្តិមតកសាសន៍ ជនដែលបានទទួលអាណត្តិត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឲ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ។[38] ម្យ៉ាងវិញទៀត ចំពោះជនដែលបានបកស្រាយខាងលើ មានបំណងលាឈប់ពីអាណត្តិ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឲ្យសន្តតិជនដោយគ្មានការយឺតយ៉ាវ។[39] ចំពោះ "**ការលាឈប់ពីអាណត្តិ**" នឹងធ្វើការបកស្រាយជាបន្តបន្ទាប់ដូចខាងក្រោម។ អ្នកប្រតិបត្តិមតកសាសន៍ គឺជាអ្នកធ្វើសកម្មភាព គតិយុត្តពេលប្រតិបត្តិមតកសាសន៍ ហេតុនេះហើយច្បាប់បានកំណត់លក្ខខណ្ឌតម្រូវទៅលើ លក្ខណៈសម្បត្តិនៃអ្នក

[38] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៤ ១

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៤ ២

ដែលមិនអាចប្រតិបត្តិមតកសាសន៍បាន គឺមានជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និងជនធនក្ស័យ ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ។[40]

លើសពីនេះទៅទៀត បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឲ្យតតិយជនអនុវត្តភារកិច្ចជំនួសខ្លួនបានឡើយ លើកលែងតែមតកជន បានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍ ហើយបើតតិយជននោះ អនុវត្តភារកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវទទួលខុសត្រូវចំពោះអច្ច័យលាភី និងសន្តតិជន ប្រសិនបើមានការខូចខាត (សងសំណងនៃការខូចខាត) កើតឡើង ជាអាទិ៍។[41]

ម្យ៉ាងវិញទៀត ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ច្រើននាក់ សហអ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើការសម្រេច ដោយយកសំឡេងលើសពីពាក់កណ្តាលនៅក្នុងការអនុវត្តន៍តួនាទីជាអ្នកប្រតិបត្តិមតកសាសន៍នេះ។

### ១.២.ជនដែលបានទទួលអាណត្តិជាអ្នកប្រតិបត្តិមតកសាសន៍

ក្នុងករណីដែលម្ចាស់បណ្តាំមិនបានហាមនោះទេ ជនដែលបានទទួលអាណត្តិនេះ អាចកំណត់យកខ្លួនឯងជាអ្នកប្រតិបត្តិមតកសាសន៍។ ទោះបីជាយ៉ាងណាក៏ដោយ ជនដែលទទួលអាណត្តិពីម្ចាស់បណ្តាំឲ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ក៏អាចបដិសេធមិនទទួលអាណត្តិនេះបាន ដែលនេះ គឺជាគោលការណ៍នៃការគោរពសិទ្ធិសេរីភាពបុគ្គល។

លើសពីនេះទៅទៀត ក្នុងករណីដែលមតកជនមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ឬមិនបានប្រគល់អាណត្តិ ឲ្យទៅបុគ្គលណាម្នាក់ជាអ្នកកំណត់អ្នកប្រតិបត្តិមតកសាសន៍ទេនោះ តុលាការនឹងត្រូវជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ តាមរយៈពាក្យសុំរបស់សន្តតិជន និងអ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងមត៌កនោះផងដែរ។ ដូច្នេះ "**ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ដោយផ្លូវតុលាការ**" នឹងត្រូវបកស្រាយដូចខាងក្រោមនេះ។

## ២.ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ដោយផ្លូវតុលាការ

ក្នុងករណីគ្មានអ្នកប្រតិបត្តិមតកសាសន៍ ឬបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ តាមពាក្យសុំរបស់សន្តតិជន ឬអ្នកមានប្រយោជន៍ពាក់ព័ន្ធ។[42]

[40] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៧

[41] មេធាវី អ៊ីវ ប៉ូលី, *នីតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ២៣

[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៨

### ៣.ការដាស់តឿនឲ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ

សន្តតិជន ឬជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ អាចកំណត់អំឡុងពេលសមរម្យ (រយៈពេល៣ ខែ) និងធ្វើការដាស់តឿនចំពោះជនដែលត្រូវបានកំណត់ថាជាអ្នកប្រតិបត្តិមតកសាសន៍ ឲ្យធ្វើការឆ្លើយតបនៅក្នុងអំឡុងពេលនោះអំពីការយល់ព្រម ឬមិនយល់ព្រមកាន់មុនងារជាអ្នកប្រតិបត្តិមតកសាសន៍បាន។[43] ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍នោះ មិនឆ្លើយបញ្ជាក់ច្បាស់ ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថាឈប់ពីការងារនោះ។[44] ម្យ៉ាងវិញទៀត ចំពោះជនដែលត្រូវបានប្រគល់អាណត្តិឲ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍នៅក្នុងអំឡុងពេលដាស់តឿននេះទេ ត្រូវចាត់ទុកថាលាឈប់ពីអាណត្តិនោះ។

បន្ទាប់ពីបានធ្វើការសិក្សានូវកថាខណ្ឌទី១ ស្តីពី "ការកំណត់អ្នកប្រតិបត្តិមតកសាសន៍" រួចមក ជាបន្ទាប់ គប្បីត្រូវសិក្សាបន្ថែមអំពី "**តួនាទី និងសិទ្ធិអំណាចអ្នកប្រតិបត្តិមតកសាសន៍**" នៅក្នុងកថាខណ្ឌទី២ ដូចខាងក្រោមនេះ។

## កថាខណ្ឌទី២៖ សិទ្ធិអំណាចអ្នកប្រតិបត្តិមតកសាសន៍

### ១.តួនាទី និងសិទ្ធិអំណាចអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមតិក ព្រមទាំងធ្វើសកម្មភាពទាំងឡាយដែលជាការចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍។ អ្នកប្រតិបត្តិមតកសាសន៍អាចធ្វើការទូទាត់សងកាតព្វកិច្ច ចំពោះម្ចាស់បំណុលរបស់មតកជន ក្នុងករណីមានកាតព្វកិច្ច ដើម្បីជាការងាយស្រួលនៅពេលធ្វើការបែងចែកមតិក។ ម្យ៉ាងវិញទៀត ម្ចាស់បំណុលរបស់មតកជនអាចទាមទារឲ្យអ្នកប្រតិបត្តិមតកសាសន៍ធ្វើការសងបំណុលនោះបាន។ ក្នុងករណីដែលមតកសាសន៍មានអច្ច័យទាន អច្ច័យលាភីអាចទាមទារឲ្យអ្នកប្រតិបត្តិមតកសាសន៍នោះ អនុវត្តអច្ច័យទានបានផងដែរ។

ក្រោយពីបានកាន់មុខងារហើយ ដំបូងបំផុតអ្នកប្រតិបត្តិមតកសាសន៍ ត្រូវរៀបចំធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់ទៅឲ្យសន្តតិជនដោយគ្មានការយឺតយ៉ាវ។[45] បញ្ជីសារពើភ័ណ្ឌចាំបាច់ត្រូវតែមាន ដើម្បីងាយស្រួលកំណត់ឲ្យបានច្បាស់លាស់អំពីកម្មវត្ថុនៃសិទ្ធិគ្រប់គ្រងចាត់ចែងមតិករបស់អ្នកប្រតិបត្តិមតកសាសន៍។ ហើយសន្តតិជនអាចមានវត្តមាននៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន។[46]

---

[43] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៦ ១ កថាខណ្ឌ១

[44] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៦ ១ កថាខណ្ឌ២

[45] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៩ ១

[46] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៩ ២

អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និងករណីយកិច្ចដែលចាំបាច់ ដើម្បីធ្វើរាល់សកម្មភាពក្នុងការប្រតិបត្តិមតកសាសន៍ នៅក្នុងសិទ្ធិអំណាច និងមុខងារតួនាទីរបស់ខ្លួន ប៉ុន្តែជននេះមិនមែនជាប្រធាននៃសិទ្ធិ និងករណីយកិច្ចទេ។ ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនគ្មានសិទ្ធិចាត់ចែងមតិក ឬធ្វើសកម្មភាពផ្សេងទៀតដែលនាំឲ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ទោះបីជាសន្តតិជនជាប្រធាននៃមតិកក៏ដោយ។[47] ការកំណត់អំពីនត្ថិភាពរបស់សន្តតិជនចំពោះការចាត់ចែងមតិកបណ្ដាលមកពីបង្ការនៅឧបសគ្គ ក៏ដូចជាភាពស្មុគស្មាញនានា ដែលអាចកើតមានឡើងចំពោះការខ្វែងគំនិតគ្នារវាងអ្នកប្រតិបត្តិមតកសាសន៍ និងសន្តតិជន ហើយបង្កឲ្យមានការរាំងស្ទះ យឺតយ៉ាវ និងប៉ះពាល់ដល់ផលប្រយោជន៍នៃសន្តតិជនដទៃទៀត។ ទោះជាយ៉ាងក៏ដោយសកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍ បានអនុវត្តក្នុងមុខនាទីរបស់ខ្លួនត្រូវមានអានុភាពចំពោះសន្តតិជនដែលជាប្រធាននៃមតិក ដូចគ្នាទៅនឹងសកម្មភាពរបស់អ្នកតំណាងដែលមានអានុភាពផ្ទាល់ចំពោះម្ចាស់សិទ្ធិដែរ។

អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាពនៅក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ។ សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ចំពោះសន្តតិជន។[48]

### ២.សោហ៊ុយ និងកម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍

សោហ៊ុយពាក់ព័ន្ធនឹងការប្រតិបត្តិមតកសាសន៍ជាបន្ទុកនៃមតិក ប៉ុន្តែមិនអាចបន្ថយភាគបម្រុងដោយសារបន្ទុកនេះឡើយ។[49] សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍ មានដូចជា សោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍ សោហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌមតិក សោហ៊ុយគ្រប់គ្រងមតិក និងកម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍ ជាអាទិ៍។

អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន។[50] ដោយការកំណត់នេះ គឺម្ចាស់បណ្ដាំអាចសរសេរនៅក្នុងមតកសាសន៍ដែលមានខ្លឹមសារថា ចំពោះបុគ្គលដែលបានទទួលបន្ទុកនៅក្នុងការប្រតិបត្តិមតកសាសន៍ នឹងទទួលបានប្រាក់ចំនួន ២,០០០ ដុល្លារ ឬក៏បានកំណត់ផ្សេងពីនេះ ជាអាទិ៍។

ម្យ៉ាងវិញទៀត ក្នុងករណីដែលមតកជនមិនបានកំណត់កម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍ទេនោះ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតក-

[47] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២២១ ១

[48] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២២៣

[49] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២២៨

[50] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២២៦ ១

សាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមត៌កទំនាក់ទំនងរវាងម្ចាស់បណ្តាំ និងអ្នកប្រតិបត្តិមតកសាសន៍ និងស្ថានភាពផ្សេងទៀត។[51]

### ៣.ការឈប់ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

ដើម្បីលាឈប់ពីមុខងាររបស់ខ្លួន បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ។[52] ការបញ្ញត្តិបែបនេះ បានបង្ហាញអំពីភាពតឹងរ៉ឹងសម្រាប់ការបំពេញការងារ និងការលាឈប់របស់អ្នកប្រតិបត្តិមតកសាសន៍ ព្រោះការបំពេញការងារនេះទាមទារឲ្យមានការទទួលខុសត្រូវខ្ពស់ និងប្រុងប្រយ័ត្ន ដោយមិនអនុញ្ញាតឲ្យអ្នកប្រតិបត្តិមតកសាសន៍អាចធ្វើអំពើតាមទំនើងចិត្តបានឡើយ។ មូលហេតុត្រឹមត្រូវ សម្រាប់ការលាឈប់ អាចមានដូចជា មានជម្ងឺ ត្រូវទៅបំពេញបេសកម្មនៅឆ្ងាយរយៈពេលវែង ចូលកាន់មុខងារថ្មីដែលមានភាពមមាញឹកខ្លាំង ឬមានធុរៈចាំបាច់ណាមួយជាដើម ដែលបណ្តាលឲ្យមានការយឺតយ៉ាវក្នុងការធ្វើកិច្ចការងារ។

ម្យ៉ាងវិញទៀត បើអ្នកប្រតិបត្តិមតកសាសន៍ធ្វេសប្រហែសក្នុងភារកិច្ចដូចជា ការខ្ជិលច្រអូសក្នុងពេលធ្វើការងារ ការបាត់ខ្លួន ឬមានជម្ងឺរយៈពេលវែង ឬបើមានមូលហេតុមិនត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ដូចជា សន្តតិជន ឬអច្ច័យលាភីអាចដាក់ពាក្យសុំទៅតុលាការឲ្យបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍នោះបាន។

## កថាខណ្ឌទី៣៖ ការប្រតិបត្តិមតកសាសន៍

### ១.នីតិវិធីមុននៃការអនុវត្តមតកសាសន៍

#### ១.១.ការពិនិត្យបញ្ជាក់ និងការបើកលិខិត

ចំពោះមតកសាសន៍ ដែលធ្វើឡើងក្រៅពីទម្រង់នៃលិខិតយថាភូត ចាំបាច់ត្រូវមានការពិនិត្យបញ្ជាក់ឲ្យបានច្បាស់លាស់ និងត្រឹមត្រូវ។ ចំពោះការពិនិត្យ និងបញ្ជាក់ឲ្យបានច្បាស់លាស់លើលិខិតមតកសាសន៍នេះ គឺធ្វើឡើងដើម្បីឲ្យបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងមតកសាសន៍ ដូចជាសន្តតិជន អច្ច័យលាភីជាអាទិ៍ បានដឹងឮពីមត៌ក និងខ្លឹមសារនៃមតកសាសន៍ ដែលបន្សល់ទុកដោយមតកជន។ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម។[53]

[51] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២២៦ ២

[52] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៧ ១

[53] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៣

ក្នុងករណីដែលបានរកឃើញលិខិតមតកសាសន៍ ក្រោយមរណភាពរបស់មតកជន អ្នកថែរក្សា និងគ្រប់គ្រងមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការដោយគ្មានការយឺតយ៉ាវ។ ម៉្យាងវិញទៀត ចំពោះលិខិតដែលបិទដោយប្រថាប់ត្រា ត្រូវបើកនៅក្នុងនីតិវិធីតុលាការ ដើម្បីការពារកុំឲ្យមានការកែប្រែ ហើយក្នុងករណី មានជនណាបើកលិខិតមតកសាសន៍ប្រភេទនេះនៅក្រៅតុលាការ នឹងត្រូវទទួលរងពិន័យ មិនលើសពី ១,០០០,០០០ (មួយលាន) រៀល ហើយមតកសាសន៍នោះ នៅតែមានអានុភាពដដែល មិនត្រូវបានចាត់ទុកជាមោឃៈឡើយ ទោះបីមានការបើកលិខិតនេះនៅក្រៅតុលាការក៏ដោយ។[54]

### ១.២.ការយល់ព្រម និងបោះបង់សន្តតិកម្ម

សន្តតិជនអាចធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្មបាន។ សន្តតិកម្មអាចត្រូវបានបោះបង់ដោយមានមូលហេតុផ្សេងៗ ជាពិសេសក្នុងករណីដែលមតកជនមានទ្រព្យសម្បត្តិអកម្មច្រើនជាងទ្រព្យសម្បត្តិសកម្ម ដែលជាហេតុអាចឲ្យសន្តតិជនក្ស័យធនបាន។

សន្តតិជនត្រូវបានរក្សានូវសេរីភាពក្នុងការសម្រេចចិត្តថា តើត្រូវទទួលសន្តតិកម្ម ឬមិនទទួល? មានន័យថា ក្នុងអំឡុងពេល ៣ (បី) ខែ ដោយគិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មបានចាប់ផ្តើម សន្តតិជនត្រូវធ្វើការជ្រើសរើសមួយណា ពីក្នុងចំណោមជម្រើសទាំង ៣ ដែលជម្រើសនោះគឺជា (ក) ការយល់ព្រមទាំងស្រុង (ខ) ការយល់ព្រមដោយមានកម្រិត និង(គ) ការបោះបង់សន្តតិកម្ម។ ចំណុចនេះ នឹងមានការបកស្រាយដូចខាងក្រោមជាបន្តបន្ទាប់។

ប្រសិនបើអំឡុងពេល ៣ (បី) ខែ បានកន្លងផុតទៅ ក្នុងករណីដែលសន្តតិជនមានមូលហេតុត្រឹមត្រូវ សន្តតិជននោះ អាចស្នើរសុំទៅតុលាការ តាមរយៈពាក្យសុំ ដើម្បីធ្វើការពន្យារពេលក្នុងការយល់ព្រម ឬបោះបង់សន្តតិកម្មបាន។ សន្តតិជនអាចធ្វើការស្រាវជ្រាវមតិកបាន នៅមុនពេលធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្ម។[55] ចំពោះការកំណត់បែបនេះ ជាការការពារផលប្រយោជន៍ចំពោះសន្តតិជន ក្នុងករណីដែលមតកជនបានបន្សល់ទុកនូវកាតព្វកិច្ចច្រើនជាងមតិក ដែលជាហេតុអាចធ្វើឲ្យសន្តតិជនក្ស័យធនបាន។ ម្យ៉ាងវិញទៀត ការកំណត់អំឡុងពេល គឺជាការពិចារណាចំពោះទំនាក់ទំនងនៃការអនុវត្តសិទ្ធិលើបំណុលចំពោះមតកជន និងសន្តតិជន ហើយការអនុញ្ញាតឲ្យមានការពន្យារពេលតាមរយៈការដាក់ពាក្យសុំទៅតុលាការ គឺជាស្ថានភាពដែលមតិកមាននៅច្រើនកន្លែង ជាអាទិ៍ និងឲ្យតុលាការធ្វើការវិនិច្ឆ័យដោយផ្អែកលើលក្ខខណ្ឌមួយចំនួន ដូចជា គុណភាពនៃមតិក កាតព្វកិច្ចដែលទទួលដោយសន្តតិកម្ម ឬការធ្វើបញ្ជីសារពើភ័ណ្ឌ ជាអាទិ៍។

[54] មេធាវី អ៊ីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ២២

[55] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤៨ ១

ក្នុងករណីដែលសន្តតិជន បានទទួលមរណភាពនៅមុនពេលធ្វើការយល់ព្រម ឬបោះបង់នៅក្នុងអំឡុងពេលដែលបានកំណត់ដោយច្បាប់ ការគណនាអំឡុងពេលត្រូវគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះ បានដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួន។ ក្នុងករណី សន្តតិជនជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលដែលមានកំណត់នៅក្នុងច្បាប់ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថាសន្តតិកម្មចំពោះជនដែលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅត្រូវបានចាប់ផ្តើម។ ចំពោះការយល់ព្រម ឬបោះបង់សន្តតិកម្ម ចាំបាច់ត្រូវឲ្យអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលធ្វើការសម្រេចដើម្បីសាមីខ្លួន។[56]

(ក).**ការយល់ព្រមទទួលសន្តតិកម្ម**

សន្តតិជន អាចធ្វើការយល់ព្រមទទួលសន្តតិកម្មទាំងស្រុងបាន។ ប្រសិនបើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មទាំងស្រុង នោះសន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន។[57] ហើយចំពោះការយល់ព្រមទទួលសន្តតិកម្មទាំងស្រុង គឺសន្តតិជនគ្រាន់តែបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ហើយ ដោយមិនចាំបាច់ដាក់ពាក្យសុំទៅតុលាការ ដូចករណីការទទួលសន្តតិកម្មដោយមានកម្រិត ឬបោះបង់សន្តតិកម្មឡើយ។ ក្នុងអំឡុងពេលសមរម្យ ដែលកំណត់ទុកសម្រាប់ការពិចារណា ប្រសិនបើមិនបានធ្វើការយល់ព្រម ឬបោះបង់ចោលទេ សន្តតិជននឹងត្រូវចាត់ទុកថាបានយល់ព្រមទាំងស្រុង។[58] ម្យ៉ាងវិញទៀត ប្រសិនបើសន្តតិជន បានធ្វើសកម្មភាពណាមួយក្នុងចំណោមសកម្មភាពខាងក្រោមនេះ ត្រូវចាត់ទុកថា យល់ព្រមទាំងស្រុង (ការយល់ព្រមទាំងស្រុងតាមផ្លូវច្បាប់)។

.សន្តតិជនបានចាត់ចែងមតិកនោះទាំងអស់ ឬមួយភាគ លើកលែងតែសកម្មភាពរក្សា ឬគ្រប់គ្រងនៃមតិកនោះ។

.ទោះបីជាសន្តតិជនបានបង្ហាញឆន្ទៈយល់ព្រម ឬបោះបង់សន្តតិកម្មក៏ដោយ ប៉ុន្តែសន្តតិជនបានលាក់មតិកទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មតិកនោះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន លើកលែងតែនៅក្រោយពេលជនដែលត្រូវបានសន្មតថាជាសន្តតិជន ដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ដោយហេតុថា ក្នុងករណីសន្តតិជននៃលំដាប់បន្ទាប់បានយល់ព្រម សន្តតិកម្មនេះត្រូវឲ្យទៅសន្តតិជនលំដាប់បន្ទាប់នោះ ដើម្បីសន្ទនាភាព និងសង្គតិភាពតាមផ្លូវ

[56] មេធាវី អ៊ីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ៤១

[57] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៤

[58] ណូម៉ូរ៉ា តូយ៉ូហ៊ីរ៉ូ, *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី* (បោះពុម្ពលើកទី៥ ភ្នំពេញ, ២០១១), ១៧៥

ច្បាប់ ហេតុនេះ ប្រសិនបើសន្តតិជនលំដាប់មុនបានធ្វើសកម្មភាពបែបនេះ សន្តតិជនលំដាប់បន្ទាប់អាចធ្វើការទាមទារឲ្យសន្តតិជនលំដាប់មុនប្រគល់មតិកវិញ ឬទាមទារឲ្យសងសំណងនៃការខូចខាត។[59]

**(ខ).ការយល់ព្រមដោយមានកម្រិត**

សន្តតិជន ដែលមិនយល់ព្រមទទួលសន្តតិកម្មទាំងស្រុង អាចសម្រេចចិត្តយល់ព្រមទទួលសន្តតិកម្មដោយមានកម្រិតបាន។ ក្នុងករណីដែលសន្តតិជនធ្វើការយល់ព្រមទទួលសន្តតិកម្មដោយមានកម្រិត បានសេចក្តីថាសន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ។[60] ហើយដើម្បីធ្វើការយល់ព្រមទទួលសន្តតិកម្មដោយមានកម្រិត ចាំបាច់ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះទៅតុលាការក្នុងអំឡុងពេលដែលបានកំណត់។[61] ចំពោះការគណនានៃអំឡុងពេល គឺត្រូវគិតចាប់ពីពេលដែលសន្តតិជនបានដឹងពីការចាប់ផ្តើមសន្តតិកម្មនេះក្រោយគេ។ ចំពោះការដាក់ពាក្យសុំទៅតុលាការ សន្តតិជនត្រូវដាក់បញ្ជីសារពើភ័ណ្ឌនៃមតិកដោយបញ្ជាក់ពីមតិកសកម្ម និងមតិកអកម្មដែលសន្តតិជននោះបានទទួល ក្នុងកម្រិតសមត្ថភាពមួយដែលខ្លួនអាចដឹងបាន ហើយប្រសិនបើមិនបានបញ្ជាក់ដោយមានចេតនា នោះត្រូវចាត់ទុកថាយល់ព្រមទទួលសន្តតិម្មទាំងស្រុង។

ក្នុងករណី សន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតអាចធ្វើទៅបាន លុះត្រាតែសន្តតិជនទាំងអស់មានការយល់ព្រមរួមគ្នា។[62] ពីព្រោះ ប្រសិនបើមានសន្តតិជនមួយចំនួនយល់ព្រម ហើយបានអះអាងនូវចំណែកមតិក ការជម្រះបញ្ជីនូវទ្រព្យសម្បត្តិទាំងអស់នឹងមិនអាចធ្វើទៅបាននោះទេ។ ផ្ទុយទៅវិញ ប្រសិនបើសន្តតិជនមួយចំនួនបានបោះបង់សន្តតិកម្ម ជនដែលបោះបង់នោះ គឺគ្មានអានុភាពតាំងពីដំបូង ដូច្នេះ សន្តតិជនដែលនៅសល់ អាចយល់ព្រមទទួលសន្តតិកម្មដោយមានកម្រិតរួមគ្នាបាន ដោយលើកលែងតែសន្តតិជនមួយចំនួនក្នុងចំណោមសន្តតិជនដែលយល់ព្រមដោយមានកម្រិត ដែលធ្វើឡើងនៅមុនការយល់ព្រមតាមច្បាប់។

អានុភាពក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនពុំអាចទាមទារឲ្យសន្តតិជនទទួលខុសត្រូវបំណុល ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន

---

[59] មេធាវី អ៊ីវ ប៉ូលី, *នីតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ៨២

[60] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៦ ១

[61] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៧

[62] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៦ ២

នោះបានឡើយ។[63] ដែលជាគោលការណ៍ មតិកត្រូវធ្លាក់ទៅសន្តតិជន ប៉ុន្តែជាលក្ខណៈសារធាតុទ្រព្យសម្បត្តិជាមតិកត្រូវធ្វើការជម្រះបញ្ជីផ្សេងៗពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន ហេតុនេះសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់សន្តតិជន និងមតកជន មិនអាចរលត់បាននោះទេ។[64]

ចំពោះកម្រិតនៃការទទួលខុសត្រូវទៅលើការយល់ព្រមដោយមានកម្រិតនេះ សហសន្តតិជនត្រូវទទួលបន្តនូវកាតព្វកិច្ចដោយមានកម្រិតរបស់មតកជនទៅតាមចំណែកមតិក ហេតុនេះម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនណាម្នាក់ ឬច្រើននាក់ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលតាមចំណែកមតិកនីមួយៗនោះបាន។[65]

(**គ**).**ការបោះបង់សន្តតិកម្ម**

សន្តតិជនដែលមានបំណងបោះបង់សន្តតិកម្ម អាចធ្វើការបោះបង់សន្តតិកម្មបាន។ ចំពោះបុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំធ្វើការបោះបង់សន្តតិកម្មនេះទៅតុលាការនៅក្នុងអំឡុងពេល ៣ (បី) ខែ ក្រោយពេលដែលបានដឹងថាសន្តតិកម្មបានចាប់ផ្តើមចំពោះខ្លួន ដោយលើកលែងតែមានពាក្យសុំពន្យារពេលទៅតុលាការ។

**១.៣.ការគ្រប់គ្រងមតិក**

ក្រោយពេលដែលម្ចាស់បណ្តាំ ទទួលមរណភាព ការគ្រប់គ្រងមតិក គឺជារឿងមួយដ៏ចាំបាច់ដើម្បីថែរក្សាការពារមតិកឲ្យបានគង់វង្ស រហូតដល់មតិកនោះត្រូវបានបែងចែក។ ចំពោះបុគ្គលដែលជាអ្នកគ្រប់គ្រងថែរក្សាមតិកទៀតសោធ ក៏ជាកត្តាមួយសំខាន់ផងដែរ ដើម្បីជាការទុកចិត្ត ក្នុងការថែរក្សាមតិកនោះឲ្យបានស្ថិតថេរ។

តើបុគ្គលណាខ្លះជាអ្នកមានសិទ្ធិដើម្បីគ្រប់គ្រងថែរក្សាមតិក? តើការគ្រប់គ្រងថែរក្សាមតិកនេះត្រូវធ្វើយ៉ាងដូចម្តេចខ្លះ? ដូច្នេះ ការបកស្រាយនឹងមានដូចខាងក្រោមនេះ

សន្តតិជនដែលកាន់កាប់មតិក នៅពេលដែលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និងគ្រប់គ្រងមតិកនេះ រហូតដល់ពេលធ្វើការបែងចែកមតិក។[66] ការរក្សាទុក និងការគ្រប់គ្រងមតិកដោយសន្តតិជន ត្រូវធ្វើការប្រុងប្រយ័ត្នដើម្បីការពារទ្រព្យ សម្បត្តិទាំងនោះ ប្រៀបបីដូចជាទ្រព្យសម្បត្តិរបស់ខ្លួនឯងផងដែរ ដែលនេះជាគោលការណ៍សុច្ចរិត និងស្មោះត្រង់។

[63] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៨

[64] មេធាវី អ៊ីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ៤៣

[65] មេធាវី អ៊ីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ៤៤

[66] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៦២ ១

**(ក).ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍**

ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ បានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍រួចហើយ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើការគ្រប់គ្រងមតិក។[67] ក្នុងករណីដែលមតកជនបានកំណត់ទ្រព្យសម្បត្តិជាក់លាក់ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើការគ្រប់គ្រងមតិកនោះ ត្រឹមអ្វីដែលមតកជនបានកំណត់តែប៉ុណ្ណោះ។

**(ខ).អ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្ន**

នៅក្នុងករណីដែលគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេនោះ សន្តតិជន ឬអច្ច័យលាភី ឬម្ចាស់បំណុល អាចដាក់ពាក្យស្នើរសុំទៅតុលាការ ដើម្បីធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្ដោះអាសន្ន ហើយចំពោះការគ្រប់គ្រងនេះផងដែរ ត្រូវបន្តរហូតដល់ពេលធ្វើការបែងចែកមតិក។ ចំពោះសោហ៊ុយដែលទាក់ទងនឹងមតិក គឺជាបន្ទុកនៃមតិក ដោយលើកលែងតែកើតចេញពីកំហុសរបស់សន្តតិជន ជាអាទិ៍ ដែលនាំឲ្យជាបន្ទុកផ្ទាល់របស់បុគ្គលនោះ។

## ផ្នែកទី២៖ អច្ច័យទាន និងនីតិវិធីនៃការបែងចែកមត៌ក

### កថាខណ្ឌទី១៖ អច្ច័យទាន និងអច្ច័យលាភី

#### ១.អច្ច័យទាន

អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្ដាំបានធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈមតកសាសន៍។ ហើយអ្នកដែលទទួលអច្ច័យទានហៅថា អច្ច័យលាភី។ ទោះបីជាយ៉ាងណាក៏ដោយ អច្ច័យទានមិនអាចបំពានលើភាគបម្រុងបានឡើយ។

អច្ច័យទាន មាន ២ ប្រភេទ គឺ (ក).អច្ច័យទានមានកំណត់ និង(ខ).អច្ច័យទានសកលៈ

(ក).អច្ច័យទានមានកំណត់: គឺជាប្រទានកម្មដែលធ្វើឲ្យទៅបុគ្គលម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិដែលមានការកំណត់ជាក់លាក់តាមរយៈមតកសាសន៍។ នៅពេលដែលមតកសាសន៍ បានបង្កើតអានុភាព ទ្រព្យសម្បត្តិដែលកំណត់ជាក់លាក់នោះ នឹងត្រូវធ្លាក់ទៅលើអច្ច័យលាភី ដោយមិនចាំបាច់ត្រូវឆ្លងកាត់ការពិភាក្សាគ្នានោះឡើយ។

ឧទាហរណ៍: នៅក្នុងមតកសាសន៍ បានកំណត់ដែលមានខ្លឹមសារថា ដីឡូត៍ដែលស្ថិតនៅក្នុងភូមិសំរោង ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ គឺជាអច្ច័យទានដែលត្រូវប្រគល់ឲ្យទៅលោក (ក)។ ដូច្នេះ នៅពេលដែលមតកសាសន៍បង្កើតអានុភាព ដីឡូត៍ដែលបានកំណត់យ៉ាងច្បាស់លាស់នោះ នឹងត្រូវប្រគល់ឲ្យទៅលោក (ក)។

---

[67] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៦៣

(ខ).អច្ច័យទានសកលៈ គឺជាប្រភេទនៃប្រទានកម្មដែលមតកជនបានធ្វើឲ្យទៅបុគ្គលម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគ។ អច្ច័យទានសកលនេះ មុននឹងធ្វើការបែងចែកមតិក គឺត្រូវធ្វើការពិភាក្សាគ្នាជាមុនសិន ដើម្បីកំណត់នូវកម្មសិទ្ធិជាក់ស្តែង។

ឧទាហរណ៍ៈ នៅក្នុងមតកសាសន៍ បានកំណត់ដែលខ្លឹមសារថា ក្នុងចំណោមមតិកទាំងអស់ ត្រូវធ្វើអច្ច័យទាន ១/៣ ឲ្យទៅ (ក)។ ដូច្នេះ ក្រោយពេលមតកសាសន៍បង្កើតអានុភាព ចាំបាច់ត្រូវធ្វើការពិភាក្សាគ្នា ក្នុងការបែងចែកមតិក ដើម្បីកាត់ចំនួន ១/៣ នៃមតិកទាំងអស់ឲ្យទៅ (ក)។

### ១.១.ការបោះបង់អច្ច័យទាន

ជាទូទៅអច្ច័យទានកើតចេញពីឆន្ទៈ និងសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្តាំ ក្នុងការផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនទៅឲ្យអច្ច័យលាភី ហើយអានុភាពរបស់វានឹងកើតឡើងដោយស្វ័យប្រវត្តិ នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព ដោយគ្មានទាក់ទងនឹងឆន្ទៈរបស់អច្ច័យលាភីឡើយ។ ទោះបីជាបែបនេះក៏ដោយ វាមិនអាចបង្ខំអោយអច្ច័យលាភីទទួលយកវត្ថុ ឬសិទ្ធិ (ទ្រព្យសម្បត្តិ, បញ្ញើ, សិទ្ធិលើបំណុល ជាអាទិ៍) ដែលខ្លួនពុំមានឆន្ទៈក្នុងការទទួលនោះឡើយ ព្រោះវាជាគោលការណ៍គោរពនូវសេរីភាពបុគ្គល។ ដើម្បីការពារនូវសិទ្ធិនេះ ក្រមរដ្ឋប្បវេណីបានបង្ហាញថា នៅក្រោយពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាននៅពេលណាក៏បាន (អច្ច័យទានមានកំណត់) បន្ទាប់ពីបោះបង់ ការបោះបង់ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ហើយកម្មវត្ថុនៃទ្រព្យអច្ច័យទានត្រូវធ្លាក់លើសន្តតិជនរបស់មតកជនចាប់ពីពេលដែលសន្តតិកម្មបានចាប់ផ្តើម។[68]

ដោយឡែក ចំពោះការបោះបង់បោះអច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្តីពីការបោះបង់សន្តតិកម្ម។[69] ក្នុងករណីដែលអច្ច័យលាភីធ្វើការបោះបង់អច្ច័យទានសកល ត្រូវធ្វើតាមនីតិវិធីច្បាប់ ដោយត្រូវដាក់ពាក្យសុំបោះបង់អច្ច័យទានសកលនោះ ទៅតុលាការនៅក្នុងអំឡុងពេលដែលបានកំណត់ គិតចាប់ពីពេលដែលអច្ច័យទាននោះ មានអានុភាពចំពោះខ្លួន ហើយអំឡុងពេលនេះ អាចពន្យារបានតាមពាក្យសុំទៅតុលាការ។

### ១.២.អច្ច័យទានដែលមិនស្ថិតក្នុងមតិក

យោងតាមមាត្រា ១២០៧ នៃក្រមរដ្ឋប្បវេណី ចំពោះអច្ច័យទានដែលមិនស្ថិតក្នុងមតិក គឺគ្មានអានុភាពនោះទេ។ អច្ច័យទាន គឺជាសកម្មភាពចាត់ចែងមតិក ហេតុនេះហើយ ប្រសិនបើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ មិនស្ថិតនៅក្នុងមតិកនៅពេលដែលម្ចាស់បណ្តាំបានទទួលមរណ

[68] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៩៨

[69] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២០១ ១ កថាខណ្ឌ២

ភាពទេ នោះអានុភាពមិនត្រូវកើតឡើងឡើយ។ ឧទាហរណ៍ ចំនួនសរុបនៃមតិកមាន ២,០០០ ដុល្លារ ពេលនោះ ទោះបីជាបានធ្វើមតកសាសន៍ឲ្យទិញដីដែលមានតម្លៃ ៩,០០០ ដុល្លារឲ្យទៅ A ដែលបានជួយថែរក្សាខ្លួនក៏ដោយក៏មិនមានអានុភាពដែរ។ ជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន មិនចាំបាច់ចេញលុយខ្លួនឯង ដើម្បីប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍នោះទេ។ ផ្ទុយទៅវិញ ប្រសិនបើមតកសាសន៍កំណត់ថា ឲ្យលក់ដីជាក់លាក់មួយ ហើយយកលុយ ១,០០០ ដុល្លារពីប្រាក់ដែលបានមកពីការលក់ដីនោះ ឲ្យទៅ A មតកសាសន៍នោះនឹងមានសុពលភាព។ ទោះបីជានៅក្នុងមតិកគ្មានទ្រព្យជាសាច់ប្រាក់ ឬជាប្រាក់បញ្ញើនៅធនាគារក៏ដោយ ក៏មានដីនោះដែរ ដូច្នេះក្នុងករណីនេះ មិនត្រូវអនុវត្តតាមមាត្រានេះទេ។

### ១.៣.អច្ច័យទានដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

ក្នុងករណីមតកជនធ្វើអច្ច័យទាននូវវត្ថុ ឬសិទ្ធិដែលភ្ជាប់ជាមួយសិទ្ធិរបស់តតិយជន អច្ច័យលាភីមិនអាចទាមទារឲ្យរំលត់សិទ្ធិនោះ ចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ដូចជាការបញ្ចាំហ៊ីប៉ូតែក ជាអាទិ៍។[70] ឧទាហរណ៍ ម្ចាស់បណ្តាំបានធ្វើអច្ច័យទានជាផ្ទះដែលជាសិទ្ធិលើបំណុល (ហ៊ីប៉ូតែកនៅធនាគារ) ឲ្យទៅអច្ច័យលាភី។ ករណីនេះ អច្ច័យលាភីមិនអាចធ្វើការទាមទារឲ្យសន្តតិជនធ្វើការរំលត់សិទ្ធិនេះបានឡើយ។ ប៉ុន្តែ អច្ច័យលាភីត្រូវរង់ចាំការដោះស្រាយរបស់សន្តតិជនពាក់ព័ន្ធនឹងសន្តតិកម្មទាំងអស់ជាមុនសិន។

## ២.អច្ច័យលាភី

### ២.១.ការដាស់តឿនអច្ច័យលាភី

ក្នុងករណីដែលអច្ច័យលាភី មិនបានធ្វើការឆ្លើយតបចំពោះការទទួល ឬមិនទទួលស្គាល់ទៅនឹងអច្ច័យទានរបស់ខ្លួនទេនោះ បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឲ្យអច្ច័យលាភីទទួលស្គាល់ ឬបោះបង់អច្ច័យទានបានដោយកំណត់អំឡុងពេលសមរម្យ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថាអច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ។[71]

### ២.២.មរណភាពរបស់អច្ច័យលាភី

អច្ច័យលាភី អាចទទួលអច្ច័យទានបាននៅពេលដែលខ្លួនរស់រានមានជីវិត ឬខ្លួនបានទទួលមរណភាពក្រោយពេលដែលម្ចាស់បណ្តាំទទួលមរណភាពប៉ុណ្ណោះ។ ដូច្នេះ ក្នុងករណីដែលអច្ច័យលាភី បានទទួលមរណភាពនៅមុន ឬស្របពេលជាមួយនឹងម្ចាស់បណ្តាំ នោះអច្ច័យទានចំពោះអច្ច័-

---

[70] មេធាវី អ៊ីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ២៧

[71] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២០២

យលាភី មិនបង្កើតនូវអានុភាពឡើយ ហើយទាយាទរបស់អច្ច័យលាភី ក៏មិនអាចទទួលអច្ច័យទានជំនួសបានដែរ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បណ្តាំ បានបង្ហាញឆន្ទៈផ្សេងពីនេះនៅក្នុងមតកសាសន៍ដែលមានខ្លឹមសារថា ក្នុងករណីដែលអច្ច័យលាភី បានទទួលមរណភាពនៅមុនពេល ឬព្រមគ្នាជាមួយខ្លួន នោះអច្ច័យទាននឹងត្រូវធ្លាក់បន្តទៅបច្ចាញាតិផ្ទាល់របស់អច្ច័យលាភី។ ម្យ៉ាងវិញទៀត ត្រូវអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាព នៅមុនពេលដែលដែលលក្ខខណ្ឌនោះត្រូវបានបំពេញ។[72]

ក្នុងករណីដែលអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬបោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភី អាចទទួលស្គាល់ ឬបោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ។[73]

### ២.៣.ករណីអច្ច័យលាភីជាសន្តតិជន

ចំពោះអច្ច័យលាភីជាសន្តតិជន ក្នុងករណីដែលអច្ច័យលាភីនោះ បានធ្វើការបោះបង់សន្តតិកម្ម នោះត្រូវបានចាត់ទុកថាបានបោះបង់ចោលទាំងអច្ច័យទានផងដែរ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យលាភី បានទទួលស្គាល់សន្តតិកម្ម ដោយអាចបោះបង់ចោលនូវអច្ច័យទានបាន។ ចំពោះការកំណត់បែបនេះ គឺដើម្បីការពារចំពោះអច្ច័យលាភី ដែលទទួលស្គាល់តែអច្ច័យទាន ដោយមិនទទួលស្គាល់សន្តតិកម្ម ក្នុងករណីដែលសន្តតិកម្មនោះ មានភ្ជាប់ជាមួយនឹងកាតព្វកិច្ចដែលមតកជនមិនទាន់បានបំពេញ។ ម្យ៉ាងវិញទៀត គឺជាសិលធម៌នៃការរស់នៅក្នុងសង្គម ដើម្បីកុំឲ្យអច្ច័យលាភីទទួលស្គាល់តែផលប្រយោជន៍ ហើយបោះបង់នូវកាតព្វកិច្ចឡើយ។

### ២.៤.សិទ្ធទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់ពីពេលដែលខ្លួនអាចទាមទារឲ្យអនុវត្តអច្ច័យទានចំពោះខ្លួនបាន មានន័យថា បើគ្មានលក្ខខណ្ឌបង្អង់ ឬគ្មានភ្ជាប់បន្ទុក ហើយអច្ច័យទានបានបង្កើតអានុភាពដែលនេះ គឺជាអច្ច័យទានមានកំណត់។ រីឯអច្ច័យទានសកលវិញ ត្រូវឆ្លងកាត់ការពិភាក្សា បានន័យថាក្រោយការពិភាក្សា និងបែងចែកមតិក អច្ច័យលាភី អាចទាមទារឲ្យអនុវត្តអច្ច័យទានចំពោះខ្លួនបាន លើកលែងតែមតកជន បានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍។[74]

---

[72] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២០០ កថាខណ្ឌ២

[73] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២០៣

[74] មេធាវី អ៊ីវ ប៉ូលី, *និតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ២៦

### ២.៥.ការទទួលខុសត្រូវរបស់អច្ច័យលាភី

ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ច ដែលខ្លួនទទួលបន្ទុក ត្រឹមកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ។[75] ឧទាហរណ៍ មតកជនបានកំណត់នៅក្នុងមតកសាសន៍ ដែលមានខ្លឹមសារថា ធ្វើអច្ច័យទាននូវទឹកប្រាក់ចំនួន ៣០,០០០ ដុល្លារ ឲ្យទៅ (ក) ប៉ុន្តែ (ក) ត្រូវទទួលបន្ទុកចិញ្ចឹមបីបាច់ថែរក្សា (ខ) រហូតដល់ក្លាយជានីតិជន។

បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬដោយសារការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ។[76]

### ២.៦.សិទ្ធិ និងករណីយកិច្ចរបស់អច្ច័យលាភីសកល

អច្ច័យលាភីសកល មានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងសន្តតិជនដែរ។[77] បើមតិកទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឲ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន នោះសន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង។[78] ជាធម្មតា អច្ច័យលាភីសកលមានសិទ្ធិ និងករណីយកិច្ចដូចសន្តតិជន ក្នុងករណីដែលអច្ច័យលាភីសកលទទួលបាននូវទ្រព្យរបស់មតកជន អច្ច័យលាភីសកល ក៏ត្រូវទទួលបន្ទុកនូវកាតព្វកិច្ចរបស់មតកជនផងដែរ។[79]

### ៣.ការលុបចោល

ជាគោលការណ៍ ចំពោះអច្ច័យលាភី ដែលបានទទួលស្គាល់ ឬបោះបង់អច្ច័យទានរួចហើយនោះ មិនអាចធ្វើការលុបចោលនូវអច្ច័យទានដែលបានទទួលស្គាល់ ឬបោះបង់នោះវិញបានទេ នេះគឺដើម្បីជាការការពារចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន លើកលែងតែការបង្ហាញឆន្ទៈនោះមានវិការៈតែប៉ុណ្ណោះ។

### កថាខណ្ឌទី២៖ នីតិវិធីនៃការបែងចែកមត៌ក

### ១.ការបែងចែកតាមសន្តិវិធី

ជាគោលការណ៍ បន្ទាប់ពីម្ចាស់បណ្តាំបានទទួលមរណភាព និងបន្ទាប់ពីមតកសាសន៍ត្រូវបានបង្កើតអានុភាព ក្នុងករណីដែលមានសន្តតិជនច្រើននាក់ សហសន្តតិជនទាំងអស់ ត្រូវធ្វើការ

[75] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១១ ១
[76] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១១ ២
[77] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១២ ១
[78] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១២ ២
[79] មេធាវី អ៊ីវ ប៉ូលី, *នីតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ២៨

ពិភាក្សាគ្នាអំពីការបែងចែកមតិកនេះ។ ជាគោលការណ៍នៃក្រមរដ្ឋប្បវេណី បានផ្ដល់សិទ្ធិឲ្យទៅបុគ្គលទាំងអស់ធ្វើការពិភាក្សាគ្នា ឬចរចាគ្នា ដែលក្នុងស្មារតីនៃក្រម គឺដើម្បីរកដំណោះស្រាយដោយសន្តិវិធី។

សហសន្តតិជនអាចចាប់ផ្ដើមពិភាក្សាបែងចែកមតិកនៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពេលដែលចាប់ផ្ដើមសន្តតិកម្ម។[80] ចំពោះការផ្លាស់ប្ដូរម្ចាស់សិទ្ធិលើមតិក ដោយសារលទ្ធផលនៃការបែងចែក មិនអាចធ្វើទៅបានឡើយ បើអំឡុងពេលដែលច្បាប់កំណត់មិនទាន់កន្លងហួស (អំឡុងពេល ០៣ ខែ នៃការបង្ហាញឆន្ទៈបោះបង់ ឬទទួលសន្តតិកម្ម) លើកលែងតែ មានភាពចាំបាច់ដើម្បីសងកាតព្វកិច្ចមតកជន ឬមតកជនបានបង្ហាញឆន្ទៈនៅក្នុងមតកសាសន៍អំពីអំឡុងពេលនៃការបែងចែក ជាអាទិ៍។[81] ម្យ៉ាងវិញទៀត ការផ្ទេរនូវសិទ្ធិចំពោះការបែងចែកមតិក ចាំបាច់ត្រូវធ្វើឡើងតាមទម្រង់នៃការផ្ទេរសិទ្ធិនីមួយៗដូចជាលិខិតជាលាយលក្ខណ៍អក្សរ ចំពោះទ្រព្យដែលជាដីធ្លី ជាអាទិ៍ ក្នុងករណីចំណែកកម្មសិទ្ធិអវិភាគត្រូវបានផ្ទេរ ប៉ុន្តែដីធ្លីនោះត្រូវបានមតកជន ដាក់ជាកម្មសិទ្ធិរបស់សន្តតិជនជាក់លាក់ណាមួយ ហើយដើម្បីចុះបញ្ជីអំពីការផ្ទេរនោះ ត្រូវធ្វើលិខិតយថាភូត។

### ២.មូលដ្ឋាននៃការបែងចែក

នៅក្នុងការបកស្រាយខាងលើនេះ ជាករណីដែលមតកជនបានកំណត់អំពីវិធីនៃការបែងចែកមតិកនៅក្នុងមតកសាសន៍។ ប្រសិនបើមតកជនមិនបានកំណត់អំពីវិធីនៃការបែងចែកមតិកទេ តើត្រូវធ្វើដូចម្ដេច?

ក្នុងករណីដែលមតកជន មិនបានកំណត់អំពីវិធីបែងចែកមតិកនៅក្នុងមតកសាសន៍ទេនោះ ចំពោះការបែងចែកមតិក ត្រូវបែងចែកដោយធ្វើការពិចារណាទៅលើប្រភេទ និងលក្ខណៈនៃវត្ថុ ឬសិទ្ធិដែលមាននៅក្នុងមតិក ឬអាយុ មុខរបរ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត ស្ថានភាពជីវភាពរបស់សហសន្តតិជននីមួយៗ និងស្ថានភាពផ្សេងៗទៀត ជាអាទិ៍។ ម្យ៉ាងវិញទៀត ប្រសិនបើសន្តតិជនទាំងអស់បានព្រមព្រៀងគ្នា បើទោះបីជាខ្លឹមសារនៃការព្រមព្រៀងនោះ មានលក្ខណៈខុសគ្នាទៅនឹងគំនិតនៃខ្លឹមសារច្បាប់ក៏ដោយ ឲ្យតែមិនផ្ទុយទៅនឹងសណ្ដាប់ធ្នាប់សារណៈ និងទំនៀមទំលាប់ដ៏ល្អរបស់សង្គមទេ នោះអាចអនុវត្តបាន។ ក្នុងករណីដែលការបែងចែកនេះ ធ្វើឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់តម្លៃ សហសន្តតិជនអាចឲ្យសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន

[80] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៦៦ ១ កថាខណ្ឌ១

[81] មេធាវី អ៊ីវ ប៉ូលី, *នីតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ៩៥

ដោយដាក់លក្ខខណ្ឌឲ្យបង់ប្រាក់សម្រួលចំពោះសហសន្តតិជនផ្សេងទៀតតាមការពិភាក្សា ដូចជាការបែងចែកវត្ថុដែលជាកម្មសិទ្ធិអវិភាគ ដែលដំណោះស្រាយគឺប្រាក់សំណង។

ចំពោះសហព័ទ្ធ ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។ នៅក្នុងការបែងចែកមតិក សហព័ទ្ធនោះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមតិកនោះ។[82] ដោយរាប់បញ្ចូលទាំងសិទ្ធិអាទិភាពក្នុងការធ្វើលទ្ធកម្មរបស់សហព័ទ្ធដែលនៅរស់ ចំពោះទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ និងមតកជននាពេលនៅរស់ ដែលជាអានុស្សាវរីយ៍រវាងសហព័ទ្ធដែលនៅរស់ និងមតកជន។

ក្នុងករណីដែលមតកជន បានបន្សល់ទុកនូវកាតព្វកិច្ច ដូច្នេះ សហសន្តតិជនទាំងអស់ត្រូវធ្វើការសងកាតព្វកិច្ចនោះ ទៅតាមចំណែករៀងៗខ្លួន ដោយគិតទៅតាមភាគនៃចំណែកមតិកដែលខ្លួនទទួលបាន។ ហើយម្យ៉ាងវិញទៀត សហសន្តតិជនមិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ចនោះដោយគ្មានការយល់ព្រមពីម្ចាស់បំណុលឡើយ។

**៣.ការបែងចែកក្នុងករណីអវត្តមានសន្តតិជនខ្លះ**

ក្នុងករណីដែលដំណើរការនៃការបែងចែកមតិកត្រូវបានចាប់ផ្តើម ចំពោះការបែងចែកនោះនឹងត្រូវអនុវត្តដូចដែលបានបកស្រាយខាងលើ។ ក្នុងករណីមានសន្តតិជនមួយចំនួន ត្រូវបានអវត្តមាន តើការបែងចែកនេះនឹងធ្វើយ៉ាងដូចម្តេច?

ប្រសិនបើមានសន្តតិជនមួយចំនួន ត្រូវបានអវត្តមានដោយសារតែបុគ្គលដែលត្រូវបានសន្មតថាជាសន្តតិជន ជាអភ័ព្វបុគ្គល បុគ្គលដែលត្រូវបានផ្តាច់មតិក ឬបុគ្គលដែលត្រូវបានកាត់កាល់ ជាអាទិ៍។ ការអនុវត្តសន្តតិកម្មចំពោះជនទាំងនេះ នឹងត្រូវអនុវត្តទៅលើសន្តតិជនជំនួស ប៉ុន្តែ ប្រសិនបើមតកជនបានបង្ហាញឆន្ទៈផ្សេង ត្រូវអនុវត្តតាមឆន្ទៈនោះ។

**៤.ការបែងចែកក្នុងករណីអច្ច័យទានមោឃៈ**

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬទទួលមរណភាព ឬដោយសារហេតុផ្សេងទៀត ឬបើពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន។ ប៉ុន្តែបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ។[83]

[82] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៦៨

[83] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៨

**៥.ការបែងចែកដោយតុលាការ**

ក្នុងករណីការពិភាក្សារវាងសន្តតិជន ចំពោះការបែងចែកមតិកមិនបានសម្រេច ឬមិនបានធ្វើការពិភាក្សាគ្នាទេនោះ សន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការ ដើម្បីធ្វើការបែងចែកមតិកនោះ។

នីតិវិធីរបស់តុលាការចំពោះការបែងចែកមតិក គឺតុលាការនឹងធ្វើការពិចារណាទៅលើទំនៀមទំលាប់ និងគិតពិចារណាទៅលើការសម្រេចចិត្តរបស់សន្តតិជនទាំងអស់ ហើយតុលាការនឹងពិនិត្យទៅលើមតិភាគច្រើនលើសពីពាក់កណ្តាលនៃចំនួនមតិរបស់សន្តតិជនទាំងអស់នោះ។ ម្យ៉ាងវិញទៀត នៅក្នុងករណីដែលការសម្រេចចិត្តនេះ អាចនឹងបណ្តាលឲ្យប៉ះពាល់ដល់ផលប្រយោជន៍សន្តតិជនណាម្នាក់ ឬច្រើននាក់ នោះតុលាការនឹងធ្វើការពិនិត្យ ហើយប្រសិនបើមតិភាគតិចនោះ មានភាពត្រឹមត្រូវជាងមតិភាច្រើន នោះតុលាការនឹងអនុវត្តតាមមតិដែលត្រឹមត្រូវនោះ។

**៦.ជនដែលទទួលស្គាល់ក្រោយការបែងចែក និងការទាមទារ**

ក្នុងករណីដែលការពិភាក្សាបែងចែកមតិកក្រោយមរណភាពរបស់មតកជនត្រូវបានធ្វើឡើងដោយមានវត្តមានរបស់សហសន្តតិជនទាំងអស់នៅពេលនោះ ដូច្នេះ ការពិភាក្សានោះមានសុពលភាព។ ផ្ទុយទៅវិញ ក្នុងករណីដែលមតកជនបានទទួលស្គាល់ជាកូនពេលនៅរស់ ក៏ប៉ុន្តែដោយសារតែសន្តតិជនផ្សេងទៀតមិនបានដឹង ហើយបានដកជនដែលត្រូវបានទទួលស្គាល់នោះចេញពីការពិភាក្សាបែងចែកមតិក ឬក្នុងករណីដែលការទទួលស្គាល់ក្រោយមរណភាពរបស់មតកជនត្រូវបានធ្វើឡើងមុនការបែងចែកមតិក ក៏ប៉ុន្តែសន្តតិជនផ្សេងទៀតមិនបានយកចិត្តទុកដាក់ដោយមិនឲ្យជននោះចូលរួមក្នុងការបែងចែក ដូច្នេះ ការបែងចែកទុកជាមោឃៈ។

ក្នុងករណីប្រសិនបើមតកជន មិនបានកំណត់ចំណែកមតិករបស់ជនដែលទទួលស្គាល់ក្រោយការបែងចែក ឬទាមទារ ឬជនដែលមានសិទ្ធិជាសន្តតិជនដែលទើបនឹងចេញមុខក្រោយការបែងចែក និងការទាមទារ ជននេះ អាចទាមទារមតិកបាន ដោយផ្អែកលើសិទ្ធិភាគបម្រុង។

បន្ទាប់ពីបានធ្វើការសិក្សានូវចំណុចខាងលើជាបន្តបន្ទាប់រួចមក ដោយពិនិត្យឃើញថា "**សន្តតិកម្មតាមមតកសាសន៍**" គឺជាស្ថានភាពមួយនៃការបង្ហាញឆន្ទៈរបស់ម្ចាស់បណ្តាំ នាពេលចុងក្រោយមុនពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ដែលម្ចាស់បណ្តាំអាចបង្ហាញឆន្ទៈរបស់ខ្លួនបាននៅក្នុងលិខិតមតកសាសន៍។ ចំពោះមតកសាសន៍នេះទៀតសោធ ចាំបាច់ត្រូវឆ្លងកាត់នីតិវិធីនិងត្រូវបំពេញលក្ខខណ្ឌជាច្រើន ដូចដែលបានបកស្រាយនៅក្នុងជំពូកទី១ "មូលដ្ឋាននៃការបង្កើតមតកសាសន៍" និងជំពូកទី២ "ការប្រតិបត្តិមតកសាសន៍" ជាអាទិ៍។ យ៉ាងណាមិញ ចំណុចដែលបានបកស្រាយខាងលើ គឺនៅមានពាក់ព័ន្ធជាមួយនឹងបញ្ហាភាគបម្រុង ក្នុងករណីដែលមានការបំពាន

លើភាគបម្រុង ជាអាទិ៍។ ដូច្នេះ ដើម្បីឲ្យមានភាពកាន់តែច្បាស់ និងមានខ្លឹមសារពេញលេញចំពោះ ប្រធានបទស្តីពី "សន្តតិកម្មតាមមតកសាសន៍" នេះ គឺចាំបាច់ត្រូវធ្វើការសិក្សាបន្ថែមទៀតនៅក្នុង ជំពូកទី៣ ដែលស្តីអំពី "**ភាគបម្រុង**"។

# ជំពូកទី៣

# ភាគបម្រុង

# ជំពូកទី៣
# ភាគបម្រុង

ការសិក្សាពី ភាគបម្រុង គឺជាការស្វែងយល់ចំពោះបុគ្គលដែលមានសិទ្ធិជាសន្តតិជន ហើយសិទ្ធិនេះ ត្រូវបានបំពានដោយខ្លឹមសារនៃមតកសាសន៍របស់មតកជន។ ដូច្នេះ ភាគបម្រុង ត្រូវបានបែងចែកជា ២ ផ្នែក ដែលផ្នែកទាំងពីរនេះ នឹងធ្វើការសិក្សាទៅលើ ផ្នែកទី១៖ ការគណនាភាគបម្រុង និងការកាត់នៃភាគបម្រុង និងផ្នែកទី២៖ នីតិវិធីនៃការកាត់បន្ថយ និងការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដែលជាចំណុចសារវន្តចំពោះការបំពេញបន្ថែមនៃប្រធានបទស្តីពី សន្តតិកម្មតាមមតកសាសន៍នេះ។

**កំណត់សំគាល់៖** បញ្ហាភាគបម្រុងនេះ ត្រូវលើកយកមកបកស្រាយ លុះត្រាតែបុគ្គលដែលមានសិទ្ធិជាសន្តតិជនដែលត្រូវបានបំពានដោយខ្លឹមសារនៃមតកសាសន៍ ហើយបុគ្គលនេះ មិនសុខចិត្តចំពោះការបំពាននេះតែប៉ុណ្ណោះ។

## ផ្នែកទី១៖ ការគណនាភាគបម្រុង និងការកាត់នៃភាគបម្រុង

### កថាខណ្ឌទី១៖ ការគណនាភាគបម្រុង

#### ១.មូលដ្ឋាននៃភាគបម្រុង

របបភាគបម្រុង គឺជារបបធានាមួយនៃចំណែកមតិកកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលកំណត់ដោយច្បាប់។ មតកជនមានសេរីភាពក្នុងការធ្វើមតកសាសន៍ ក៏ប៉ុន្តែ របបនេះទទួលស្គាល់ឲ្យសន្តតិជនដែលកំណត់ដោយច្បាប់មួយចំនួន ធ្វើការបដិសេធនូវសេរីភាពនេះមួយភាគ។ របបភាគបម្រុងនេះ មានតួនាទីសម្រួលសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ ហើយព្រមទាំងជាវិធានមួយដែលធានា ដើម្បីកុំឲ្យមានការបំពានចំណែកមតិកផងដែរ។

ភាគបម្រុង នឹងត្រូវលើកយកមកពិភាក្សា និងបកស្រាយនៅក្នុងករណីមានការបំពានសិទ្ធិទៅលើបុគ្គល ដែលបុគ្គលនោះមានសិទ្ធិជាសន្តតិជន។ តើបុគ្គលណាខ្លះដែលជាអ្នកមានសិទ្ធិលើភាគបម្រុង?

ច្បាប់បានកំណត់ចំពោះបុគ្គលដែលមានសិទ្ធិលើភាគបម្រុង ក្នុងចំណោមសន្តតិជនទាំងនោះ រួមមាន បច្ឆាញាតិផ្ទាល់ ឬឪពុកម្តាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជនតែប៉ុណ្ណោះ ដែលជាអ្នកមានសិទ្ធិលើភាគបម្រុង។ ចំណែក បងប្អូនបង្កើត និងសន្តតិជនជំនួសនៃបងប្អូនបង្កើតមិនមានសិទ្ធិលើភាគបម្រុងឡើយ។ ជាគោលការណ៍ មតិក ១/៣ (១ភាគ៣) នៃមតិកទាំងអស់ គឺជាភាគបម្រុង ដែលនេះក្នុងករណី ឪពុកម្តាយ ឬជីដូនជីតា គឺជាអ្នកមានសិទ្ធិលើភាគបម្រុង និងមតិក ១/២ (១ភាគ២) នៃមតិកទាំងអស់ សម្រាប់បុគ្គលផ្សេងទៀត។ ហើយភាគបម្រុង ក៏អនុវត្តចំពោះសន្តតិជនជំនួសបុគ្គលទាំងនោះផងដែរ។ ម្យ៉ាងវិញទៀត ក្នុងករណី អ្នកមានសិទ្ធិលើភាគបម្រុង

មានចំនួនច្រើននាក់ ត្រូវធ្វើការបែងចែកទ្រព្យដែលចាត់ទុកថាជាភាគបម្រុងនោះ ទៅតាមសមាមាត្រនៃភាគបម្រុង។

ឧទាហរណ៍១ លោក (ក) ពុំមានទាំងកូន និងពុំមានទាំងសហព័ទ្ធ ប៉ុន្តែមាន (ខ)ឪពុក និង(គ) ម្តាយ។ ដូច្នេះ សន្តតិជនដែលមានសិទ្ធិក្នុងការទាមទារលើភាគបម្រុង គឺជាឪពុក និងម្តាយរបស់លោក (ក)។ ប្រសិនបើគិតទៅតាមច្បាប់បានកំណត់ចំពោះសន្តតិជនដែលជាឪពុកម្តាយ គឺចំណែកនៃភាគបម្រុងរបស់សន្តតិជនទាំងនោះស្មើនឹង ១/៣ (១ភាគ៣) នៃទ្រព្យជាមូលដ្ឋាននៃការគណនាភាគបម្រុង។ ដោយសន្តតិជនមានចំនួនពីរនាក់ ដូច្នេះ យកចំណែកនៃសិទ្ធិលើភាគបម្រុង ១/៣÷២= ១/៦។ ដូច្នេះ អាចសន្មតសម្មតិកម្មបានថា ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងមានចំនួន ១៨,០០០ ដុល្លារ

អាចធ្វើគំនូសតាងដូចខាងក្រោម

នាំឲ្យភាគបម្រុង=ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង×(១/៦)

នាំឲ្យភាគបម្រុង=១៨,០០០×(១/៦)=៣,០០០ ដុល្លារ

ដូច្នេះ ចំណែកនៃមតិក ដែលអាចទាមទារបានពីភាគបម្រុង គឺ(ខ)=៣,០០០ ដុល្លារ និង(គ)=៣,០០០ ដុល្លារ។

ឧទាហរណ៍២ លោក (ក) មានកូន (ខ) (គ) និង (ឃ)សហព័ទ្ធ។ ដូច្នេះ សន្តតិជនដែលមានសិទ្ធិក្នុងការទាមទារលើភាគបម្រុង គឺមាន (ខ) (គ) និង(ឃ)។ ប្រសិនបើគិតទៅតាមច្បាប់បានកំណត់ចំពោះសន្តតិជនផ្សេងក្រៅពីឪពុកម្តាយ ឬជីដូនជីតា ដូច្នេះមានតែកូន និងសហព័ទ្ធប៉ុណ្ណោះដែលចំណែកនៃភាគបម្រុងរបស់សន្តតិជនទាំងនោះស្មើនឹង ១/២ (១ភាគ២) នៃទ្រព្យជាមូលដ្ឋាននៃការគណនាភាគបម្រុង។ ដោយសន្តតិជនមានចំនួនបីនាក់ ដូច្នេះ យកចំណែកនៃសិទ្ធិលើភាគបម្រុង ១/២÷៣=១/៦។ ដូច្នេះ អាចសន្មតសម្មតិកម្មបានថា ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងមានចំនួន ១៨,០០០ ដុល្លារ

អាចធ្វើគំនូសតាងដូចខាងក្រោម

នាំឲ្យភាគបម្រុង=ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង×(១/៦)

នាំឲ្យភាគបម្រុង=១៨,០០០×(១/៦)=៣,០០០ ដុល្លារ

ដូច្នេះ ចំណែកមតិកដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារបាន គឺ(ខ)=៣,០០០ ដុល្លារ (គ)=៣,០០០ ដុល្លារ និង(ឃ)=៣,០០០ ដុល្លារ។

**២.ការគណនាភាគបម្រុង**

**(ក).ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃភាគបម្រុង:** ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស និងបូកជាមួយនឹងតម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម ហើយដកចំនួនប្រាក់សរុបនៃកាតព្វកិច្ចដែលត្រូវទទួលបន្តដោយសន្តតិកម្ម (កាតព្វកិច្ចដែលចំណាយទៅលើបុណ្យសព និងតាតព្វកិច្ចផ្សេងរបស់មតកជន)។ [84] ដូច្នេះ អាចទាញរូបមន្តដូចខាងក្រោម៖

| |
|---|
| ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង=មតិកនាពេលចាប់ផ្តើមសន្តតិកម្ម+តម្លៃនៃផលប្រយោជន៍ពិសេស+ប្រទានកម្ម-កាតព្វកិច្ច |

ឧទាហរណ៍: មតកជនបានបន្សល់ប្រាក់ចំនួន ៣,៣០០ ដុល្លារអាមេរិច ក្រោយខ្លួនទទួលមរណភាព ដោយមតកជនកាលនៅរស់ ក្នុងអំឡុងពេលមួយឆ្នាំមុនចាប់ផ្តើមសន្តតិកម្ម បានធ្វើប្រទានកម្មនូវប្រាក់ចំនួន ១,០០០ ដុល្លារ ឲ្យទៅកូន (ក) ព្រមទាំងសហាព័ទ្ធ (ង) បានទទួលនូវផលប្រយោជន៍ពិសេសជាអំណោយចិញ្ចៀនពេជ្រមួយវង់ពីមតកជន គិតជាប្រាក់ចំនួន ១,២០០ ដុល្លារ ហើយមតកជនមានកាតព្វកិច្ច (បំណុល) ចំនួន ៥០០ ដុល្លារ។ នៅក្នុងខ្លឹមសារនៃមតកសាសន៍បានកំណត់ថាកូន (ក) ត្រូវទទួបានមតិកចំនួន ១,០០០ ដុល្លារ (ខ) ទទួលបានមតិកចំនួន ១,០០០ ដុល្លារ (គ) ទទួលបានមតិក ៣០០ ដុល្លារ និង(ង) សហាព័ទ្ធទទួលបានមតិកចំនួន ១,០០០ ដុល្លារ។

**A.តាមរូបមន្តដើម្បីរកទ្រព្យជាមូលដ្ឋាន៖**

ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង=មតិកនាពេលចាប់ផ្តើមសន្តតិកម្ម+តម្លៃនៃផលប្រយោជន៍ពិសេស+ប្រទានកម្ម-កាតព្វកិច្ច

នាំឲ្យទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង=៣,៣០០+១,២០០+១,០០០-៥០០= ៥,០០០ ដុល្លារ ដូច្នេះ ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង គឺមានចំនួន ៥,០០០ ដុល្លារ។ (មានបន្តទៀតនៅចំណុចខាងក្រោម)

**(ខ).ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង:** ដោយលើកលែងតែផលប្រយោជន៍ពិសេស ប្រទានកម្មដែលកំណត់ដូចខាងក្រោមនេះ នឹងក្លាយជាប្រទាកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង៖

[84] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣១

.ប្រទានកម្មដែលបានធ្វើឡើងនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលដែលចាប់ផ្តើមសន្តតិកម្ម។[85] ជាគោលការណ៍ ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេលមួយឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្ម ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។[86] ចំពោះការកំណត់អំឡុងពេលបែបនេះ គឺជាការការពារចំពោះការបំពានដោយមិនត្រឹមត្រូវ ព្រមទាំងដើម្បីការពារចំពោះផលប្រយោជន៍របស់អច្ច័យលាភី ដែលទាក់ទងទៅនឹងការធ្វើមុខជំនួញជាអាទិ៍។

.ប្រទាកម្មដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្តាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង។[87] ចំពោះប្រទានកម្មបែបនេះ គឺជាចេតនារបស់ភាគីទាំងសងខាងដែលបានដឹងថាការធ្វើប្រទានកម្មបែបនេះ នឹងបណ្តាលឲ្យមានការបំពានលើអ្នកដែលមានសិទ្ធិលើភាគបម្រុង។ ហើយការធ្វើប្រទានកម្មបែបនេះ គឺមិនត្រូវបានកំណត់ពីអំឡុងពេលដូចដែលបានបកស្រាយខាងលើនោះទេ ហើយដើម្បីដឹងថាជាការបំពាន ឬមិនបំពាននោះ ត្រូវធ្វើដោយការប្រៀបធៀបទ្រព្យសម្បត្តិសរុបដែលមតកជនមានពេលធ្វើប្រទានកម្ម និងតម្លៃដែលបានធ្វើប្រទានកម្ម។

ឧទាហរណ៍១ មតកជនមានប្រាក់ចំនួន ១០,០០០ ដុល្លារ ដោយនៅមុនពេលមតកជនទទួលមរណភាព ២ ខែ មតកជនបានធ្វើប្រទានកម្មដល់កូន (ក) ចំនួន ៣,០០០ ដុល្លារដើម្បីបង្កើនមុខរបបរកស៊ី ដូច្នេះ នេះមិនមែនជាការបំពានភាគបម្រុងឡើយ បើទោះបីក្រោយមក ប្រាក់របស់មតក-ជន បានថយចុះនៅត្រឹម ២,០០០ ដុល្លារក៏ដោយ។

ឧទាហរណ៍២ មតកជនមានប្រាក់ចំនួន ១០,០០០ ដុល្លារ ដោយនៅមុនពេលមតកជនទទួលមរណភាព ២ ខែ មតកជនបានធ្វើប្រទានកម្មដល់កូន (ក) ចំនួន ៧,០០០ ដុល្លារដើម្បីបង្កើនមុខរបបរកស៊ី ដូច្នេះ នេះគឺជាការបំពានភាគបម្រុង។

.ចំពោះកាតព្វកិច្ចដែលមិនយកតម្លៃតប ឬការលើកលែងកាតព្វកិច្ច ដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ និងកិច្ចសន្យាដែលបានធ្វើដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ក៏ត្រូវបានចាត់ទុកថាជាប្រទានកម្មដែរ។

### កថាខ័ណ្ឌទី២៖ ការកាត់នៃភាគបម្រុង

#### ១.ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរួមមាន៖

[85] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣២

[86] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី៨ -ទី៩* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ៩២

[87] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣២ ខ

- អច្ច័យទាន
- ចំណែកមត៌កតាមមតកសាសន៍
- ផលប្រយោជន៍ពិសេស និង
- ប្រទានកម្ម

**កំណត់សំគាល់៖** ក្នុងករណីដែលអច្ច័យទានរបស់សន្តតិជន ការកំណត់ចំណែកមត៌ក និងការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនេះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជនប៉ុណ្ណោះ។ មានន័យថា ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ប្រសិនបើសន្តតិជនដែលត្រូវបានគេទាមទារឲ្យកាត់បន្ថយនោះ ត្រូវបានគេបំពានភាគបម្រុងរបស់ខ្លួនវិញ ដោយសារតែការកាត់បន្ថយនោះ សន្តតិជននោះអាចបដិសេធនូវការទាមទារនោះបាន។[88] ការបកស្រាយលម្អិតមាននៅក្នុង "**២.៣.ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងពីសន្តតិជន**"។

## ២.ចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុង អាចទាមទារបានដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និងចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម។[89] ដូច្នេះ អាចទាញរូបមន្តដូចខាងក្រោម៖

| |
|---|
| ចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង=ទ្រព្យនៃភាគបម្រុង-(ទ្រព្យនៃអ្នកមានសិទ្ធិលើភាគបម្រុងទទួលបានដោយសន្តតិកម្ម+ចំនួននៃផលប្រយោជន៍ពិសេស+ចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលសន្តតិជនម្នាក់ត្រូវបានទទួល) |

តាមសម្មតិកម្មខាងលើក្នុងចំណុច (២.ការគណនាភាគបម្រុង) ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃភាគបម្រុង គឺមានចំនួន ៥,០០០ ដុល្លារ

**B.ដើម្បីរកចំនួនទឹកប្រាក់នៃភាគបម្រុងដែលត្រូវបានគណនា៖**

ចំនួនទឹកប្រាក់នៃភាគបម្រុងដែលត្រូវបានគណនា=ភាគបម្រុង÷២ (ជាគោលការណ៍ សិទ្ធិលើភាគបម្រុងរបស់សន្តតិជនដែលជាបច្ឆាញាតិផ្ទាល់ ឬសហាព័ទ្ធិស្មើនឹង ១/២)

[88] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣១
[89] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣៤

នាំឲ្យចំនួនទឹកប្រាក់ដែលត្រូវបានគណនា=៥,០០០÷២=២,៥០០ ដុល្លារ

**C.ដើម្បីរកសិទ្ធិលើភាគបម្រុងនៃសន្តតិជនម្នាក់ៗ៖**

សិទ្ធិលើភាគបម្រុងនៃសន្តតិជន=ចំនួនទឹកប្រាក់ដែលត្រូវបានគណនា÷ចំនួនសន្តតិជន

នាំឲ្យសិទ្ធិលើភាគបម្រុងនៃសន្តតិជន=២,៥០០÷៤=៦២៥ ដុល្លារ។ ដោយចំណែកនៃមតិក ដែលសន្តតិជន (ក) (ខ) និង(ង) ទទួលបានតាមរយៈមតកសាសន៍ មានចំនួនលើសពីចំណែកនៃសិទ្ធិទាមទារលើភាគបម្រុង ដូច្នេះសន្តតិជនទាំងនេះ មិនអាចទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះបានទៀតឡើយ។ ដោយសន្តតិជនមានចំនួន៤ នាក់ ដែលជាគោលការណ៍ចំពោះកាតព្វកិច្ច ត្រូវធ្វើទៅតាមសមាមាត្រនៃចំណែកមតិករបស់សន្តតិជនម្នាក់ៗ។

**D.ដើម្បីរកចំនួនកាតព្វកិច្ចរបស់សន្តតិជនម្នាក់៖**

ចំនួនកាតព្វកិច្ចនៃសន្តតិជនម្នាក់=ចំណែកមតិកដែលសន្តតិជនបានទទួល×កាតព្វកិច្ចសរុប÷មតិកសរុប

(ក) ចំនួនកាតព្វកិច្ច=១,០០០×៥,០០÷៣,៣០០=១៥១.៥១៥

(ខ) ចំនួនកាតព្វកិច្ច=១,០០០×៥,០០÷៣,៣០០=១៥១.៥១៥

(គ) ចំនួនកាតព្វកិច្ច=៣០០×៥០០÷៣,៣០០=៤៥.៤៥៤

(ង) ចំនួនកាតព្វកិច្ច=១,០០០×៥,០០÷៣,៣០០=១៥១.៥១៥

ដោយសន្តតិជន (គ) ទទួលបានចំណែកមតិកតាមរយៈខ្លឹមសារនៃមតកសាសន៍ គឺចំនួន ៣០០ ដុល្លារ ដែលធាតុពិតតាមរយៈភាគបម្រុង (គ) ត្រូវទទួលបានមតិករហូតដល់ ៦២៥ ដុល្លារ។ (គ) គឺជាជនដែលត្រូវបានបំពានភាគបម្រុង ដូច្នេះលើកយកតែបញ្ហារបស់ (គ) មកដោះស្រាយតែប៉ុណ្ណោះ។

តាមរូបមន្ត៖

| |
|---|
| ចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង=ទ្រព្យនៃភាគបម្រុង-(ទ្រព្យនៃអ្នកមានសិទ្ធិលើភាគបម្រុងទទួលបានដោយសន្តតិកម្ម+ចំនួននៃផលប្រយោជន៍ពិសេស+ចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលសន្តតិជនម្នាក់ត្រូវបានទទួល |

នាំឲ្យចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង=៦២៥-(៣០០+0+៤៥.៤៥៤)=២៧៩.៥៤៦ ដុល្លារ។ ដូច្នេះចំនួនទឹកប្រាក់ដែល (គ) អាចទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបានគឺមានចំនួន ២៧៩.៥៤៦ ដុល្លារ។ (មានបន្តទៀតដែលនឹងដោះស្រាយក្នុងចំណុចស្តីពី“ការកាត់បន្ថយប្រទានកម្ម”)

## ផ្នែកទី២៖ នីតិវិធីនៃការកាត់បន្ថយ និងការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

### កថាខ័ណ្ឌទី១៖ នីតិវិធីនៃការកាត់បន្ថយ

#### ១.ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តនោះ អាចទាមទារឲ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ។[90] ជនដែលត្រូវបានបំពានភាគបម្រុង អាចយកសិទ្ធិដែលជាកម្មវត្ថុនៃការកាត់បន្ថយនោះមកធ្វើជារបស់ខ្លួនបាន ដោយធ្វើការទាមទារឲ្យកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ហើយអ្នកមានសិទ្ធិលើភាគបម្រុង ឬប្រតិសិទ្ធិរបស់ខ្លួនមានសេរីភាពក្នុងការទាមទារ ឬមិនទាមទារ និងប្រសិនបើមិនទាមទារ នាំឲ្យមតកសាសន៍មានសុពលភាពពេញលេញ ហើយជាគោលការណ៍ ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត ហេតុនេះ បើមិនទាមទារ នាំឲ្យបាត់បង់នូវអានុភាពដោយស្វ័យប្រវត្តិ ក្នុងកម្រិតនៃការបំពានសិទ្ធិលើភាគបម្រុងទៅតាមកម្រិតនៃភាគបម្រុង។ម្យ៉ាងវិញទៀត ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះ មិនចាំបាច់ធ្វើសកម្មភាពបណ្តឹងឡើយ ដោយតម្រូវឲ្យបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ ប៉ុន្តែបើភាគីម្ខាងទៀតមិនយល់ព្រម ត្រូវដាក់ពាក្យបណ្តឹង ហើយចំពោះការបង្ហាញឆន្ទៈនេះ ត្រូវធ្វើឡើងនៅក្នុងអំឡុងពេលនៃអាជ្ញាយុកាល ១ (មួយ) ឆ្នាំដោយគិតចាប់ពីថ្ងៃដែលខ្លួនដឹងពីការចាប់ផ្តើមសន្តតិកម្ម ឬ ៥ (ប្រាំ) ឆ្នាំគិតចាប់ពីថ្ងៃដែលចាប់សន្តតិកម្ម។ ដែលនាំឲ្យសិទ្ធិនេះ ត្រូវស្នងដោយជនដែលមានសិទ្ធិលើភាគបម្រុង ចាប់ពីពេលដែលបានបង្ហាញឆន្ទៈនោះ ហេតុនេះទោះបីជាដាក់ពាក្យបណ្តឹងក្រោយអំឡុងពេលនេះ ក៏មិនមានបញ្ហាអ្វីឡើយ។[91]

#### ២.លំដាប់នៃការកាត់បន្ថយ

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុង រួមមាន អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និងប្រទានកម្ម។ ដើម្បីយល់ដឹងថាតើការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងយ៉ាងដូចម្តេចនោះ ច្បាប់ក៏បានកំណត់ពីលំដាប់នៃការកាត់បន្ថយផងដែរ។[92]

---

[90] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣៥

[91] មេធាវី អ៊ីវ ប៉ូលី, *នីតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ៣៥

[92] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣៧

ប្រទានកម្ម និងការទទួលផលប្រយោជន៍ពិសេស មិនអាចកាត់បន្ថយបានឡើយ ដរាបណាអច្ច័យទាន និងការកំណត់ចំណែកមត៌ក មិនទាន់បានកាត់បន្ថយជាមុននោះទេ។[93] ជាគោលការណ៍ ប្រសិនបើមត៌កដែលមាននៅពេលចាប់ផ្ដើមសន្តតិកម្ម មានគ្រប់គ្រាន់ក្នុងការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង នោះប្រទានកម្ម និងការចាត់ចែងពិសេសរបស់មតកជនពេលនៅរស់ មិនចំបាច់លើកមកពិចារណាទេ។ ប៉ុន្តែ ក្នុងករណីដែលមានការកាត់បន្ថយមត៌កនាំឲ្យទៅជាការបំពានទៅលើភាគបម្រុង ដោយសារការធ្វើប្រទានកម្មពេលនៅរស់ ដូចនេះប្រទានកម្ម គឺជាកម្មវត្ថុនៃការកាត់បន្ថយផងដែរ។

**២.១.ការកាត់បន្ថយអច្ច័យទាន និងការកំណត់ចំណែកមត៌កតាមមតកសាសន៍**

ការកាត់បន្ថយអច្ច័យទាន គឺជាចំណុចមួយដែលត្រូវលើកយកមកពិចារណាក្នុងករណីដែលមានការបំពានលើភាគបម្រុង ហើយចំពោះទ្រព្យសម្បត្តិមុនដំបូងគេ ដែលត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺមានអច្ច័យទាន និងចំណែកមត៌ករបស់សន្តតិជនដែលបានកំណត់នៅក្នុងមតកសាសន៍។ ក្នុងករណី ប្រសិនបើនៅតែមិនគ្រប់ចំនួនដែលត្រូវកាត់បន្ថយ គឺត្រូវធ្វើការពិចារណាកាត់បន្ថយអច្ច័យទានដែលបានធ្វើចំពោះតតិយជន ដើម្បីបង្គ្រប់ចំនួនដែលត្រូវការនោះ។ ម្យ៉ាងវិញទៀត នេះគឺជាគោលការណ៍ ដែលគោលបំណងដើម្បីធ្វើឲ្យមានភាពច្បាស់លាស់នៃនីតិវិធីកាត់បន្ថយអច្ច័យទាន ព្រមទាំងចំណែកមត៌កដែលបានកំណត់នៅក្នុងមតក-សាសន៍ និងដើម្បីធ្វើចំណាត់ថ្នាក់ចំពោះអច្ច័យទានរបស់សន្តតិជន និងអច្ច័យទានរបស់តតិយជន។

សន្តតិជន គឺជាជនដែលត្រូវបានទទួលសន្តតិកម្មនូវឋានៈជាកូនបំណុលនៃអច្ច័យទានពីមតកជន ដូច្នេះ មុនដំបូងត្រូវធ្វើការសម្រួលផ្ទៃក្នុងចំពោះអច្ច័យទាន និងចំណែកមត៌កតាមមតក-សាសន៍របស់សន្តតិជនជាមុនសិន។ ករណីម្យ៉ាងវិញទៀត ចំពោះអច្ច័យទាន និងចំណែកមត៌កដែលបានកំណត់តាមវិធីនៃការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់ ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុ។ ប៉ុន្តែចំពោះករណីអច្ច័យទានរបស់សន្តតិជន និងចំណែកមត៌កដែលបានកំណត់ ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ហើយផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជន ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ។ លើសពីនេះទៅទៀត ក្នុងករណីដែលបានកំណត់ចំណែកមត៌កតាមមតកសាសន៍ ភាគនៃមត៌កត្រូវកាត់បន្ថយដើម្បីបង្គ្រប់

[93] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣៦

ភាគបម្រុង ដោយធ្វើការផ្លាស់ប្តូរភាគនោះ។ បានសេចក្តីថា ត្រូវរំលែកចំណែកមតិក ដើម្បីបង្គ្រប់ភាគបម្រុង ដោយលើកលែងតែមតកជនបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍។[94]

តាមរយៈសម្មតិកម្មដែលបានដោះស្រាយនៅក្នុងចំណុច (២.ការគណនាភាគបម្រុង នៃផ្នែកទី១៖ ការគណនាភាគបម្រុង និងការកាត់នៃភាគបម្រុង) និង(២.ចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង) ខាងលើរួចមក ដោយលទ្ធផលឃើញថា (គ) ត្រូវបានបំពានភាគបម្រុងដោយសន្តតិជនផ្សេង ដូច្នេះចំនួនទឹកប្រាក់ដែល (គ) អាចទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន គឺមានចំនួន ២៧៩.៥៤៦ ដុល្លារ។

តាមរយៈការបកស្រាយខាងលើ លំដាប់នៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរួមមាន អច្ច័យទាន ការកំណត់ចំណែកមតិកតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និងប្រទានកម្ម។ ដោយនៅក្នុងសម្មតិកម្មខាងលើ គឺគ្មានអច្ច័យទាននោះទេ ដូច្នេះ ការកំណត់ចំណែកមតិកតាមមតកសាសន៍ ត្រូវបានលើកយកមកពិភាក្សាកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

មតិកតាមមតកសាសន៍របស់សន្តតិជន ដែលត្រូវលើកយកមកកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរួមមាន៖

(ក) មតិកចំនួន ១,០០០ ដុល្លារ

(ខ) មតិកចំនួន ១,០០០ ដុល្លារ

(ង) មតិកចំនួន ១,០០០ ដុល្លារ

ដោយចំណែកមតិកតាមមតកសាសន៍របស់ (ក) (ខ) និង(ង) ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងមានចំនួនស្មើៗគ្នា ដូច្នេះ សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់ (គ) ត្រូវធ្វើសមាមាត្រនៃចំណែកមតិករបស់ (ក) (ខ) និង(ង)

នាំឲ្យចំណែកមតិកដែលត្រូវកាត់ ២៧៩.៥៤៦÷៣=៩៣.១៨២ ដុល្លារ ដូច្នេះ (ក) (ខ) និង(ង) ត្រូវកាត់ចំណែកមតិករបស់ខ្លួនចំនួន ៩៣.១៨២ ប្រគល់ឲ្យទៅ (គ)។

**E.ដើម្បីរកចំនួនទឹកប្រាក់សរុបរបស់សន្តតិជន (ក) (ខ) និង(ង)**

ចំណែកមតិកតាមមតកសាសន៍+ផលប្រយោជន៍ពិសេស+ប្រទានកម្ម-កាតព្វកិច្ច-សិទ្ធិទាមទារឲ្យបង្គ្រប់ភាគបម្រុងរបស់អ្នកមានសិទ្ធិលើភាគបម្រុង

(ក)=១,០០០+០+១,០០០-១៥១.៥១៥-៩៣.១៨២=១,៧៥៥.៣០៣ ដុល្លារ

(ខ)=១,០០០+០-១៥១.៥១៥-៩៣.១៨២=៧៥៥.៣០៣ ដុល្លារ

(ង)=១,០០០+១,២០០+០-១៥១.៥១៥-៩៣.១៨២=១,៩៥៥.៣០៣ ដុល្លារ

[94] មេធាវី អ៊ីវ ប៉ូលី, *នីតិរដ្ឋប្បវេណី៖ (មេរៀនសង្ខេប)* (ភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), ៣៦

**F.ដើម្បីរកចំណែកសរុបរបស់សន្តតិជន(គ)**

ចំណែកមតិកតាមមតកសាសន៍+សិទ្ធិទាមទារឲ្យបង្គ្រប់ភាគបម្រុងរបស់អ្នកមានសិទ្ធិលើភាគបម្រុង-កាតព្វកិច្ច

(គ)=៣០០+២៧៩.៥៤៦-៤៥.៤៥៤=៥៣៤.០៩២ ដុល្លារ។

ឧទាហរណ៍₂ មតកជនបានធ្វើសន្តតិកម្មដោយបានកំណត់ខ្លឹមសារនៅក្នុងមតកសាសន៍ថា សន្តតិជនកូន (ក) ទទួលបានចំណែកមតិកចំនួន ២,២០០ ដុល្លារ និងកូន(ខ) ទទួលបានចំណែកមតិកចំនួន ២០០ ដុល្លារ និងតតិយជនដែលជាបងធម៌ គឺ(គ) ទទួលបានមតិកចំនួន ១,៦០០ ដុល្លារ។

ដំណោះស្រាយ៖

ដូច្នេះអាចកំណត់បានថា ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង គឺមានចំនួន ៤,០០០ ដុល្លារ។

ចំណែកនៃសិទ្ធិលើភាគបម្រុង ដែលត្រូវបានកំណត់ដោយច្បាប់របស់សន្តតិជនដែលជាកូន ១/២ នៃទ្រព្យសរុបរបស់មតកជនដែលមានពេលចាប់ផ្តើមសន្តតិកម្ម។

នាំឲ្យភាគបម្រុង=៤,០០០÷២=២,០០០ ដុល្លារ

ដោយសន្តតិជនមានចំនួន ២ នាក់ នាំឲ្យ ២,០០០÷២=១,០០០ ដុល្លារ

ដូច្នេះ (ខ) ត្រូវបានបំពានភាគបម្រុងចំនួន ៨០០ ដុល្លារ ហើយចំនួនទឹកប្រាក់នេះ (ខ) អាចធ្វើការទាមទារចំណែកមតិកដែលត្រូវបានបំពាននេះចំនួន ៨០០ ដុល្លារពី (ក)។ ក្នុងករណីប្រសិនបើ ការកាត់បន្ថយនេះ នៅមិនទាន់គ្រប់ចំនួននោះទេ គឺត្រូវធ្វើការកាត់បន្ថយទៅលើចំណែកមតិករបស់តតិយជន (គ)។

នាំឲ្យចំណែកមតិករបស់សន្តតិជន (ក) (ខ) និងតតិយជន (គ) ដែលត្រូវទទួលបាន៖

(ក)=២,២០០-៨០០=១,៤០០ ដុល្លារ

(ខ)=២០០+៨០០=១,០០០ ដុល្លារ

(គ)=១,៦០០ ដុល្លារ។

## ២.២.លំដាប់នៃការកាត់បន្ថយប្រទានកម្ម ឬផលប្រយោជន៍ពិសេស

ការកាត់បន្ថយប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មកត្រូវធ្វើចំពោះប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេស ដែលបានធ្វើមុនមកជាបន្តបន្ទាប់។[95] ប៉ុន្តែបើការធ្វើប្រទានកម្ម ឬទទួលផលប្រយោជន៍ពិសេសលើសពី ២០ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិ

[95] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣៨ ១

ជនដែលបានទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធនូវការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន។[96] ហើយនេះ គឺជាគោលគំនិតដែលកំណត់លើអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ដោយគិតទៅលើចំនួនឆ្នាំ ដើម្បីធ្វើឲ្យមានសមភាពចំពោះសន្តតិជន និងអ្នកទទួលបានផលប្រយោជន៍ពិសេស។ ម្យ៉ាងវិញទៀត ក្នុងករណីប្រសិនបើ ជនដែលត្រូវបានធ្វើការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះ ជាសន្តតិជន ហើយសន្តតិជនត្រូវបានបំពានដោយសារការកាត់បន្ថយនោះវិញ ដូច្នេះ ការកាត់បន្ថយនោះត្រូវធ្វើឡើងដោយដកចំនួនភាគបម្រុងរបស់សន្តតិជនដែលត្រូវបានបំពាននោះជាមុនសិន។

## ២.៣.ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងពីសន្តតិជន

ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាសិទ្ធិទាមទាររបស់បុគ្គលដែលជាអ្នកមានសិទ្ធិលើភាគបម្រុង ក្នុងការទាមទារឲ្យកាត់នូវចំណែកដែលខ្វះ ឬបំពាននោះ។ ក្នុងករណីដែលសន្តតិជន ជាជនដែលត្រូវបានសន្តតិជនផ្សេងទៀតទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ហើយការទាមទារនេះ ត្រូវបានបំពានសិទ្ធិលើភាគបម្រុងរបស់ខ្លួនវិញ នោះអាចការពារសិទ្ធិរបស់ខ្លួនបាន។

ចំពោះការធ្វើប្រទានកម្ម និងអច្ច័យទាន ប្រសិនបើជនដែលទទួលនោះជាសន្តតិជន ហើយចំណែកមតិករបស់ពួកគេស្ថិតក្នុងស្ថានភាពនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ការកាត់បន្ថយនេះ ត្រូវធ្វើឡើងដោយដកនូវភាគបម្រុងរបស់សន្តតិជននោះជាមុនសិន ដើម្បីកុំឲ្យភាគបម្រុងរបស់ពួកគេត្រូវបានបំពានដោយសារការកាត់បន្ថយនោះ។[97] [98]

ឧទាហរណ៍: មតកជនបានបន្សល់ទុកមតិកចំនួន ១,០០០ ដុល្លារ ដោយកាលនៅរស់ បានធ្វើប្រទានកម្មចំនួន ១១,០០០ ដុល្លារឲ្យទៅ (ក) ដើម្បីជាដើមទុនសម្រាប់ប្រកបមុខរបរ ហើយក្រោយមកក៏បានធ្វើប្រទានកម្មចមនួន ៣,០០០ ដុល្លារឲ្យទៅ (ខ)។ ដោយខ្លឹមសារនៅក្នុងមតកសាសន៍បានកំណត់ថា មតិកដែលនៅសល់ ត្រូវប្រគល់ឲ្យទៅ (គ)។ ហើយ (គ) បានធ្វើការទាមទារសិទ្ធិលើភាគបម្រុង។

ដំណោះស្រាយ៖

ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុងមានចំនួន ១៥,០០០ ដុល្លារ

សិទ្ធិលើភាគបម្រុងរបស់សន្តតិជន (គ) ១/២ និងសន្តតិជនមានចំនួន ៣ នាក់ នាំឲ្យស្មើ ១/៦

ភាគបម្រុង=១៥,០០០×(១/៦)=២,៥០០ ដុល្លារ

---

[96] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣៨ ២

[97] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣៣

[98] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣៧ ១

នាំឲ្យ (គ) ២,៥០០-១,០០០=១,៥០០ ដុល្លារ ដូច្នេះ (គ) អាចទាមទារបានចំនួន ១,៥០០

ដោយប្រទានកម្មរបស់ (ខ) បានធ្វើក្រោយគេ ដូច្នេះត្រូវក្លាយជាកម្មវត្ថុនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ហើយការទាមទារនេះ អាចទាមទារបានត្រឹមកម្រិតមួយប៉ុណ្ណោះ ដើម្បីរក្សាភាគបម្រុងរបស់ (ខ) ហើយប្រសិននៅខ្វះ ត្រូវកាត់ពីប្រទានកម្មរបស់ (ក)។

នាំឲ្យ (ខ) ៣,០០០-៥០០=២,៥០០ ដុល្លារ

(ក) ១១,០០០-១,០០០=១០,០០០ ដុល្លារ

(គ) មតិករបស់ខ្លួន+កាតព្វកិច្ចដកពី(ខ)+កាតព្វកិច្ចដកពី(ក)

នាំឲ្យ (គ) ១,០០០+៥០០+១,០០០=២,៥០០ ដុល្លារ។

### ២.៤.ការកាត់បន្ថយប្រទានកម្មភ្ជាប់បន្ទុក

ការកាត់បន្ថយចំពោះប្រទានកម្មភ្ជាប់បន្ទុក ដែលបានដកតម្លៃនៃបន្ទុកចេញពីក្នុងតម្លៃនៃកម្មវត្ថុនោះ អាចទាមទារឲ្យធ្វើការកាត់បន្ថយបាន។[99] មានន័យថា ក្រោយពីការដកចំនួនទឹកប្រាក់ដែលជាប់ជាមួយនឹងបន្ទុក នោះចំនួនទឹកប្រាក់ដែលនៅសល់ពីការដកបន្ទុក គឺជាកម្មវត្ថុនៃការកាត់បន្ថយ។ ដើម្បីធ្វើការកាត់បន្ថយប្រទានកម្មដោយមានភ្ជាប់បន្ទុក គឺត្រូវធ្វើទៅតាមរូបមន្តដូចខាងក្រោម៖

| |
|---|
| ការកាត់បន្ថយប្រទានកម្មដោយមានភ្ជាប់បន្ទុក=តម្លៃនៃប្រទានកម្ម-តម្លៃនៃបន្ទុក |

ឧទាហរណ៍: កាលពីមតកជននៅរស់ គាត់បានធ្វើប្រទានកម្មម៉ូតូ ១ គ្រឿង ដែលមានតម្លៃគិតជាប្រាក់ចំនួន ២,០០០ ដុល្លារ ទៅឲ្យ (ក) ដោយភ្ជាប់លក្ខខណ្ឌថា (ក) ត្រូវបរិច្ចាគ ២០០ ដុល្លារ ដល់មជ្ឈមណ្ឌលកុមារកំព្រា។ ដូច្នេះ អ្នកមានសិទ្ធិលើភាគបម្រុង អាចទាមទារឲ្យកាត់បន្ថយបានត្រឹមតែ ១៨០០ ដុល្លារប៉ុណ្ណោះ។ ហើយទឹកប្រាក់ចំនួន ១,៨០០ ដុល្លារនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

### ២.៥.ការកាត់បន្ថយចំពោះកិច្ចសន្យាដែលចាត់ទុកថាជាប្រទានកម្ម

របបភាគបម្រុង គឺជារបបការពារជនដែលមានសិទ្ធិលើភាគបម្រុងពីការចាត់ចែងដោយគ្មានកម្រៃ ដូច្នេះ ចំពោះកិច្ចសន្យាដែលមានតម្លៃថ្នូរមិនត្រឹមត្រូវក៏ចាត់ទុកជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងដែរ។[100] ចំពោះការបកស្រាយខាងលើនេះ ត្រូវលើកយកមកពិភាក្សា នៅក្នុង

[99] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤១

[100] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី៨ -ទី៩* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ១០៣

ករណីដែលភាគីទាំងសងខាងបានដឹងថា ការធ្វើកិច្ចសន្យាបែបនេះ នឹងបណ្តាលឲ្យមានការខូចខាតដល់បុគ្គលដែលមានសិទ្ធិលើភាគបម្រុងតែប៉ុណ្ណោះ។

ឧទាហរណ៍: មតកជន មានដីស្រែមួយកន្លែង ដែលមានតម្លៃគិតជាប្រាក់ចំនួន ១២,០០០ ដុល្លារ ហើយបានលក់ឲ្យទៅ (ក) ដែលតម្លៃលក់ត្រឹមតែ ៥,០០០ ដុល្លារតែប៉ុណ្ណោះ។ ក្នុងករណីនេះ ប្រសិនបើភាគីទាំងសងខាងបានដឹងថា ការលក់ទិញនេះ នឹងបណ្តាលឲ្យមានការបំពានលើភាគបម្រុងរបស់សន្តតិជន នោះកិច្ចសន្យាលក់ទិញនោះ ត្រូវចាត់ទុកជាប្រទានកម្ម ហើយនឹងត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង និងដើម្បីរក្សានូវសមភាពរវាងភាគី នៅពេលដែលធ្វើការកាត់ត្រឡប់មកវិញ ទឹកប្រាក់ចំនួន ៥,០០០ ដុល្លារនោះត្រូវសងទៅឲ្យ (ក) ដែលជាអ្នកទិញនោះវិញ។

### ២.៦.ការកាត់បន្ថយក្នុងករណីបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម

អ្នកមានសិទ្ធិលើភាគបម្រុងមានសិទ្ធិទាមទារ ទោះបីជាសហសន្តតិជនដែលត្រូវទទួលការកាត់បន្ថយ បានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្មទៅឲ្យអ្នកដទៃ ឬបានបង្កើតផលុភោគ ឬសិទ្ធិប្រាតិភោគប្រត្យក្សសម្រាប់អ្នកដទៃក៏ដោយ ក៏ខ្លួនអាចទាមទារឲ្យអនុប្បទាយីសងជាប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាត់ចែងនោះ ទៅឲ្យអ្នកមានសិទ្ធិលើភាគបម្រុង។[101]

អ្នកមានសិទ្ធិលើភាគបម្រុងក៏អាចធ្វើការទាមទារពីអនុប្បទានិកបានផងដែរ ក្នុងករណីដែលអនុប្បទានិកបានដឹងថា ការធ្វើនេះនឹងបណ្តាលឲ្យមានការខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ប្រសិនបើមានការទាមទារឲ្យកាត់បន្ថយពីអនុប្បទានិក នាំឲ្យអនុប្បទាននឹងបាត់បង់អានុភាព។ ចំណែកឯការបង្កើតផលុបភោគ ឬសិទ្ធិប្រាតិភោគប្រត្យក្សសម្រាប់អ្នកដទៃ ក៏អនុវត្តដូចគ្នាផងដែរ ប្រសិនបើផលុភោគីជាជនទុច្ចរិត នោះអ្នកមានសិទ្ធិលើភាគបម្រុងអាចអះអាងអំពីការរលត់សិទ្ធិនោះបាន ដោយទាមទារឲ្យប្រគល់ការកាន់កាប់លើកម្មវត្ថុនោះវិញ និងទាមទារឲ្យលុបចោលនូវការចុះបញ្ជីចំពោះការបង្កើតសិទ្ធិហ៊ីប៉ូតែក។[102] ដូច្នេះ ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងក្នុងករណីបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម ដែលជាកម្មវត្ថុនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដែលនេះគឺជាសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត ហើយអច្ច័យទាន ឬប្រទានកម្មដែលបំពាន នឹងបាត់បង់អានុភាពដោយស្វ័យប្រវត្តិក្នុងកម្រិតដែលបានបំពាន ដោយសារការទាមទាររបស់បុគ្គលដែលមានសិទ្ធិលើភាគបម្រុង។

---

[101] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤៣ ១

[102] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ គន្ថីទី៨ -ទី៩* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ១០៤-១០៥

## ៣.អានុភាពនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

### ៣.១.ការសងផលដែលកើតចេញពីកម្មវត្ថុនៃការកាត់បន្ថយ

ជាទូទៅទ្រព្យសម្បត្តិអ្វីមួយតែងតែបានបង្កើតនូវផលផ្សេងៗ ដែលកើតចេញពីទ្រព្យនោះ។ ដូចជាដីចម្ការ ផលដែលកើតចេញពីដីចម្ការអាចមានដំណាំជាច្រើន។ ដូច្នេះ ក្រៅពីទ្រព្យសម្បត្តិ និងប្រាក់សំណងដែលត្រូវសង សន្តតិជនដែលមានសិទ្ធិទាមទារលើភាគបម្រុង អាចទាមទារនូវផលដែលកើតចេញពីកម្មវត្ថុនៃការទាមទារឲ្យកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងបានផងដែរក្រោយពីថ្ងៃដែលបានទាមទារឲ្យធ្វើការកាត់បន្ថយ។[103] បានន័យថា អាចទាមទារផលដែលកើតចេញក្រោយពីថ្ងៃដែលបានទាមទារនោះ។

ឧទាហរណ៍ មតកជន (ក) បានធ្វើប្រទានកម្មនូវផ្ទះល្វែងសម្រាប់ជួលឲ្យទៅ (ខ) ដោយផលដែលកើតចេញពីផ្ទះល្វែងនោះ មានចំនួន ១,៥០០ ដុល្លារជារៀងរាល់ខែ។ ហើយមតកជនបានទទួលមរណភាពនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ហើយនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ សន្តតិជនរបស់ (ក) ក៏បានទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងពី (ខ) ចំពោះផ្ទះល្វែងទាំងមូល ហើយ (ខ) ក៏បានប្រគល់ផ្ទះនោះនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០។ ដោយ (ខ) បានទទួលផលដែលកើតចេញពីកម្មវត្ថុនៃការទាមទារឲ្យកាត់បន្ថយនោះ គឺបានប្រាក់ឈ្នួលពីការជួលផ្ទះចំនួន៩ខែ។

នាំឲ្យ ៩×១,៥០០=១៣,៥០០ ដុល្លារ ដូច្នេះ (ខ) ត្រូវកាត់ទឹកប្រាក់ចំនួន៣ ខែ ដែលស្មើនឹង ៤,៥០០ ដុល្លារ ប្រគល់ឲ្យទៅសន្តតិជនរបស់ (ក) ដោយសារការទាមទារនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ ហើយទឹកប្រាក់ដែលនៅសល់ចំនួន ៩,០០០ ដុល្លារ (ខ) អាចរក្សាទុក។

### ៣.២.សំណងដោយបង់ថ្លៃ

សហសន្តតិជន អច្ច័យលាភី ឬបដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសងបាន ដោយបង់តម្លៃនៃចំណែកមតិកដែលបានកំណត់តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬតម្លៃនៃកម្មវត្ថុនៃប្រទានកម្មទៅឲ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវទទួលការកាត់បន្ថយ។[104] មានន័យថា អ្នកមានកាតព្វកិច្ចនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អាចរួចផុតពីកាតព្វកិច្ចនៃការសងបានដោយបង់តម្លៃនៃកម្មវត្ថុនោះទៅអ្នកមានសិទ្ធិលើភាគបម្រុង។

ប្រសិនបើអ្នកមានកាតព្វកិច្ចអះអាងថានឹងសងថ្លៃ ហើយបានសងថ្លៃក្រោយពីការព្រមព្រៀងគ្នា នោះសិទ្ធិទាមទារឲ្យកាត់បន្ថយនឹងរលត់ដោយស្វ័យប្រវត្តិ។ ប៉ុន្តែបើអ្នកមានកាតព្វកិច្ចមិន

[103] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤៩

[104] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៤

បានអះអាងថានឹងសងដោយបង់តម្លៃនោះទេ អ្នកមានសិទ្ធិលើភាគបម្រុងមិនអាចទាមទារឲ្យសងជាប្រាក់បានទេ គឺអាចត្រឹមតែទាមទារឲ្យសងជាវត្ថុនោះតែប៉ុណ្ណោះ។

**៣.៣.បន្ទុកនៃការខាតបង់ដោយអសាធនភាព**

ចំពោះការខាតបង់ដែលកើតឡើងដោយសារអសាធនភាព របស់សហសន្តតិជន អច្ច័យលាភី ឬបដិគ្គាហកដែលត្រូវទទួលការកាត់បន្ថយ ត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង។[105] នៅក្នុងការកំណត់របស់ក្រមរដ្ឋប្បវេណី ក្នុងករណីដែលភាគីម្ខាងទៀតនៃសិទ្ធិទាមទារឲ្យសងស្ថិតក្នុងអសាធនភាព អ្នកមានសិទ្ធិដែលជាភាគីម្ខាងទៀតនោះ ត្រូវទទួលបន្ទុកចំពោះការខាតបង់នោះ។ បានសេចក្តីថា បើទោះបីជាអ្នកមានកាតព្វកិច្ចដែលត្រូវបានទាមទារពីបុគ្គលដែលមានសិទ្ធិជាអ្នកអសាធនភាពក៏ដោយ ក៏បុគ្គលដែលមានសិទ្ធិលើភាគបម្រុងនោះ មិនអាចធ្វើការទាមទារពីបុគ្គលដែលជាអ្នកមានកាតព្វកិច្ចក្នុងលំដាប់បន្ទាប់ ឲ្យសងនូវចំណែកដែលខ្វះនោះបានឡើយ។

**កថាខណ្ឌទី២៖ ការរលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង**

**១.អាជ្ញាយុកាល**

សិទ្ធិទាមទារឲ្យកាត់បន្ថយភាគបម្រុង ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស ដោយគិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងការកំណត់ចំណែកមតិក អច្ច័យទាន ប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ។ សិទ្ធិទាមទារឲ្យកាត់បន្ថយក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស ដោយគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម។[106]

ការរំលត់ដោយអាជ្ញាយុកាលនៃសិទ្ធិទាមទារឲ្យកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនម្នាក់ ឬការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតឡើយ។

ក្នុងករណីដែលបានធ្វើប្រទានកម្ម ឬទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន។

**២.ការបោះបង់ភាគបម្រុង**

ភាគបម្រុងអាចបោះបង់ចោលទាំងអស់ ឬមួយផ្នែកបាន។ ការបោះបង់ភាគបម្រុង គឺអាចធ្វើបានដោយការបង្ហាញឆន្ទៈតែម្ខាងចំពោះអ្នកមានកាតព្វកិច្ច។[107] ចំណែកឯ ការបោះបង់ភាគបម្រុង

[105] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤០

[106] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤៥

[107] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤៦

នៅមុនពេលចាប់ផ្តើមសន្តតិកម្មមានអានុភាពបាន លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ។ ការណ៍នេះ ដើម្បីកុំឲ្យមានការបោះបង់សិទ្ធិនេះជាមុន ដោយសារតែចាញ់អំណាចឪពុកម្តាយ ជាអាទិ៍ ប៉ុន្តែប្រសិនបើមានការបោះបង់ ចាំបាច់ត្រូវមានការពិនិត្យតាងនាមជាអាណាព្យាបាលដោយតុលាការ។ តុលាការដែលទទួលពាក្យសុំអនុញ្ញាតនោះ ត្រូវធ្វើការវិនិច្ឆ័យដោយពិនិត្យមើលថា តើការបោះបង់នោះជាឆន្ទៈពិតរបស់ជនដែលមានសិទ្ធិលើភាគបម្រុងដែរឬទេ? តើការបោះបង់នោះមានភាពសមហេតុសមផលដែរឬទេ?

ម្យ៉ាងវិញទៀត ទោះបីជាបានបោះបង់សិទ្ធិនោះ មុនពេលចាប់ផ្តើមសន្តតិកម្មដោយទទួលការអនុញ្ញាតពីតុលាការក៏ដោយ ក៏អ្នកមានសិទ្ធិលើភាគបម្រុងនោះអាចដាក់ពាក្យសុំឲ្យតុលាការលុបចោលវិញបាន នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរក្រោយពេលបោះបង់សិទ្ធិនោះ។

**៣.សហសន្តតិជននៃភាគបម្រុង**

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ ឬការលះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតបាននោះទេ។[108] នេះបានន័យថា ទោះបីជាមានសន្តតិជនណាម្នាក់បានបោះបង់សិទ្ធិទាមទារលើភាគបម្រុងក៏ដោយ ក៏សន្តតិជនផ្សេងទៀតនៅតែមានសិទ្ធិរបស់ខ្លួនដដែល។

[108] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវ និងបកស្រាយចំពោះប្រធានបទស្តីពី "សន្តតិកម្មតាមមតកសាសន៍" រួចមក អាចធ្វើសេចក្តីសន្និដ្ឋានបានថា របបសន្តតិកម្ម គឺជារបបមួយដែលគោរពចំពោះសិទ្ធិរបស់ម្ចាស់បណ្តាំ ដែលអាចបង្ហាញឆន្ទៈរបស់ខ្លួនតាមរយៈខ្លឹមសារនៃមតកសាសន៍។ ហើយខ្លឹមសារនេះទៀតសោត ម្ចាស់បណ្តាំអាចធ្វើការកំណត់ចំពោះទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបែងចែកមតិក កំណត់ចំពោះបុគ្គលដែលមានសិទ្ធិក្នុងការស្នងមតិករបស់ខ្លួន។ ហើយបើទោះបីជាបុគ្គលនោះជាអ្នកមានសិទ្ធិតាមផ្លូវច្បាប់ក៏ដោយ ឬជាតតិយជនក៏ដោយ ក៏ម្ចាស់បណ្តាំអាចធ្វើទៅបាន ពីព្រោះនេះគឺជាគោលការណ៍ដែលបានកំណត់ថា សន្តតិកម្មតាមមតកសាសន៍ គឺជាការបង្ហាញឆន្ទៈរបស់ម្ចាស់បណ្តាំ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ត្រូវតែគោរពចំពោះបញ្ញត្តិស្តីពីភាគបម្រុងផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ម្ចាស់បណ្តាំអាចជ្រើសរើសទម្រង់ណាមួយក្នុងចំណោមទម្រង់នៃលិខិតមតកសាសន៍ដែលត្រូវបានកំណត់ដោយច្បាប់ ដើម្បីធ្វើជាលិខិតបណ្តាំ។

សន្តតិកម្មតាមមតកសាសន៍ គឺជាគោលការណ៍នៃការគោរពសិទ្ធិរបស់ម្ចាស់បណ្តាំ គឺម្ចាស់បណ្តាំអាចបង្កើតសិទ្ធិកម្មសិទ្ធិលើមតិកមួយ ឬច្រើនចំពោះបុគ្គលម្នាក់ ឬច្រើននាក់ ទៅតាមឆន្ទៈរបស់ខ្លួន ហើយសិទ្ធិដែលបានកំណត់នឹងកើតមានឡើង នៅពេលដែលសន្តតិកម្មត្រូវបានបង្កើតអានុភាព។ យ៉ាងណាមិញ បុគ្គលដែលនឹងត្រូវមានសិទ្ធិនេះ ក៏អាចបាត់បង់សិទ្ធិទទួលបានមតិកវិញផងដែរ ដោយសារការផ្តាច់មតិករបស់ម្ចាស់បណ្តាំតាមរយៈខ្លឹមសារនៃមតកសាសន៍ ឬតាមផ្លូវតុលាការ ដោយសារមូលហេតុផ្សេងៗ ឬតាមរយៈការបោះបង់សិទ្ធិរបស់ខ្លួន ជាអាទិ៍។ ម្យ៉ាងវិញទៀត ក៏អាចបាត់បង់សិទ្ធិដោយសារតែម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ដែលនេះ គឺជាសិទ្ធិផ្តាច់មុខរបស់ម្ចាស់បណ្តាំ។

ចំពោះបុគ្គលដែលមានសិទ្ធិក្នុងការស្នងនូវទ្រព្យសម្បត្តិដែលបានបន្សល់ដោយមតកជន គឺជាជនដែលត្រូវបានច្បាប់កំណត់ថាជាបុគ្គលដែលមានសិទ្ធិ ពោលគឺសន្តតិជន ជាញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ។ ក្រៅពីសន្តតិជន ក៏នៅមានតតិយជន ឬអច្ច័យលាភី ជាអាទិ៍ ក៏អាចនឹងទទួលបានមតិកផងដែរ ដោយតាមរយៈឆន្ទៈរបស់មតកជន។ ម្យ៉ាងវិញទៀត ចំពោះសន្តតិជនដែលត្រូវបានបំពានដោយខ្លឹមសារនៃមតកសាសន៍ ត្រូវបានច្បាប់គាំពារ ដោយមិនអនុញ្ញាតឲ្យមានការបំពានសិទ្ធិទទួលបានមតិកចំពោះជនទាំងនោះបានឡើយ គឺត្រូវប្រតិបត្តិរបបសន្តតិកម្មឲ្យសមស្របតាមគោលការណ៍នៃភាគបម្រុង។

ការសិក្សាអំពីសន្តតិកម្ម គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ចំពោះការបង្កើនពុទ្ធិ ក៏ដូចជាការស្វែងយល់ដែលទាក់ទងទៅនឹងការរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប។ របបសន្តតិកម្មតាមមតកសាសន៍ គឺជាវិធានមួយមានសារៈប្រយោជន៍ ដែលមានទំនាក់ទំនងជាមួយនឹងទ្រព្យសម្បត្តិ និងសិទ្ធិបេតិកភ័ណ្ឌក្នុងគ្រួសារ ដោយមនុស្សមានប្រាស្រ័យទាក់ទងញាតិលោហិតរវាងឪពុកម្តាយ និងកូន ជីដូនជីតា ឬបងប្អូនបង្កើត ជាអាទិ៍។

ចំពោះគ្រប់វិធានច្បាប់ទាំងអស់ ដូចជាសន្តតិកម្មនេះឯង គឺមិនមែនត្រឹមតែជាវិធានដែលបានកំណត់នៅក្នុងអត្ថបទ ក្រដាស ក្រម ឬច្បាប់ប៉ុណ្ណោះទេ តែគឺជាវិធានដែលមានគោលដៅដើម្បីការពារ និងជាវិធាននៃវិធីដោះស្រាយរាល់បញ្ហាដែលកើតមានឡើង ហើយមានគោលដៅចម្បងម្យ៉ាងទៀត គឺដើម្បីរក្សានូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅក្នុងសង្គម។ ប៉ុន្តែយ៉ាងណាមិញការសិក្សាទៅលើប្រធានបទស្តីពី "សន្តតិកម្មតាមមតកសាសន៍" ដែលបានបកស្រាយខាងលើនេះ គឺគ្រាន់តែជាការសិក្សាទៅលើទ្រឹស្តីមួយផ្នែកនៅក្នុងវិធានច្បាប់ ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនាពេលបច្ចុប្បន្នតែប៉ុណ្ណោះ ពីព្រោះនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ចំពោះការអនុវត្តទៅលើវិធានសន្តតិកម្មនេះ នៅមិនទាន់ទូលំទូលាយនៅឡើយទេ ដោយសារការយល់ដឹងរបស់ប្រជាពលរដ្ឋមួយចំនួននៅមានកម្រិត ព្រមទាំងបញ្ហាជីវភាពផងដែរ។

ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏អត្ថប្រយោជន៍ដែលទទួលបាននៅក្នុងវិធាននេះ នៅតែជាគុណតម្លៃដ៏វិសេសវិសាលនៅក្នុងការយល់ដឹង ដែលញ្ហានេះកំពុងតែកើតមានឡើងនាពេលបច្ចុប្បន្ន និងអាចកើតមានឡើងពេលអនាគត។ ម្យ៉ាងវិញទៀត គឺជាការយល់ដឹងចំពោះទ្រឹស្តីមួយផ្នែកដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងមានអានុភាព និងដើម្បីជាដើមទុនសម្រាប់ការសិក្សាទៅលើក្រមរដ្ឋប្បវេណី ដែលអាចនឹងបង្កើតឡើងជាថ្មីទៀតនៅពេលខាងមុខ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ចំពោះប្រធានបទដូចដែលបានបកស្រាយខាងលើរួចមក ដោយយល់ឃើញថា មានចំណុចវិជ្ជមាន និងអវិជ្ជមានមួយចំនួន ដោយសូមផ្តល់ជាអនុសាសន៍ដូចខាងក្រោមៈ

សន្តតិកម្មតាមមតកសាសន៍ គឺជាគោលការណ៍នៃការគោរពសិទ្ធិ និងជាគោលការណ៍ដើម្បីកំណត់អំពីសិទ្ធិ និងការបង្ហាញឆន្ទៈរបស់ម្ចាស់សិទ្ធិ ពោលគឺម្ចាស់បណ្តាំ ដែលនេះគឺជាស្មារតីនៃក្រមរដ្ឋប្បវេណី ដែលបានបង្កើតរបបនេះឡើង ដើម្បីជាប្រយោជន៍ចំពោះម្ចាស់សិទ្ធិ និងអ្នកទទួលស្នងនៃសិទ្ធិនេះ។

របបសន្តតិកម្ម គឺបានផ្តល់សិទ្ធិទូលំទូលាយឲ្យទៅម្ចាស់បណ្តាំ ក្នុងការកំណត់ចំពោះជនដែលមានសិទ្ធិទទួលស្នងមតិករបស់ខ្លួន បើទោះបីជាបុគ្គលនោះមិនមែនជាញាតិលោហិតផ្ទាល់របស់ខ្លួនក៏ដោយ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ក៏បានកម្រិតសិទ្ធិរបស់ម្ចាស់បណ្តាំក្នុងការតាក់តែងខិលិតមតកសាសន៍ ដែលធ្វើយ៉ាងណាឲ្យមានភាពសមស្របទៅនឹងច្បាប់ ហើយម្យ៉ាងវិញទៀត គឺត្រូវគោរពលើគោលការណ៍ស្តីពីភាគបម្រុង ដែលនេះ គឺជាការការពារសិទ្ធិរបស់ជនដែលមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីកុំឲ្យមានការបំពានសិទ្ធិរបស់ខ្លួនពីខ្លឹមសារនៃមតកសាសន៍ដោយភាពលំអៀងរបស់ម្ចស់បណ្តាំ។

សន្តតិកម្មតាមមតកសាសន៍ គឺជាគោលការណ៍នៃការគោរពសិទ្ធិចំពោះបុគ្គលដែលមានសិទ្ធិស្នងករណីយកិច្ច និងស្នងសិទ្ធិរបស់ម្ចាស់សិទ្ធិ ដោយអាចបង្ហាញឆន្ទៈចំពោះការទទួលយកការបដិសេធ ឬការទាមទារចំពោះការបំពានសិទ្ធិរបស់ខ្លួន ហើយបុគ្គលនេះត្រូវបានច្បាប់កំណត់ថាជាសន្តតិជន។

សន្តតិកម្មតាមមតកសាសន៍ គឺជាវិធានដែលបានលាយឡំរវាងគោលការណ៍ទំនៀមទំលាប់នីតិរបស់ខ្មែរ និងច្បាប់ដែលយកពីបរទេស ដូចជា ច្បាប់កូនកាត់ ដែលយកពីបារាំង និងច្បាប់របស់ជប៉ុន ដែលជាម្ចាស់ជំនួយក្នុងការតាក់តែងក្រមរដ្ឋប្បវេណី។ ចំពោះការយកខ្លឹមសារនៃវិធានច្បាប់បរទេសបែបនេះ គឺពិតជាមានភាពស្មុគស្មាញពិបាកក្នុងការស្វែងយល់ចំពោះអត្ថន័យនៃឃ្លាមួយចំនួន ដោយសារទំនៀមទំលាប់ បរិបទ របៀបរបប ប្រពៃណីវប្បធម៌ខុសគ្នារវាងកម្ពុជា និងប្រទេសទាំងនោះ។ តើការយកវិធានពីបរទេសបែបនេះ អាចនឹងមានផលប៉ះពាល់ដល់ប្រពៃណី វប្បធម៌ខ្មែរដែរឬទេ? ម្យ៉ាងវិញទៀត ការអនុវត្តរបបសន្តតិកម្មនៅកម្ពុជា តើប្រជាជនមួយចំនួនដែលមានបញ្ហាជីវភាពក្រីក្រ អាចធ្វើទៅបានដែរឬទេ?

នៅក្នុងរបបភាគបម្រុង បុគ្គលដែលមានសិទ្ធិលើភាគបម្រុង គឺមានបច្ឆាញាតិផ្ទាល់ ឬឪពុកម្ដាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជន ដែលសុទ្ធសឹងតែជាបុគ្គលដែលមានសិទ្ធិលើភាគបម្រុង ចុះហេតុអ្វីបានជាបងប្អូនបង្កើតរបស់មតកជនមិនមានសិទ្ធិលើភាគបម្រុង? ហើយជាក់ស្ដែងតាមរយៈការកំណត់របស់ច្បាប់ បងប្អូនបង្កើតរបស់មតកជន ក៏ត្រូវបានកំណត់ថាជាសន្តតិជនដែរ។ ដែលនេះ ច្បាប់ហាក់បីដូចជាមើលរំលងចំពោះបងប្អូនបង្កើតរបស់មតកជន ក្នុងករណីដែលមានការបំពានសិទ្ធិលើភាគបម្រុង។

បំពោះបញ្ហាដែលបានលើកឡើងខាងលើ ច្បាស់ណាស់ គឺពិតជាមិនអាចស្វែងចម្លើយនៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទដែលស្ដីពី "សន្តតិកម្មតាមមតកសាសន៍" ខាងលើនេះបានទេ។ នេះបានបញ្ជាក់ឲ្យឃើញថា ការសិក្សាស្រាវជ្រាវ គឺនៅមិនទាន់មានភាពគ្រប់គ្រាន់សម្រាប់ការស្វែងយល់ឲ្យកាន់តែច្បាស់ និងទូលំទូលាយនោះទេ។ ដូច្នេះ ជាការស្នើសុំ ឲ្យមានការសិក្សា និងបកស្រាយបន្ថែម ដោយផ្ដោតទៅលើបញ្ហាដែលបានកំណត់ខាងលើ ដើម្បីឲ្យមានវិសាលភាពគ្រប់ជ្រុងជ្រោយទៅលើប្រធានបទស្ដីពី "សន្តតិកម្មតាមមតកសាសន៍" នេះ ទើបអ្នកស្រាវជ្រាវក្រោយៗទៀត ងាយយល់ និងអាចក្ដាប់អត្ថន័យបានយ៉ាងល្អ។

# ឯកសារពិគ្រោះ និងឯកសារយោង

# ឯកសារពិគ្រោះ និងឯកសារយោង

**១.វចនានុក្រម៖**

១.១.ពុទ្ធសាសន៍បណ្ឌិត. ១៩៦៨ *វចនានុក្រមខ្មែរ ភាគទី១ ភាគទី២*។

១.២.ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់. ២០០៧. *សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី.* អាចរកបាននៅ https://drive.google.com/file/d/0B2BhecGG1FSeT2daRzZaeTZ1YU0/view?fbclid=IwAR0rFJCCWlw4Yp9n9WlxF5LgJTHqPmh_UHHKsdCCMwroSDyre09RxetXkbQ (ថតចម្លងថ្ងៃទី១ កក្កដា ២០១៩)

**២.អត្ថបទច្បាប់៖**

២.១.ក្រសួងយុត្តិធម៌. ២០០៧. *ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

២.២.ក្រសួងយុត្តិធម៌. ២០១០. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨-ទី៩.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

**៣.ស្នាដៃសៀវភៅ៖**

៣.១.ហាប់ ផល្លី. ២០១៧. *វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា*។

៣.២.មេធាវី អ៊ីវ ប៉ូលី. ២០១១. *នីតិរដ្ឋប្បវេណី.* ភ្នំពេញ។

៣.៣.តូយ៉ូហ៊ីរ៉ូ, ណូមូរ៉ា. ២០១១. *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី.* បកប្រែ សរ សិនិរ៉ា និង ស៊ឹម វិរៈ. ភ្នំពេញ។

៣.៤.ម៉ៃ ច័ន្ទតារាវុធ និងហូ ឡេងហុង. ២០១៤. *ម៉ៃ ច័ន្ទតារាវុធ៖ សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជាបច្ចុប្បន្ន.* ភ្នំពេញ។

៣.៥.ហ៊ីង គឹមឡេង និងទេព សុខ. ២០១៥. *ហ៊ីង គឹមឡេង៖ មតកសាសន៍.* ភ្នំពេញ។

៣.៦.ម៉ក់ ខ្វែត និងមុត សារីរត្ន. ២០១៦. *ម៉ក់ ខ្វែត៖ ភាគបម្រុង.* ភ្នំពេញ។

**៤.ឯកសារតាមរយៈការធ្វើបទបង្ហាញ សិក្ខាសាលា និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ៖**

៤.១.គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្រុមការងារកិច្ចការរដ្ឋប្បវេណី. ២០១៣. *សិក្ខាសាលាស្តីពីអច្ច័យទាន និងភាគបម្រុង.* https://web.facebook.com/cvnlawyer/photos/pcb.782430968569604/782428975236470/?type=3&theater (ថតចម្លងថ្ងៃទី១២ មិថុនា ២០១៩)។

៤.២.អ៊ីវ ប៉ូលី និងទេព បូផល. ២០១៨. *សន្តតិជន.* https://web.facebook.com/contributionoflaws/photos/a.749805028694230/749805242027542/?type=3&theater (ថតចម្លងថ្ងៃទី១២ មិថុនា ២០១៩)។

# ឧបសម្ព័ន្ធ

ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

**មាត្រា ១១៦៧.-** ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

## ជំពូកទី ៣
## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១
### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.-** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

ចោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

**មាត្រា ១១៦៩.-** សមត្ថភាពនាពេលធ្វើមតកសាសន៍

១-ម្ចាស់បណ្តាំ ត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ។

២-បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងមាត្រា ១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

## ផ្នែកទី ២
## ទម្រង់នៃមតកសាសន៍

**មាត្រា ១១៧០.-** ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

**មាត្រា ១១៧១.-** សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

**មាត្រា ១១៧២.–** បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍

បុគ្គលដែលកំណត់ដូចខាងក្រោមនេះ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍បានឡើយ :

ក-អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។

ខ-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និង ញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ ។

គ-បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិតរបស់សារការីនោះ ។

**មាត្រា ១១៧៣.–** មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយ ត្រូវចុះហត្ថលេខា រៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។

ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

**មាត្រា ១១៧៤.-** មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្ដាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតក-សាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

**មាត្រា ១១៧៥.-** មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

គ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្ដីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថ-លេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្ដាំ ។

**មាត្រា ១១៧៦.–** មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

**មាត្រា ១១៧៧.–** មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

១-ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្តាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវចុះហត្ថលេខាលើលិខិតនោះ ។

២-មតកសាសន៍ដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

៣-តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿ

ទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំ ។

**មាត្រា ១១៧៨.-** មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

១-បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់ ។

២-បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

៣-នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ម្ចាស់បណ្ដាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះបាន ។

៤-បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ ពាក្យ សារការីត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ។

៥-មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្ដាំនោះ បែរជាអាចធ្វើមតកសាសន៍បាន តាមទម្រង់ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ដល់មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមនេះ ក្រោយពេលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

**មាត្រា ១១៧៩.-** ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

១-នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) មាត្រា ១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមនេះ ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី ។

២-ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវអានឱ្យម្ចាស់បណ្តាំ ឬ សាក្សី ស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និង សាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះចូលទៅក្នុងលិខិតនោះ ។

**មាត្រា ១១៨០.-** ការសរសេរនាមត្រកូល និង នាមខ្លួន និង ការផ្តិតម្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា

ក្នុងករណីដែលសារការី និង សាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សីគ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្តិតម្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។

**មាត្រា ១១៨១.-** បទប្បញ្ញត្តិពិសេសចំពោះមតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែរមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិត

សម្ងាត់ នៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី ។

## ផ្នែកទី ៣
## ចំណុចនៃមតកសាសន៍

**មាត្រា ១១៨២.-** ការកំណត់ចំណែកមត៌ក

១-មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍ ឬ អាចបង្គាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្ដីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង ។

២-បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) ជំពូកទី ២ ។

**មាត្រា ១១៨៣.-** ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្មនោះ បាន ។

**មាត្រា ១១៨៤.-** អនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្ដាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩ (និយមន័យនៃអច្ច័យទាន) នៃក្រមនេះបាន នៅក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង ។

**មាត្រា ១១៨៥.-** អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

១-បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតក-សាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ ។

២-ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ ។

**មាត្រា ១១៨៦.-** ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន ។

**មាត្រា ១១៨៧.-** ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ដោយផ្តល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេងៗទៀតបាន ។ នៅក្នុងករណីនេះ សន្តតិជន ជាអាទិ៍ ត្រូវគោរពទៅតាមមតកសាសន៍នោះ ។

## ផ្នែកទី ៤
## ការលុបចោលនូវមតកសាសន៍

**មាត្រា ១១៨៨.-** ពេល និង ទម្រង់នៃការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៤ (ការលុបចោលនូវមតកសាសន៍) នេះ ។

**មាត្រា ១១៨៩.-** ការលុបចោលដោយទម្រង់នៃមតកសាសន៍

១-ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។

២-បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតកសាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។

**មាត្រា ១១៩០.-** ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ ។

**មាត្រា ១១៩១.-** ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

**មាត្រា ១១៩២.-** ការបោះបង់សិទ្ធិលុបចោលមតកសាសន៍

ម្ចាស់បណ្តាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍ បានឡើយ ។

**មាត្រា ១១៩៣.-** ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្ដាំបានតម្រូវឱ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះ មិនបានអនុវត្តករណីយកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះអាចទាមទារទៅតុលាការ ឱ្យលុបចោលអច្ច័យទាននោះបាន ។

## ផ្នែកទី ៥
## អានុភាពនៃមតកសាសន៍

**មាត្រា ១១៩៤.-** ពេលដែលមតកសាសន៍បង្កើតអានុភាព

១-មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

**មាត្រា ១១៩៥.-** អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍

១-បើមតកជនបានកំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថា ត្រូវបានធ្លាក់ទៅ

សន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេលដែលមតកជននោះ បានទទួលមរណភាព ។

**មាត្រា ១១៩៦.–** មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ករបស់សន្តតិជន ឬ វិធីនៃការបែងចែកមត៌ក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១១៩៧.–** ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតក-សាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ១១៩៨.-** សិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ បើពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

## ផ្នែកទី ៦
## អច្ច័យទាន

**មាត្រា ១១៩៩.-** និយមន័យនៃអច្ច័យទាន

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ។

**មាត្រា ១២០០.-** មរណភាពរបស់អច្ច័យលាភី

១-អច្ច័យទាន ពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាព នៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

៣-ក្នុងករណីដែលសន្តតិជនដែលត្រូវបានសន្មត ជាអច្ច័យលាភី បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងចំពោះការយកបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៩៦ (មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍) នៃក្រមនេះ មកអនុវត្តឡើយ ។

**មាត្រា ១២០១.–** ការបោះបង់អច្ច័យទាន

១-នៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីការបោះបង់សន្តតិកម្ម ។

២-ការបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

**មាត្រា ១២០២.–** ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ដោយកំណត់អំឡុងពេលសមរម្យ ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

**មាត្រា ១២០៣.–** ការបោះបង់ ឬ ការទទួលស្គាល់ ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៤.–** ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

១-ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាន ពុំអាចលុបចោលវិញបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទទួលស្គាល់ និង ការបោះបង់អច្ច័យទាននេះ ។

**មាត្រា ១២០៥.–** ការទទួលស្គាល់ ឬ បោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

១-ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ ។

២-ទោះបីបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបោះបង់អច្ច័យទានមានកំណត់ បានដែរ ។

**មាត្រា ១២០៦.–** សិទ្ធិទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់តាំងពីពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យ-ទានបាន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៧.–** អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតនៅក្នុងមតិក

អច្ច័យទាន ពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមតិក នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

**មាត្រា ១២០៨.–** អច្ច័យទាននៃវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

បើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទាន ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

**មាត្រា ១២០៩.–** ឧបាទេសកម្មលើវត្ថុ

១-បើម្ចាស់បណ្តាំមានសិទ្ធិទាមទារប្រាក់សំណង ចំពោះតតិយជន ដោយការបាត់បង់ ឬ កែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬ បាត់បង់ការកាន់កាប់វត្ថុនោះ ត្រូវសន្មតថាបានយកសិទ្ធិនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា ឬ

ច្របល់គ្នានឹងវត្ថុផ្សេងទៀត បើម្ចាស់បណ្ដាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) នៃក្រមនេះ ត្រូវសន្មតថា ម្ចាស់បណ្ដាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិអវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

**មាត្រា ១២១០.-** ឧបាទេសកម្មលើវត្ថុ នៃអច្ច័យទាននៃសិទ្ធិលើបំណុល

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន បើម្ចាស់បណ្ដាំបានទទួលសំណង ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមត៌ក ត្រូវសន្មតថាបានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវសន្មតថាបានយកប្រាក់ និង ប្រាក់បញ្ញើ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមត៌ក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានសង ។

**មាត្រា ១២១១.-** ការទទួលខុសត្រូវរបស់អច្ច័យលាភី នៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

១-ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។

២-បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២១២.-** សិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល

១-អច្ច័យលាភីសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន ។

២-បើមត៌កទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឱ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។

## ផ្នែកទី ៧
## ការប្រតិបត្តិមតកសាសន៍

**មាត្រា ១២១៣.–** ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

១-អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះមតកសាសន៍ដែលបានធ្វើដោយលិខិតយថាភូត ។

៣-លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ ។

៤-បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

៥-ចំពោះលិខិតមតកសាសន៍ ទោះបីជាបានបើកនៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ក៏ដោយ មិនត្រូវបាត់បង់អានុភាព ដោយសារតែមូលហេតុនោះឡើយ ។

**មាត្រា ១២១៤.-** ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

១-បើម្ចាស់បណ្តាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-បើជនដែលបានទទួលអាណត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២១៥.-** ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

បើអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតក-សាសន៍នោះ ត្រូវអនុវត្តភារកិច្ចនោះ ភ្លាមៗ ។

**មាត្រា ១២១៦.-** ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ

១-សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ ហើយដាស់តឿន ចំពោះជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតក-សាសន៍ ឱ្យឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន ។ បើអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់ ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីការងារនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតតិយជន ដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ឱ្យបានឆាប់រហ័ស ។ ក្នុងករណីនេះ បើតតិយជននោះមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ នៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីអាណត្តិនោះ ។

**មាត្រា ១២១៧.-** បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និង ជន

ធនក្ស័យ ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ។

**មាត្រា ១២១៨.-** ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ បើបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ១២១៩.-** ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

១-អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-សន្តតិជន អាចមានវត្តមាន នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។

**មាត្រា ១២២០.-** សិទ្ធិអំណាច មុខនាទី នៃអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។

**មាត្រា ១២២១.-** ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន

១-បើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមត៌ក ឬ ធ្វើសកម្ម-ភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ។

២-ការចាត់ចែងដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ។

**មាត្រា ១២២២.-** ការប្រតិបត្តិមតកសាសន៍ ចំពោះទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់

ក្នុងករណីមតកសាសន៍ ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ បញ្ញត្តិចាប់ពីមាត្រា ១២១៩ (ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ) រហូតដល់មាត្រា ១២២១

(ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះតែទៅលើទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២២៣.–** ឋានៈនៃអ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតក-សាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ។

២-សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ ចំពោះសន្តតិជន ។

**មាត្រា ១២២៤.–** សិទ្ធិជ្រើសតាំងបន្ត របស់អ្នកប្រតិបត្តិមតកសាសន៍

១-បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង នៅក្នុងមតកសាសន៍ ។

២-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។ បើអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចនោះ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។

**មាត្រា ១២២៥.–** សហអ្នកប្រតិបត្តិមតកសាសន៍

១-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ អ្នកប្រតិបត្តិមតក-សាសន៍នីមួយៗ អាចធ្វើសកម្មភាពរក្សាទុកបាន ។

**មាត្រា ១២២៦.–** កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន ។

២-ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមតិក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២២៧.–** ការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

១-បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើអ្នកប្រតិបត្តិមតកសាសន៍ បានធ្វេសប្រហែសក្នុងភារកិច្ច ឬ បើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់ជននោះបាន ។

**មាត្រា ១២២៨.–** សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក ។ ប៉ុន្តែ មិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ ។

**មាត្រា ១២២៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាណត្តិ

បញ្ញត្តិស្តីពីអាណត្តិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ។

# ជំពូកទី ៤
# ភាគបម្រុង

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៣០.-** អ្នកមានសិទ្ធិលើភាគបម្រុង

១-បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជន អាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិ ដូចខាងក្រោមនេះ :

ក-១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្តាយ ឬ ជីដូន ជីតាប៉ុណ្ណោះ ។

ខ-១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង ។

២-ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗ អាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមត៌កបាន ។

៣-បញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង មាត្រា ១១៥៨ (ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះភាគបម្រុង ។

**មាត្រា ១២៣១.-** ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) និង តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្មដែលបានកំណត់ក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) នៃក្រមនេះ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ ។

២-សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់ ត្រូវកំណត់តម្លៃនោះ ដោយផ្អែកតាមការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែល

ត្រូវបានជ្រើសតាំងដោយតុលាការ ។

៣-កាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលផងដែរ នូវសោហ៊ុយបុណ្យសពតាមឋានៈរបស់មតកជន ។

**មាត្រា ១២៣២.-** ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ប្រទានកម្មដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវក្លាយជាមូលដ្ឋានក្នុងការគណនាភាគបម្រុង លើកលែងតែផលប្រយោជន៍ពិសេសដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ :

ក- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។

ខ- ក្រៅពីប្រទានកម្មដែលបានកំណត់ក្នុងចំណុច ក ខាងលើនេះ ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ។

២-នៅក្នុងជំពូកទី ៤ (ភាគបម្រុង) នេះ ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ត្រូវចាត់ទុកថាជាប្រទានកម្ម ។

**មាត្រា ១២៣៣.-** ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និង ប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) ខាងលើនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ការកំណត់ចំណែកមត៌ក និង ការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនោះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ ។

**មាត្រា ១២៣៤.-** ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារបានដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និង ចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម ។

## ផ្នែកទី ២
## វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

**មាត្រា ១២៣៥.-** ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និង អ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ ។

**មាត្រា ១២៣៦.-** លំដាប់នៃការកាត់បន្ថយ

ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ជាមុនទេ ។

**មាត្រា ១២៣៧.-** ការកាត់បន្ថយអច្ច័យទាន ជាអាទិ៍

១-ដំបូង ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន នៅក្នុងពេលជាមួយគ្នា ហើយប្រសិនបើនៅតែខ្វះ ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ។

២-អច្ច័យទាន ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ ។

បញ្ញត្តិនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចំណែកមត៌កដែលបានកំណត់តាមវិធីធ្វើអនុប្បទានទ្រព្យសម្បត្តិដែលមានកំណត់ តែមួយចំណុច ឬ ច្រើនចំណុច ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានដែលធ្វើចំពោះសន្តតិជន និង ចំណែកមត៌កដែលបានកំណត់នោះ ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ផ្នែកដែលលើសពីចំនួនប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះ ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ ។

៣-ចំណែកមត៌កតាមមតកសាសន៍ ដែលបានកំណត់ជាភាគនៃមត៌ក ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយធ្វើការផ្លាស់ប្តូរភាគនោះ ។

៤-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈពិសេសផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមទៅតាមឆន្ទៈនោះ ។

**មាត្រា ១២៣៨.-** លំដាប់នៃការកាត់បន្ថយប្រទានកម្ម ជាអាទិ៍

១-ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មក ត្រូវធ្វើចំពោះប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនមកជាបន្តបន្ទាប់ ។

២-បើបានធ្វើប្រទានកម្ម ឬ ទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំនៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះអាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ។

**មាត្រា ១២៣៩.-** ការសងផលមកវិញ

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ក្រៅពីទ្រព្យសម្បត្តិ ឬ ប្រាក់សំណងដែលត្រូវសងមកវិញនោះ ត្រូវសងមកវិញផងដែរនូវផលដែលកើតឡើងក្រោយពីថ្ងៃដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ ។

**មាត្រា ១២៤០.-** បន្ទុកនៃការខាតបង់ ដោយអសាធនភាព

ការខាតបង់ដែលកើតឡើងដោយសារអសាធនភាព របស់សហសន្តតិជន អច្ច័យ-

លាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ ត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ។

**មាត្រា ១២៤១.–** ការកាត់បន្ថយប្រទានកម្មដែលមានភ្ជាប់បន្ទុក

ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក ដែលបានដកតម្លៃនៃបន្ទុកចេញពីក្នុងតម្លៃនៃកម្មវត្ថុនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយបាន ។

**មាត្រា ១២៤២.–** ការកាត់បន្ថយចំពោះកិច្ចសន្យា ជាអាទិ៍ ដែលត្រូវចាត់ទុកថាជាប្រទានកម្ម

១-កិច្ចសន្យាដែលបានធ្វើដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាប្រទាន-កម្ម តែក្នុងករណីដែលត្រូវបានធ្វើឡើង ដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងប៉ុណ្ណោះ ។ ក្នុងករណីនេះ បើអ្នកមានសិទ្ធិលើភាគបម្រុង ទាមទារឱ្យធ្វើការកាត់បន្ថយនោះ អ្នកនោះត្រូវសងតម្លៃថ្នូរនោះមកវិញ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលើកលែងកាតព្វកិច្ច ដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ។

**មាត្រា ១២៤៣.–** ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម

១-បើសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ បានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដទៃ ជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាត់ចែងនោះ ទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ។ ប៉ុន្តែ ប្រសិនបើអនុប្បទានិកនោះបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង នៅពេលធ្វើអនុប្បទាន អ្នកមានសិទ្ធិលើភាគបម្រុងក៏អាចទាមទារឱ្យកាត់បន្ថយចំពោះអនុប្បទានិកនោះ បានដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក បានបង្កើតសិទ្ធិលើកម្មវត្ថុនៃប្រទានកម្មនោះ ។

**មាត្រា ១២៤៤.-** សំណងដោយបង់តម្លៃ

១-សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសង បាន ដោយបង់តម្លៃនៃចំណែកមត៌កដែលបានកំណត់ តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬ តម្លៃនៃកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវទទួលការកាត់បន្ថយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១២៤៣ (ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម) ខាងលើនេះ ។

## ផ្នែកទី ៣
## ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

**មាត្រា ១២៤៥.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម និង ការកំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ ។ សិទ្ធិទាមទារឱ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្ដើមសន្តតិកម្ម ។

**មាត្រា ១២៤៦.-** ការបោះបង់ភាគបម្រុង

ភាគបម្រុង អាចបោះបង់ចោលទាំងអស់ ឬ មួយផ្នែកបាន ។ ប៉ុន្តែ ការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្ដើមសន្តតិកម្ម មានអានុភាព លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១២៤៧.–** ករណីជាសហសន្តតិជន

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ ។

# ជំពូកទី ៥
# ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៤៨.–** អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយកម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិ-ជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមត៌កបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

**មាត្រា ១២៤៩.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនទទួលមរណភាព

បើសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះ បានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។

**មាត្រា ១២៥០.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនជាអនីតិជន ជាអាទិ៍

បើសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។

**មាត្រា ១២៥១.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

១-ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសន្តតិជនបានចាត់ចែងមត៌កដើម្បីសងកាតព្វកិច្ចផ្សេង ដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម នៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ បញ្ញត្តិនៃចំណុច ក មាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

**មាត្រា ១២៥២.-** ការលុបចោលការយល់ព្រម ឬ ការបោះបង់

១-ការយល់ព្រម និង ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះជានៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ក៏ដោយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងចំពោះការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម ដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈឡើយ ។ ប៉ុន្តែ សិទ្ធិលុបចោលនេះ ត្រូវរលត់ បើពុំបានអនុវត្ត នៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ

គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមធ្វើសន្តតិកម្ម ។

៣-បុគ្គលដែលមានបំណងចង់លុបចោល ការយល់ព្រមដោយកម្រិត ឬ ការបោះបង់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវដាក់ពាក្យសុំលុបចោលនោះ ទៅតុលាការ ។

**មាត្រា ១២៥៣.–** ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម

សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលយល់ព្រមលើសន្តតិកម្មបានឡើយ ។

## ផ្នែកទី ២
## ការយល់ព្រម

**មាត្រា ១២៥៤.–** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១២៥៥.–** ការយល់ព្រមទាំងស្រុងតាមច្បាប់

ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ :

ក-បើសន្តតិជនបានចាត់ចែងមតិកនោះ ទាំងអស់ ឬ មួយភាគ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ-បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

គ-ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ។

**មាត្រា ១២៥៦.-** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៥៧.-** វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

**មាត្រា ១២៥៨.-** អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយល្បាកុល-

ភាពឡើយ ។

**មាត្រា ១២៥៩.-** ករណីដែលហេតុនៃការយល់ព្រមតាមច្បាប់ កើតឡើង ក្រោយការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ គ នៃមាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិ-ជននោះ ត្រូវចាត់ទុកថា សន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍នៃការយល់ព្រមដោយកម្រិត មិនបង្កើតអានុភាព តាំងពីដំបូងមក ។

២-បើមានមូលហេតុដូចកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសហ-សន្តតិជនម្នាក់ ឬ ច្រើននាក់ ដែលបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលពុំអាចទទួលការសងដោយមតិក តាមចំណែកមតិកនីមួយៗនោះបាន ។

## ផ្នែកទី ៣
## ការបោះបង់

**មាត្រា ១២៦០.-** ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ ។

**មាត្រា ១២៦១.-** អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។

# ជំពូកទី ៦
# ការគ្រប់គ្រង និង ការបែងចែកមត៌ក

## ផ្នែកទី ១
## ការគ្រប់គ្រងមត៌ក

**មាត្រា ១២៦២.–** ការរក្សាទុក និង ការគ្រប់គ្រងមត៌ក

១-សន្តតិជនដែលកាន់កាប់មត៌ក នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក ។ ប៉ុន្តែ ការរក្សាទុក និង ការគ្រប់គ្រងនេះ ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៦៣ (ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍) ខាងក្រោមនេះ ។

២-ទោះបីជានៅមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ ។ ទោះបីជានៅក្រោយពេលបោះបង់សន្តតិកម្មក៏ដោយ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ រហូតដល់ពេលបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់នោះ អាចចាប់ផ្តើមធ្វើការគ្រប់គ្រងមត៌កនោះបាន ។

**មាត្រា ១២៦៣.–** ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍

បើបានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវធ្វើការគ្រប់គ្រងមត៌ក ។ ប៉ុន្តែ ប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២៦៤.–** អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន

១-បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ គ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក ។

២-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១២៥៣ (ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម) នៃក្រមនេះ ក៏ដោយ អ្នកគ្រប់គ្រងជាបណ្តោះអាសន្នដែលត្រូវបានជ្រើសតាំងដោយបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ គឺជាអ្នកទទួលបន្ទុកក្នុងបណ្តឹងនោះ ចំពោះសិទ្ធិទាមទារដែលទាក់ទងនឹងមត៌ក នៅក្នុងនាមជាអ្នកទទួលបន្ទុកក្នុងបណ្តឹងរបស់សន្តតិជននៃមតកជន ដោយបញ្ជាក់ឈ្មោះមតកជននោះផង រហូតដល់ពេលដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មនោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងជាបណ្តោះអាសន្ន ។

**មាត្រា ១២៦៥.–** សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក

សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ សោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះ ។

## ផ្នែកទី ២
## ការបែងចែកមត៌ក

**មាត្រា ១២៦៦.–** ការពិភាក្សាបែងចែកមត៌ក

១-សហសន្តតិជនអាចចាប់ផ្តើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ចំពោះការផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌ក ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៧៧ (ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ) នៃក្រមនេះ ឬ ចំពោះករណីដែលមតកជនហាមឃាត់ការបែងចែកមត៌កតាមមតកសាសន៍ ការបែងចែកមត៌កពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ ។

២-ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ ។

**មាត្រា ១២៦៧.–** មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌កនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់ល័ក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

**មាត្រា ១២៦៨.–** សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ ។

**មាត្រា ១២៦៩.–** សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍

បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌ក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះ និង មិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ ។

**មាត្រា ១២៧០.–** ការបែងចែកដោយតុលាការ

១-បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការបែងចែកមត៌កនោះបាន ។